

# រក្សាសុវត្ថិភាពកុមារពី ការរំលោភបំពានផ្លូវភេទ

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល ក្នុងវេទិកាពិភាក្សា ជាមួយឪពុកម្តាយ និងអ្នកថែទាំ

Australian Aid

World Vision

# រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួលក្នុងវេទិកាពិភាក្សា ជាមួយឪពុកម្ដាយ និងអ្នកថែទាំ

ISBN: 978-0-9925214-9-3
រក្សាសិទ្ធិ © ឆ្នាំ ២០១៤ ដោយអង្គការទស្សនៈពិភពលោកកម្ពុជា

សម្ភារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះអាចយកទៅប្រើប្រាស់បាន និងកែសម្រួលដោយសេរី ឱ្យតែមានការបញ្ជាក់ប្រភពឯកសារត្រឹមត្រូវថាបានដកស្រង់ពីប្រភពឯកសារនេះ។ អ្នកអាចទាញយកឯកសារអេឡិចត្រូនិចពីគេហទំព័រ http://www.childsafetourism.org ឬ http://wvi.org/asiapacific/childsafetourism. ។ សូមផ្ញើសំណួរ ឬយោបល់ត្រឡប់ទៅកាន់អ៊ីម៉ែល childsafetourism@wvi.org.

រូបថត: រូបថតទាំងអស់គឺរក្សាសិទ្ធិដោយអង្គការទស្សនៈពិភពលោក។ រូបថតទំព័រមុខដោយ គង់ សុភត្រ័។ រូបកុមារ ដែលប្រើក្នុងសម្ភារអប់រំនេះគ្រាន់តែជាការលម្អប៉ុណ្ណោះគម្រោងកុមារភាពមិនយករូបពិតរបស់កុមាររងគ្រោះដោយការរំលោភបំពានមកប្រើទេ ។ អង្គការទស្សនៈពិភពលោកធ្វើការដោយយោងតាមបទដ្ឋានការពារកុមារក្នុងការថតរូបរបស់កុមារ ។

រចនាដោយ Inís Communication.

គម្រោងកុមារភាពគឺជាការផ្តួចផ្តើមគំនិតមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ ២០១១-២០១៤)។



# រក្សាសុវត្ថិភាពកុមារពី ការរំលោភបំពានផ្លូវភេទ

កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល ក្នុងវេទិកាពិភាក្សា
ជាមួយឪពុកម្តាយ និងអ្នកថែទាំ

# សេចក្ដីថ្លែងអំណរគុណ

ការបង្កើតឲ្យមានកញ្ចប់ឧបករណ៍ស្ដីពីវេទិកាពិភាក្សា ដែលស្ថិតក្រោមកិច្ចដឹកនាំរបស់ Aarti Kapoor ប្រធានកម្មវិធី និងAfrooz Kaviani Johnson ប្រធានផ្នែកបច្ចេកទេស គម្រោងកុមារភាព ផ្ទែកបង្ការ បានទទួលការចូលរួម ពីសំណាក់មនុស្ស និងអង្គការជាច្រើន។ សូមថ្លែងអំណរគុណ ចំពោះទីប្រឹក្សាម្នាក់ គឺ Anita Dodds ដែលបានរៀបចំធ្វើអត្ថបទពង្រៀងលើកទីមួយ នៃសៀវភៅស្ដីពីវេទិកាពិភាក្សាក្នុង ឆ្នាំ២០១២។ សូមថ្លែងអំណរគុណចំពោះលោក ផង់ ចិន្ដា, Chalermrat Chaiprasert, Chansamone Bouakhamvongsa និង Nguyen Khanh Hoi អ្នកសម្របសម្រួលថ្នាក់ជាតិសម្រាប់គម្រោងកុមារភាព ផ្ទែកបង្ការ នៃ ប្រទេសកម្ពុជា ថៃឡាវ និងប្រទេសវៀតណាម ដែលបានចូលរួមចំណែក ត្រួតពិនិត្យ និងកែសម្រួល រួមទាំងប្រើប្រាស់ថ្នាក់ជាតិ នូវកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សាចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៤។

លើសពីនេះ ក៏សូមថ្លែងអំណរគុណ ចំពោះគោលគំនិត និងព័ត៌មានត្រឡប់វិញសំខាន់ៗ ដែលបានមកពីសហការី រាប់បញ្ចូលទាំង Kristine Mikhailidi អ្នកឯកទេសផ្នែករៀបចំកម្មវិធីការពារកុមាររបស់អង្គការទស្សនៈពិភពលោក អន្តរជាតិ និងដៃគូនានានៅតាមទីកន្លែង ដែលបានប្រើប្រាស់គំនិតអប់រំសំខាន់ៗទាំងនេះ។ សូមអរគុណចំពោះ Verity Kowal ជាមន្ត្រីផ្សព្វផ្សាយ និងទំនាក់ទំនងនៃគម្រោងកុមារភាព ផ្ទែកបង្ការ ដែលបានជួយបញ្ចប់ការ បោះពុម្ពសៀវភៅណែនាំ ស្ដីពីវេទិកាពិភាក្សា ក្នុងឆ្នាំ២០១៤។ សូមថ្លែងអំណរគុណផងដែរ ចំពោះ អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ លោក ហ៊ឹម ជា និង លោកស្រី សាយ សុម៉ាលី និងលោកស្រី ស៊ឹម សុជាតា  ជាទីប្រឹក្សាដែលបានចូលរួមក្នុងការបង្កើតសម្ភារនេះឡើងជាភាសាខ្មែរ ។

# មាតិកា


អារម្ភកថា ............ i

សារតា ............ ii

គោលបំណងនៃកញ្ចប់ឧបករណ៍ស្ដីពីវេទិកាពិភាក្សា ............ iii

របៀបប្រើកញ្ចប់ឧបករណ៍ស្ដីពីវេទិកាពិភាក្សា ............ iv

ផ្នែកទី១៖ ការចាប់ផ្ដើម ............ 1

តើនណាអាចសម្របសម្រួលវេទិកាពិភាក្សានេះបាន? ............ 3

តើអ្នកណាខ្លះ គួរចូលរួមក្នុងវេទិកាពិភាក្សានេះ? ............ 4

តើលទ្ធផលរំពឹងទុកពីវគ្គសិក្សានេះមានអ្វីខ្លះ? ............ 5

តើគេត្រូវការអ្វីខ្លះដើម្បីរៀបចំវេទិកាពិភាក្សានេះ ............ 6

តើគេត្រូវការពេលប៉ុន្មាន ដើម្បីដំណើរការវេទិកានេះ? ............ 8

គោលការណែនាំពិសេស សម្រាប់ការបណ្ដុះបណ្ដាលស្ដីពីកិច្ចការពារកុមារ ............ 10

ផ្នែកទី២៖ ការណែនាំតាមរយៈស្លាយ ............ 13

ផ្នែកទី៣៖ ឧបសម្ព័ន្ធ ............ 57

ឧបសម្ព័ន្ធទី១៖ កាតយកតាមខ្លួន ............ 59

ឧបសម្ព័ន្ធទី២៖ ទម្រង់វត្តមានរបស់អ្នកចូលរួម ............ 70

ឧបសម្ព័ន្ធទី៣៖ សំណួរមុនចូលមេរៀន ............ 71

ឧបសម្ព័ន្ធទី៤៖ សំណួរក្រោយមេរៀន ............ 72

ឧបសម្ព័ន្ធទី៥៖ កាតចម្លើយសំណួរមុនចូលមេរៀននិងក្រោយមេរៀន ............ 73

ឧបសម្ព័ន្ធទី៦៖ គំរូសម្រាប់ការវិភាគសំណួរមុនចូលមេរៀននិងក្រោយមេរៀន ............ 74

ឧបសម្ព័ន្ធទី៧៖ ទម្រង់ស្ដីពីមតិរបស់ខ្ញុំ ............ 75

ឧបសម្ព័ន្ធទី៨៖ ទម្រង់គំរូរបាយណ៍ក្រោយការបណ្ដុះបណ្ដាល ............ 77

# បុព្វកថា

វិស័យទេសចរណ៍នៅប្រទេសកម្ពុជា មានការរីកចម្រើនជាបន្តបន្ទាប់ យ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០១៣  ប្រទេសកម្ពុជា បានទទួលស្វាគមន៍ដំណើរកំសាន្តរបស់ភ្ញៀវទេសចរអន្តរជាតិចំនួន ៤.២លាននាក់ ដោយចំនួននេះបានកើនឡើង ១៧%ធៀបនឹងឆ្នាំ២០១២។ ការអភិវឌ្ឍន៍វិស័យទេសចរណ៍ កំពុងនាំមកនូវឱកាសជាច្រើនសម្រាប់ប្រទេសកម្ពុជា និងសហគមន៍នានា។

ក្នុងពេលជាមួយគ្នានេះ យើងក៏បានសង្កេតឃើញនូវចំណុចអវិជ្ជមាននៃទំនាក់ទំនងរវាងវិស័យទេចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ។ នៅក្នុងប្រទេសកម្ពុជា យើងបានឃើញកុមារងាយរងគ្រោះ និង ក្រុមគ្រួសាររបស់កុមារទាំងនោះ ត្រូវបានទាក់ទាញឲ្យចូលទៅកាន់ ទីកន្លែងគោលដៅទេសចរណ៍ ដើម្បីរកប្រាក់ចំណូល។ កុមារា និងកុមារី អាចធ្វើការ នៅក្នុងឧស្សាហកម្មទេសចរណ៍ នៅក្នុងលក្ខខណ្ឌដែលមិនអំណោយផលដល់សុវត្ថិភាព និង សុខុមាលភាពរបស់ពួកគេ។ កុមារដែលរកប្រាក់ចំណូលបានពីភ្ញៀវទេសចរ តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ ឬការខាត់ស្បែកជើង ទំនងជាមិនសូវបានទៅសាលារៀនឡើយ។ កុមារទាំងនេះ ត្រូវប្រឈមមុខនឹងភាពងាយរងគ្រោះក្នុងកម្រិតខ្ពស់ នៅក្នុងការរំលោភបំពានលើរាងកាយ  អារម្មណ៍ និងផ្លូវភេទ។

នៅក្នុងអនុតំបន់ទន្លេមេគង្គ ទាំងកុមារា ទាំងកុមារី គឺជារឿយៗបានក្លាយខ្លួនជាជនរងគ្រោះ ដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ កុមារដែលធ្វើការ នៅតាមចិញ្ចើមថ្នល់ ឬក្នុងវិស័យក្រៅប្រព័ន្ធ គឺជាគោលដៅរបស់អ្នករំលោភបំពានផ្លូវភេទកុមារ។ ក្រៅពីនេះ អ្នករំលោភបំពានអាចនឹងតម្រង់ឆ្ពោះទិសទៅរកកុមារងាយរងគ្រោះ តាមរយៈការបំរើការងារនៅក្នុងសាលារៀន ឬសេវាថែទាំកុមារតាមមណ្ឌលនានា។

តាមរយៈគម្រោងកុមារភាពផ្អែកបង្ការ រដ្ឋាភិបាលអូស្ត្រាលីបានបង្កើតឱ្យមានការវិនិយោគមួយយ៉ាងសំខាន់ ដើម្បីប្រយុទ្ធប្រឆាំង នឹងទម្រង់នៃការកេងប្រវ័ញ្ចដ៏ជាក់លាក់នេះ នៅក្នុងអនុតំបន់ទន្លេមេគង្គ។ គម្រោងកុមារភាពផ្អែកបង្ការ គឺជាគំនិតផ្តួចផ្តើមមួយរបស់ រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយថវិកា ៧,៥ លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៏ និងការធ្វើដំណើរ ក្នុងអនុតំបន់ទន្លេមេគង្គ (ឆ្នាំ២០១១-២០១៤)។ គម្រោងកុមារភាពនេះ ពឹងផ្អែកលើការជួយឧបត្ថម្ភ ក្នុងរយៈពេលវែងរបស់ប្រទេសអូស្ត្រាលីសម្រាប់កម្មវិធីនានា ដើម្បីការពារនិងទប់ស្កាត់ការរំលោភបំពានមកលើកុមារ ឱ្យបានកាន់តែប្រសើរឡើង។

គម្រោងកុមារភាពផ្អែកបង្ការ បាននាំមកនូវកិច្ចសហប្រតិបត្តិការគ្នា រវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀននិងឧក្រិដ្ឋកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏ធ្ងន់ធ្ងរ នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះដំណើរការនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម។ គម្រោងនេះប្រើប្រាស់ទាំងវិធីបង្ការ និងការពារ។

នៅក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោក កំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍នានា និងរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា ដើម្បីការពារកុមារា និងកុមារី ឱ្យរួចផុតពីការក្លាយខ្លួនជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទ ទាំងនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។

តាមការស្រាវជ្រាវរបស់អង្គការទស្សនៈពិភពលោកបានបង្ហាញថា មានកង្វះខាតយ៉ាងខ្លាំងផ្នែកចំណេះដឹង និងការយល់ដឹងនៅក្នុងកម្រិតសហគមន៍ពាក់ព័ន្ធទៅនឹងប្រធានបទ “អ្វីជាការរំលោភបំពានផ្លូវភេទ ហើយតើវាអាច កើតឡើងដូចម្តេច?” ។ តាមពិតទៅ ឪពុកម្តាយ និងអ្នកថែទាំ មានការយល់ដឹង និងចំណេះដឹងតិចតួចទាក់ទងទៅនឹងសមាជិកទាំងឡាយនៅក្នុងសហគមន៍។  យើងដឹងថា អ្នករំលោភបំពានឆក់ឱកាសទាញយកប្រយោជន៍ពីកង្វះខាតផ្នែកចំណេះដឹង និងការយល់ខុសទាំងនេះ ដើម្បីបានទៅជួប និងរំលោភបំពានលើកុមារា

និងកុមារី។ វាចាំបាច់ណាស់សម្រាប់ការចែករំលែកព័ត៌មានច្បាស់លាស់មួយ ទៅឱ្យសមាជិកទាំងអស់គ្នានៅក្នុងសហគមន៍ពីការបំពានផ្លូវភេទ និងវិធីការពារការរំលោភបំពានទាំងនេះ។ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ ឪពុកម្ដាយ និងអ្នកថែទាំទាំងឡាយ ទទួលបាននូវព័ត៌មានច្បាស់លាស់ និងទាន់សភាពការណ៍អំពីការរំលោភបំពានកុមារ ដើម្បីឱ្យពួកគាត់អាចការពារកូនៗរបស់ពួកគាត់ពីគ្រោះថ្នាក់បាន និងអប់រំពួកគេអំពីរបៀបរក្សាសុវត្ថិភាពខ្លួន។  តួនាទីរបស់ឪពុកម្ដាយ និងអ្នកថែទាំក្នុងការការពារ កូនៗពីគ្រោះថ្នាក់ពិតជាមានសារៈសំខាន់ណាស់។

ហេតុនេះហើយ *រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖ កញ្ចប់ឧបករណ៍ សម្រាប់អ្នកសម្របសម្រួលក្នុងវេទិកាពិភាក្សាជាមួយឪពុកម្ដាយ និងអ្នកថែទាំ* ពិតជាមានតម្លៃគួរត្រូវបោះពុម្ពមែន ។ សៀវភៅនេះផ្ដល់នូវការណែនាំងាយស្រួលអនុវត្តតាម និងសម្ភារឧបទេសផ្សេងៗ ដែលអាចឱ្យអ្នកសម្របសម្រួលប្រើប្រាស់ ដើម្បីរៀបចំ វេទិកាពិភាក្សាជាមួយឪពុកម្ដាយ និងអ្នកថែទាំកុមារ និងក្មេងជំទង់។ សៀវភៅនេះមានអ្វីៗ ដែលអ្នកសម្របសម្រួល ត្រូវការដើម្បីរៀបចំមេរៀនការប្រាស្រ័យទាក់ទងគ្នា ទាំងក្នុងបរិបទផ្លូវការ និងក្រៅផ្លូវការដោយប្រើប្រាស់សម្ភារ និងបច្ចេកវិជ្ជាតិចតួច។  គំនិតនានានៅក្នុងកញ្ចប់ឧបករណ៍នេះ ត្រូវបាន អង្គការសហគមន៍នានា សាលារៀន និងទីភ្នាក់ងាររដ្ឋាភិបាល យកមកប្រើប្រាស់រួចហើយ នៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំសង្ឃឹមថាដោយមានការបោះពុម្ពផ្សព្វផ្សាយជាផ្លូវការនេះ ព័ត៌មាននានានៅក្នុងសៀវភៅនេះ នឹងធ្លាក់ទៅដល់ដៃ របស់ឪពុកម្ដាយ និងអ្នកថែទាំកាន់តែច្រើនឡើងទូទាំងប្រទេសកម្ពុជា និងផ្ដល់អំណាចឱ្យពួកគាត់ដើម្បីការពារកូនៗរបស់គាត់ឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទជាមិនខាន ។

យើងសង្ឃឹមថា ការបោះពុម្ពផ្សាយជាផ្លូវការនេះ នឹងផ្ដល់ព័ត៌មានត្រឹមត្រូវ ដល់កុមារា និងកុមារីកាន់ តែច្រើននៅទូទាំងប្រទេស និងចូលរួមចំណែកក្នុងកិច្ចការពារកុមារ ឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។

សូមលើកទឹកចិត្តឱ្យមានការប្រើប្រាស់ដ៏ទូលំទូលាយនូវអត្ថបទបោះពុម្ពនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរដ្ឋាភិបាលអូស្ត្រាលី សម្រាប់ការវិនិយោគលើកិច្ចការដ៏មានសារសំខាន់ទាំងនេះ។

# សារតា

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្រ្តាលី ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភផ្លូវភេទក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរនៅប្រទេសកម្ពុជា ឡាវ ថៃ និង ប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បានមកនូវកិច្ចសហការ រវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ គម្រោងនេះ ប្រើប្រាស់ទាំងវិធីសាស្រ្តបង្ការ និងការពារ។ អង្គការទស្សនៈពិភពលោក បានសហការជាដៃគូជាមួយអាជ្ញាធរ និងសហគមន៍នានា ដើម្បីការពារកុមារមិនឲ្យក្លាយ ជាជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ តាមរយៈព័ត៌មានការអប់រំ និងការទំនាក់ទំនង អង្គការទស្សនៈពិភពលោក មានគោលដៅផ្តល់ជូននូវចំណេះដឹង និងជំនាញនានាដល់សមាជិកសហគមន៍ ក្រុមហ៊ុនអាជីវកម្ម និងមន្រ្តីអាជ្ញាធរនានា ដើម្បីបង្កើតបរិស្ថានទេសចរណ៍មួយ ដែលកាន់តែមានសុវត្ថិភាពប្រសើរឡើងសម្រាប់កុមារ។

ដោយផ្អែកលើលទ្ធផលស្រាវជ្រាវ ស្តីពីការយល់ដឹងរបស់សហគមន៍ទៅលើការរំលោភបំពានផ្លូវភេទកុមារ ការអប់រំ និងការផ្សព្វផ្សាយរបស់គម្រោងកុមារភាពផ្នែកបង្ការ បានផ្តល់ព័ត៌មានថ្មី និងសមស្របទៅតាមទំនៀមទម្លាប់ ដើម្បីបំពេញកង្វះខាតចំណេះដឹង និងបើកបង្ហាញនូវអាថ៌កំបាំង និងការយល់ខុសនានា ពីការរំលោភបំពានផ្លូវភេទកុមារដែលអាចទុកឲ្យកុមារងាយនឹងត្រូវរងគ្រោះដោយសារការរំលោភបំពាន។ អ្នកតំណាងសហគមន៍ (អ្នកទទួលបន្ទុក នៅក្នុងសហគមន៍ដែលមានមុខងារ ជាអ្នកមានអំណាច ជាអ្នកដឹកនាំ និងជាអ្នកមានឥទ្ធិពល) មានតួនាទីយ៉ាងសំខាន់ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពាន និងដើម្បីការពារមិនឲ្យការរំលោភបំពានកើតឡើង និង/ឬមានជាបន្តទៀត។ វាចាំបាច់ដែលត្រូវ ទទួលបានព័ត៌មានថ្មីៗនិងត្រឹមត្រូវ ស្តីពីការរំលោភបំពានផ្លូវភេទលើកុមារ។

# គោលបំណងនៃកញ្ចប់ឧបករណ៍ សម្រាប់វេទិកាពិភាក្សា

វេទិកាពិភាក្សាសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ គឺជាវគ្គដែលមានភាពបត់បែន ហើយអាចកែសម្រួលបាន ដើម្បីធ្វើឱ្យអ្នកចូលរួមមានចំណេះដឹង និងជំនាញ ដើម្បីការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទ នៅក្នុងសហគមន៍ របស់ខ្លួន។ កញ្ចប់ឧបករណ៍វេទិកាពិភាក្សា ផ្ដល់ឱ្យអ្នកសម្របសម្រួលនូវឧបករណ៍ និង គោលការណ៏ណែនាំ ដែលអាចធ្វើបានយ៉ាងងាយស្រួលដើម្បីរៀបចំវេទិកាពិភាក្សាគ្នារយៈពេលពីរម៉ោង ជាមួយនឹងឪពុកម្ដាយ និងអ្នកថែទាំ។ ព័ត៌មានសំខាន់ៗ ដែលតម្រូវឱ្យមាននៅវគ្គសិក្សានេះ គឺមាននៅក្នុងកញ្ចប់ ឧបករណ៍សម្រាប់វេទិកា ពិភាក្សានេះ។ អ្នកសម្របសម្រួល គួរតែអានកញ្ចប់ឧបករណ៍ស្ដីពីវេទិកាពិភាក្សានេះ ឱ្យបានច្បាស់ មុននឹងចាប់ផ្ដើមកម្មវិធីណាមួយ ហើយត្រូវប្រើសៀវភៅនេះ ដើម្បីជាជំនួយក្នុងការរៀបចំវេទិកា ពិភាក្សានេះឱ្យបានល្អ។ ឯកសារនេះអាចមានការកែសម្រួលបន្ថែម ដើម្បីឱ្យសមស្របទៅនឹងអ្នកចូលរួម។ អ្នកអាច ទាញយកឯកសារជាអេឡិចត្រូនិចនៃសៀវភៅណែនាំស្ដីពីវេទិកាពិភាក្សា នេះបានពីក្នុងគេហទំព័រ http://www.childsafetourism.org និងគេហទំព័រ http://wvi.org/asiapacific/childsafetourism.

# របៀបប្រើកញ្ចប់ឧបករណ៍វេទិកាពិភាក្សា

កញ្ចប់ឧបករណ៍វេទិកាពិភាក្សា មានបីផ្នែក៖

## ផ្នែកទី១៖ ការចាប់ផ្ដើម

ផ្នែកនេះមានផ្ដល់នូវអ្វីគ្រប់យ៉ាងដែលអ្នកសម្របសម្រួលត្រូវការដឹង និងត្រៀមរៀបចំមុនពេលធ្វើវេទិកាពិភាក្សានេះឡើង។ វាផ្ដល់ជូននូវដំបូន្មានមានប្រយោជន៍អំពីការជ្រើសរើសអ្នកចូលរួម ទីកន្លែង និងការរៀបចំសម្ភារបរិក្ខារ និងការណែនាំពិសេសដើម្បីដោះស្រាយបញ្ហាលើប្រធានបទរសើបពីការរំលោភបំពានផ្លូវភេទកុមារ។

## ផ្នែកទី ២៖ ការណែនាំតាមរយៈស្លាយ

ផ្នែកនេះផ្ដល់ជូននូវការណែនាំជាជំហានៗ ដើម្បីជួយដល់អ្នកសម្របសម្រួលឱ្យផ្ដល់នូវគ្រប់ទិដ្ឋភាពទាំងអស់នៃវេទិកាពិភាក្សា។ ឯកសារជាស្លាយ ផៅវើភ័ញស្ដីពីឪពុកម្ដាយ និងអ្នកថែទាំនេះ អាចទាញយកបានពីគេហទំព័រ http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism ហើយគួរត្រូវបានត្រួតពិនិត្យឡើងវិញ និងកែសម្រួលមុនពេលវេទិកាពិភាក្សា ដើម្បីដាក់បញ្ចូលនូវខ្លឹមសារថ្នាក់ជាតិ និង/ឬ ក្នុងមូលដ្ឋានដែលពាក់ព័ន្ធ។ បើគ្មានឧបករណ៍បញ្ចាំងស្លាយទេ ឬមិនអាចបោះពុម្ពស្លាយដែលនៅលើក្រដាសផ្ទាំងធំនោះបានទេ អ្នកសម្របសម្រួលអាចយក*ផ្នែកការណែនាំតាមរយៈស្លាយ* នេះមកធ្វើជាកំណត់ត្រាសម្រាប់និយាយវិញ។ ការណែនាំតាមរយៈស្លាយ ក៏មានបញ្ចូលសកម្មភាពចូលរួមនានាទៅតាមសំណើដែរ ព្រមទាំងផ្ដល់គន្លឹះផ្សេងៗដល់អ្នកសម្របសម្រួល ដើម្បីជម្រុញការពិភាក្សា និង/ឬគំនិតឆ្លុះបញ្ចាំងរបស់អ្នកចូលរួមទៀតផង។

## ផ្នែកទី៣៖ ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទាំងនេះ មានបន្ថែមឧបករណ៍សម្រាប់ធ្វើវេទិកាពិភាក្សានេះ និងសម្រាប់វាយតម្លៃកម្មវិធី ដើម្បីជាការសិក្សាបន្ថែមទៀត។ ឧបសម្ព័ន្ធទាំងនេះរួមមាន៖

- កាតយកតាមខ្លួន
- ទម្រង់វត្តមានអ្នកចូលរួម
- សំណួរមុនចូលមេរៀននិងក្រោយមេរៀន
- ទម្រង់ស្ដីពីមតិរបស់ខ្ញុំ
- កាតចម្លើយសំរាប់សំណួរមុនចូលមេរៀននិងក្រោយមេរៀន
- គំរូសម្រាប់ការវិភាគសំណួរមុនចូលមេរៀននិងក្រោយមេរៀន
- គំរូរបាយការណ៍ក្រោយវគ្គវេទិកាពិភាក្សា

# ផ្នែកទី១

# ការចាប់ផ្ដើម



# ការចាប់ផ្តើម

## តើនរណាអាចសម្របសម្រួលវេទិកាពិភាក្សានេះបាន ?

ដោយសារតែវេទិកាពិភាក្សានេះ លើកឡើងពីបញ្ហាចាំបាច់នានា នៃការរំលោភបំពានផ្លូវភេទកុមារនោះ អ្វីដែលសំខាន់ណាស់ គឺត្រូវជ្រើសរើសអ្នកសម្របសម្រួលប្រកបដោយយកចិត្តទុកដាក់។ អ្នកសម្របសម្រួលត្រូវមានសមត្ថភាពគ្រប់គ្រាន់  និងមានជំនាញក្នុងការផ្តល់ខ្លឹមសារនៅក្នុងកញ្ចប់ឧបករណ៍នេះ ដល់អ្នកចូលរួម។ គេរំពឹងថាអ្នកសម្របសម្រួលត្រូវមានទាំងចំណេះដឹង និងជំនាញដូចខាងក្រោម៖

- ជាអ្នកជំនាញការដែលមានចំណេះដឹងស្តីពីបញ្ហាការពារកុមារ ដោយមានការយល់ដឹងជាពិសេសពីការរំលោភបំពានផ្លូវភេទកុមារ។
- មានបទពិសោធន៍ចាំបាច់ក្នុងការអប់រំក្នុងសហគមន៍ សម្របសម្រួល បង្រៀន និង/ឬបណ្តុះបណ្តាល
- មានសមត្ថភាពក្នុងការទំនាក់ទំនងបានយ៉ាងច្បាស់លាស់ មានប្រសិទ្ធិភាព ព្រមទាំងអាចសម្រេចបាននូវលទ្ធផលល្អ ក្នុងការរៀនសូត្រ តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម។

អ្នកសម្របសម្រួល មិនត្រឹមតែត្រូវមានអារម្មណ៍ងាយស្រួល ក្នុងការពិភាក្សាពីប្រធានបទ នៃការរំលោភបំពានលើកុមារ ជាពិសេសការរំលោភបំពានផ្លូវភេទប៉ុណ្ណោះទេ ពួកគាត់ថែមទាំងត្រូវតែអាច គ្រប់គ្រងលើស្ថានភាពនិងបញ្ហាលំបាកផ្សេងៗដែលពាក់ព័ន្ធ ដែលអាចកើតឡើងនៅក្នុងវេទិកាពិភាក្សាទាំងនេះទៀតផង។ កត្តានេះរួមមាន បញ្ហាបច្ចេកទេស និងបញ្ហាមិនច្បាស់លាស់នានា ដែលអាចនឹងកើតមានចំពោះអ្នកចូលរួមដែលពួកគេផ្ទាល់ប្រហែលជាធ្លាប់មានបទពិសោធន៍ទទួលរងនូវការរំលោភបំពានរួចទៅហើយនោះ។ ដោយសារតែប្រធានបទ នៃការពិភាក្សានេះ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហារំលោភបំពានផ្លូវភេទ វាផ្តោតទៅលើទំនាក់ទំនងផ្លូវភេទរវាងមនុស្ស ទាំងទំនាក់ទំនងដែលមានការយល់ព្រម និងមិនយល់ព្រម។ ត្រូវតែមានការយកចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់បំផុតដើម្បីធានាថា អ្នកសម្របសម្រួលពិតជាមិនប្រកាន់ឥរិយាបថ ឬគំនិតរើសអើងចំពោះទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រទោះបីជាដោយផ្ទាល់ឬដោយប្រយោលក្តី។ ការប្រកាន់នូវគំនិតរើសអើងដោយផ្អែកលើយេនឌ័រ ទំនោរផ្លូវភេទ ឬពូជសាសន៍ គឺមិនស្របទៅនឹងសិទ្ធិជាសកលរបស់កុមារឡើយ ហើយវាក៏ជាការរួមចំណែកនៅក្នុងការធ្វើឱ្យមានភាពងាយរងគ្រោះនានា ដែលដាក់កុមារឱ្យស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពានទៀតផង។ គោលការណ៍ណែនាំពិសេសពីការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារត្រូវបានបញ្ចូលទៅក្នុងកញ្ចប់ឧបករណ៍វេទិកាពិភាក្សានេះ។

# តើអ្នកណាខ្លះ គួរចូលរួមក្នុងវេទិកាពិភាក្សានេះ ?

វេទិកាពិភាក្សានេះ ត្រូវបានរៀបចំឡើង និងមានលក្ខណៈសមស្របបំផុតសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ ( ឧ. បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ )។ បុគ្គលទាំងនេះរួមមាន៖

- ការចូលរួមរបស់ឪពុក ឬម្តាយ ឬទាំងពីរនាក់តែម្តង។ ក្នុងករណីដែលអាច ទាំងឪពុក និងម្តាយគួរត្រូវបាន លើកទឹកចិត្តឱ្យចូលរួម។
- ចំពោះហេតុផលមួយចំនួន កុមារពេលខ្លះមិនត្រូវបានថែទាំពេញម៉ោង ពីសំណាក់ឪពុកម្តាយបង្កើតរបស់គេនោះទេ។ វេទិកាពិភាក្សានេះក៏ត្រូវបានរៀបចំឡើងសម្រាប់អ្នកថែទាំផងដែរ ។ អ្នកថែទាំ រួមមានសាច់ញាតិបង្កើត ឪពុកម្តាយចិញ្ចឹម ជីដូនជីតា និងមនុស្សពេញវ័យផ្សេងទៀតដែលមានការទទួលខុសត្រូវក្នុងការថែទាំកុមារ ។










## តើលទ្ធផលរំពឹងទុកពីវគ្គសិក្សានេះមានអ្វីខ្លះ ?

នៅចុងបញ្ចប់នៃវេទិកាពិភាក្សា ឪពុកម្តាយ និងអ្នកថែទាំនឹងមានសមត្ថភាពអាច៖

- យល់ពីការរំលោភបំពានកុមារ
- ស្គាល់ពីរបៀបដែលកុមារអាចប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ
- យល់ថា កុមារដែលជាជនរងគ្រោះពីអំពើរំលោភបំពានផ្លូវភេទ មិនត្រូវរងការស្តីបន្ទោសចំពោះការរំលោភបំពាននោះទេ។
- យល់ពីបញ្ហាជាក់លាក់នៃការរំលោភបំពានផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។
- យល់ពីរបៀបដែលអាចរក្សាកុមារឱ្យមានសុវត្ថិភាព រួចផុតពីការរំលោភបំពានផ្លូវភេទ។
- ធ្វើសកម្មភាព និងអាកប្បកិរិយាការពារយ៉ាងសកម្ម ដើម្បីរក្សាកុមារឱ្យមានសុវត្ថិភាព រួចផុតពីការរំលោភបំពានផ្លូវភេទ។
- ដឹងពីអ្វីដែលត្រូវធ្វើ នៅពេលជួបករណីការរំលោភបំពានផ្លូវភេទកុមារ។
- កំណត់បាននូវយន្តការគាំទ្រដ៏មានប្រយោជន៍នៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ ដែលពួកគេអាចស្វែងរកបាន ប្រសិនបើពួកគេត្រូវការការគាំទ្របន្ថែម។

# តើគេត្រូវការអ្វីខ្លះដើម្បីរៀបចំវេទិកាពិភាក្សានេះ ?

## អ្នកចូលរួម

- វេទិកាពិភាក្សានេះ គឺសក្តិសមបំផុតសម្រាប់អ្នកចូលរួមចំនួន២០-២៥នាក់។ ចំនួននេះ
- អនុញ្ញាតិឱ្យមានការពិភាក្សានិងការចែករំលែកបទពិសោធន៍ប្រកបដោយផ្លែផ្កា។
- ប្រសិនបើចំនួនអ្នកចូលរួមឡើងលើសពី៤០នាក់ ការពិភាក្សាជាក្រុម និងព័ត៌មានត្រឡប់វិញ អាចត្រូវចំណាយពេលយូរ ហើយត្រូវការពេលវេលាបន្ថែមទៀត សម្រាប់វេទិកាពិភាក្សានេះ។ ជួនកាល វាជារឿងមួយចាំបាច់ ដែលត្រូវសម្របសម្រួលក្រុមតូចៗ ឬក្រុមធំៗជាងនេះ។ ចំណុចនេះអាចធ្វើបាន ដោយគ្រាន់តែអ្នកសម្របសម្រួល ត្រូវកែសម្រួលរបៀបបំផុសឱ្យមានការចូលរួមរបស់ក្រុម ឱ្យកាន់តែផុសផុល និងមានប្រសិទ្ធិភាព។
- អាស្រ័យដោយធម្មជាតិនៃប្រធានបទមានលក្ខណ:ងាយរសើប ហើយអាចនឹងមានចម្លើយខុសគ្នាពីអ្នកចូលរួមជាស្ត្រី និងជាបុរសនោះ ប្រហែលជាការល្អក្នុងការបែងចែកក្រុមអ្នកចូលរួមទៅតាមភេទ សម្រាប់វេទិកាពិភាក្សានេះ។ ដូចនេះតុល្យភាពយេនឌ័ររវាងម្ដាយនិងឪពុក និងអ្នកថែទាំស្ត្រី/បុរស គួរត្រូវបានលើកទឹកចិត្ត។ ជាញឹកញាប់នៅក្នុងការរៀបចំកម្មវិធីប្រជុំ តែងតែមានផលប៉ះពាល់ច្រើនលើការចូលរួម (ដោយបុរស និងស្ត្រី)។ ជាឧទាហរណ៍ តាមបទពិសោធន៍បង្ហាញថា អាស្រ័យលើការឯកភាពរបស់សហគមន៍ ការប្រជុំ ដែលត្រូវ បានគ្រោងធ្វើសម្រាប់ពេលល្ងាច ឬចុង សប្ដាហ៍នោះ អាចនឹងមានឬគ្មានការជ្រើសរើស អ្នកចូលរួមបន្ថែម។
- ដោយសារតែវេទិកាពិភាក្សានេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកចូលរួមពេញវ័យ អ្នកសម្របសម្រួល គួររៀបចំឱ្យមានអ្នកថែទាំកូនៗរបស់អ្នកចូលរួម នៅជិតកន្លែងដែលរៀបចំវគ្គសិក្សានេះ តាមតែអាចធ្វើបាន។ ព័ត៌មានដែលចែករំលែកក្នុងអំឡុងពេលនៃការពិភាក្សា អាចនឹងមិនមានភាពសមស្របសម្រាប់កុមារឡើយ។
- **ឧបសម្ព័ន្ធទី២** រួមមាន *ទម្រង់ចុះបញ្ជីវត្តមានអ្នកចូលរួម* អាចប្រើប្រាស់សម្រាប់កត់ត្រាទុកនូវព័ត៌មានលម្អិតរបស់អ្នកចូលរួម។

## ទីកន្លែង

- អ្នកសម្របសម្រួល គួរបង្កើតឱ្យមានបរិយាកាសមួយ ដែលអំណោយផលដល់ការសិក្សារៀនសូត្រ មានភាពងាយស្រួល និងមានផាសុកភាពចំពោះអ្នកចូលរួម តាមដែលអាចធ្វើទៅបាន។ គួរចាំថា ទីតាំងគឺជាកន្លែងដែលអ្នកចូលរួមធ្លាប់ស្គាល់ និងជាទីកន្លែងអព្យាក្រឹត្យ។ ឧទាហរណ៍៖ សាលាឆទានដែលនៅក្នុងមូលដ្ឋាន មជ្ឈមណ្ឌលសហគមន៍។ល។ អ្នកសម្របសម្រួល គួរយកចិត្តទុកដាក់បំពេញតាមសេចក្តីត្រូវការជាពិសេសរបស់អ្នកចូលរួមដែលជាជនពិការ។
- ប្រសិនបើអាចធ្វើបាន គួររៀបចំទីកន្លែងក្នុងទម្រង់ជា “រង្វង់” ឬជា “អក្សរអ៊ុយ” តាមភាពងាយស្រួល។ ការរៀបចំបែបនេះ មានលក្ខណ:អំណោយផលដល់ការពិភាក្សាយ៉ាងសកម្ម ដោយ មិនចាំបាច់ត្រូវមានតុ សម្រាប់វេទិកាពិភាក្សានេះទេ។ ក្នុងករណីមួយចំនួន អ្នកចូលរួមទាំងអស់អាចអង្គុយនៅលើឥដ្ឋ ឬផ្ទាល់ដី។
- វេទិកាពិភាក្សានេះមានអាច នៅទីវាល។ បើស្ថិតក្នុងស្ថានភាពបែបនេះ អ្នកសម្របសម្រួលត្រូវជានាឯកជនភាពតាមតែអាចធ្វើបាន។






| | |
|---|---|
| **សម្ភារ** | • អ្នកសម្របសម្រួលគួរដឹងអំពីកម្រិតអក្ខរកម្ម និងសមត្ថភាពខុសៗគ្នារបស់អ្នកចូលរួម និងសម្រួលវិធីសាស្ត្របង្រៀន និងសម្ភារសិក្សាឱ្យត្រូវទៅតាមនោះដែរ។<br>• ការប្រើប្រាស់សម្ភារឧបទេសជំនួយ អាចជួយបង្កើនបទពិសោធន៍សិក្សារបស់អ្នកចូលរួមបានយ៉ាងច្រើន។ អាស្រ័យលើធនធានដែលមាន គេអាចប្រើប្រាស់សម្ភារឧបទេសផ្សេងទៀតជាជំនួយ។<br>• នៅកន្លែងដែលមានភ្លើងអគ្គិសនី និងសម្ភារបរិក្ខារ អ្នកសម្របសម្រួលអាចប្រើប្រាស់ឧបករណ៍ និងផ្ទាំងបញ្ចាំងស្លាយ ដើម្បីធ្វើបទបង្ហាញអំពី ការធ្វើបទបង្ហាញរបស់ *ឪពុកម្តាយ និងអ្នកថែទាំ។* ម្យ៉ាងទៀត វាអាចកាន់តែងាយស្រួល និង/ឬ អាចទុកចិត្តបានកាន់តែល្អ ប្រសិនបើ មានប្រើឯកសារជំនួយដែលបោះពុម្ពចេញ។ ឧទាហរណ៍ដូចជា ឯកសារការធ្វើបទបង្ហាញ*របស់ឪពុកម្តាយ និងអ្នកថែទាំ* គឺអាចបោះពុម្ពចេញបានលើក្រដាសផ្ទាំងធំ ឬអ្នកសម្របសម្រួល អាចសរសេរដោយដៃលើក្រដាសផ្ទាំងធំនូវសារសំខាន់ៗបាន។<br>• អាស្រ័យលើជម្រើសផ្សេងទៀត អ្នកសម្របសម្រួលអាចរៀបចំធ្វើវេទិកាពិភាក្សាបានយ៉ាងងាយស្រួលដោយមិនចាំបាច់ប្រើប្រាស់ សម្ភារឧបទេសជំនួយ។ |
| **ឯកសារចែកជូនអ្នកចូលរួម** | ឯកសារចែកជូន ខាងក្រោមអាចត្រៀមរៀបចំទុកសម្រាប់អ្នកចូលរួមម្នាក់ៗ ៖<br>• កាតយកតាមខ្លួន៖ **ឧបសម្ព័ន្ធទី១**។<br>• កាតចម្លើយសម្រាប់សំណួរមុនចូលមេរៀននិងក្រោយមេរៀន៖ **ឧបសម្ព័ន្ធទី៥** ឬប្រសិនបើអ្នកសម្របសម្រួល ចង់រៀបចំសំណួរមុនចូលមេរៀននិងក្រោយមេរៀនជាលាយលក្ខណ៍អក្សរ គួរថតចម្លង**ឧបសម្ព័ន្ធទី៣ និង ទី៤** សម្រាប់អ្នកចូលរួមម្នាក់ៗ។<br>• ប្រសិនបើអ្នកសម្របសម្រួលចង់ប្រមូលព័ត៌មានត្រឡប់ជាលាយលក្ខណ៍អក្សរ អាចថតចម្លង **ឧបសម្ព័ន្ធទី៧** សម្រាប់អ្នកចូលរួមម្នាក់ៗ។ ទោះជាយ៉ាងណា វាជាការល្អដែលអ្នកសម្របសម្រួល ប្រមូលព័ត៌មានដោយផ្លាស់ប្តូរយោបល់ជាពាក្យសម្តី។<br>ឯកសារចែកជូន និង/ឬ សកម្មភាពទាំងនេះ គួរត្រូវបានកែសម្រួល តាមការចាំបាច់ដើម្បីជួយដល់អ្នកចូលរួម ដែលមានសមត្ថភាពផ្សេងៗគ្នាក្នុងការចូលរួម។ |
| **ឯកសារផ្សេងទៀត** | • ក្រដាសផ្ទាំងធំ ឬក្តារខៀន<br>• ហ្វឺត ឬ ដីស និងប្រដាប់លុបក្តារខៀន<br>• កូនបាល់ទន់ *(តាមជម្រើស)* |

# តើគេត្រូវការពេលប៉ុន្មាន ដើម្បីដំណើរការវេទិកានេះ ?

វេទិកាពិភាក្សាត្រូវបានរៀបចំឡើងសម្រាប់រយៈពេលពីរម៉ោង។ ទោះជាយ៉ាងណា ប្រសិនចាំបាច់ គេអាចផ្តល់ការ បណ្តុះបណ្តាលនោះរយៈពេលវែងជាងនេះ ដោយអាស្រ័យទៅលើការអនុវត្ត និងវិធានការបែបចូលរួមដែលត្រូវបានជ្រើសរើស។

តារាងខាងក្រោមនេះ បង្ហាញពីផែនការពេលវេលាសម្រាប់ប្រធានបទ និងសកម្មភាពនីមួយៗ ហើយវាបង្ហាញ សកម្មភាពគោលនានា ដែលអាចជ្រើសរើសបាន ក្នុងករណីផែនការពេលវេលានោះមានកំណត់។ នៅក្នុង គោលការណ៍ណែនាំជាបទបង្ហាញ (ផ្នែកទីពីរ) គេសម្គាល់ស្លាយសំខាន់ៗ ដោយសញ្ញា ●។

| មេរៀន | ខ្លឹមសារ | សំខាន់ | តាមជម្រើស | ម៉ោង |
|---|---|---|---|---|
| **សេចក្តីផ្តើម** | ការណែនាំពីអ្នកសម្របសម្រួល | ● | | ៥ នាទី |
| | ការណែនាំពីអ្នកចូលរួម | | ● | រហូតដល់ ១៥ នាទី |
| | ហេតុអ្វីបានជាយើងនៅទីនេះ ? | ● | | ៥ នាទី |
| | សកម្មភាព៖ ការបំផុសក្រុមពិភាក្សាពីអ្វីដែលឪពុកម្តាយ/ អ្នកថែទាំធ្វើ | | ● | រហូតដល់ ១០ នាទ |
| | សកម្មភាព៖ សំណួរពេលចាប់ផ្តើម | ● | | ១០ នាទី |
| **តើអ្វីជាការរំលោភបំពានផ្លូវភេទកុមារ ?** | តើអ្វីជាការរំលោភបំពានកុមារ ?<br>តើអ្វីជាការរំលោភបំពានផ្លូវភេទកុមារ ? | ● | | ២០ នាទី |
| **តើយើងអាចធ្វើ ឱ្យប្រសើរដល់ការការពារកុមារយ៉ាងដូចម្តេច ?** | ១. តើព័ត៌មានអ្វីខ្លះដែលយើងត្រូវការដឹង ? | | | |
| | តើនរណាខ្លះជាជនរងគ្រោះ ? | ● | | ៥ នាទី |
| | តើនរណាខ្លះជាអ្នករំលោភបំពាន ?<br>តើគេធ្វើសកម្មភាពយ៉ាងដូចម្តេច ? | ● | | ២០ នាទី |
| | តើផលប៉ះពាល់ ពីការរំលោភបំពានផ្លូវភេទលើកុមារមានអ្វីខ្លះ ? | ● | | ៥ នាទី |
| | តើអ្វីខ្លះជាទំនាក់ទំនងរវាងបច្ចេកវិជ្ជាឌីជីថល និងការរំលោភបំពានលើកុមារ ? | | ● | ១៥ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ គ្រោះថ្នាក់ចំពោះសុវត្ថិភាពកុមារបណ្តាលមកពីបច្ចេកវិជ្ជាឌីជីថល។ | | ● | ៥ នាទី |
| | តើអ្វីខ្លះជាទំនាក់ទំនងរវាងវិស័យទេសចរណ៍ និងការរំលោភបំពានលើកុមារ ? | ● | | ៥ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ គ្រោះថ្នាក់ចំពោះសុវត្ថិភាពកុមារដោយការរីកចម្រើនក្នុងវិស័យទេសចរណ៍ | | ● | ៥ នាទី |

| មេរៀន | ខ្លឹមសារ | សំខាន់ | តាមជម្រើស | ម៉ោង |
|---|---|---|---|---|
| | ២. តើយើងអាចនិយាយជាមួយកុមារអំពីការរក្សាសុវត្ថិភាពសម្រាប់គេយ៉ាងដូចម្តេច? | | | |
| | ? សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ តើអាកប្បកិរិយាការពារខ្លួនអ្វីខ្លះដែល អ្នក លើកទឹកចិត្ត? | • | | ១០ នាទី |
| | បង្កើតទំនាក់ទំនងបើកចំហ និងទំនាក់ទំនងដែលអាចជឿទុកចិត្តបាន | • | | ៥ នាទី |
| | និយាយជាមួយកុមារអំពីបញ្ហាភេទ និងផ្លូវភេទ | • | | ១០ នាទី |
| | ការបង្រៀនពីយុទ្ធសាស្រ្តការពារ | • | | ១៥ នាទី |
| | ៣. តើសញ្ញាអ្វីខ្លះដែលចង្អុលបង្ហាញថាកុមារអាចកំពុងស្ថិតក្នុងគ្រោះថ្នាក់? | • | | ៥ នាទី |
| | ៤. តើត្រូវទៅកន្លែងណាដើម្បីរកជំនួយ? | | | |
| | ធនធានក្នុងសហគមន៍ | • | | ៥ នាទី |
| | សកម្មភាព៖ ធ្វើផែនទីធនធានសហគមន៍របស់យើង | | • | រហូតដល់ ១៥ នាទី |
| | សកម្មភាព៖ ធ្វើផែនការសកម្មភាព | | • | រហូតដល់ ១៥ នាទី |
| សេចក្តីសន្និដ្ឋាន | សកម្មភាព៖ ការវាយតម្លៃ | • | | ៥ នាទី |
| | សកម្មភាព៖ សំណួរក្រោយមេរៀន | • | | ១០ នាទី |
| | បិទកម្មវិធី | • | | ៥ នាទី |

# គោលការណ៍ណែនាំពិសេស សម្រាប់ការបណ្តុះបណ្តាលពីការការពារកុមារ

## ត្រូវយកចិត្តទុកដាក់សម្របសម្រួលការពិភាក្សានេះឲ្យបានល្អ

ការរំលោភបំពានលើកុមារ គឺជាបញ្ហារសើប ដែលនឹងត្រូវការការត្រិះរិះ និងការពិចារណា ជាពិសេសពីអ្នកចូលរួម។ សិក្ខាកាមគួរត្រូវបានផ្តល់ឱកាសក្នុងការលើកឡើងពីប្រធានបទដែលមិនមានការប្រឈមមុខដាក់គ្នា ដូចដែលមានកំណត់នៅក្នុង គោលការណ៍ណែនាំតាមរយៈស្លាយ មុនពេលចាប់ផ្តើមការពិភាក្សាអំពីការរំលោភបំពានលើកុមារ។ តាមរយៈការផ្តល់ឱ្យអ្នកចូលរួមនូវឱកាសបញ្ចេញ "មតិយោបល់" ក្នុងអំឡុងពេលនៃសកម្មភាពណែនាំ ពួកគាត់នឹងមានអារម្មណ៍កាន់តែងាយស្រួល ក្នុងការនិយាយអំពីបញ្ហារំលោភបំពានលើកុមារ ក្នុងអំឡុងពេលនៃដំណើររបស់វេទិកាពិភាក្សា។

## ត្រូវរៀបចំជាស្រេចនូវព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង ដើម្បីផ្តល់សេវាពិគ្រោះយោបល់ប្រកបដោយវិជ្ជាជីវៈ ឬសេវាបញ្ជូន

ត្រូវដឹងថា អ្នកចូលរួមមួយចំនួន អាចជាជនរងគ្រោះនៃការរំលោភបំពាន ឧទាហរណ៍ អ្នកខ្លះប្រហែលជាគិតអំពីបញ្ហានេះពីមុន ឬជាយូរយារណាស់មកហើយ ហើយការពិភាក្សានេះ អាចនឹងនាំមកនូវការចងចាំដែលឈឺចាប់[1]។ វាជាការសំខាន់ ដែលត្រូវមានការឆ្លើយតបខ្ពស់ចំពោះលទ្ធភាពអាចកើតមាននេះគ្រប់ពេលវេលា។ ប្រសិនបើអ្នកចូលរួមចង់និយាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ សូមអញ្ជើញឱ្យគាត់ទៅនិយាយ នៅក្នុងកន្លែងឯកជនមួយ (ក្នុងអំឡុងពេលសម្រាក ឬនៅពេលធ្វើការសន្និដ្ឋាននៃការពិភាក្សា)។ អ្នកសម្របសម្រួលគួររៀបចំត្រៀមទុកនូវព័ត៌មានសម្រាប់ទំនាក់ទំនងសម្រាប់ការប្រឹក្សាយោបល់បែបជំនាញ វិជ្ជាជីវៈ និងសេវាបញ្ជូនបន្តផ្សេងទៀត សម្រាប់អ្នកចូលរួមណាដែលមានបំណងចង់ពិភាក្សាពីស្ថានភាពរបស់ខ្លួនជា លម្អិត។

## ត្រូវរាយការណ៍ជាបន្ទាន់ នូវការប្រាប់ការពិតអំពីកុមារម្នាក់ ដែលអាចឆ្លងកាត់បទពិសោធន៍នៃការរំលោភបំពាន

អ្នកចូលរួមខ្លះ ប្រហែលជាអាចនឹងចែករំលែកព័ត៌មានដែលបង្ហាញថា ក្នុងពេលនេះកុមារម្នាក់ អាចកំពុងជួបប្រទះការរំលោភបំពាននៅក្នុងគ្រួសាររបស់គេ សមាគមន៍ ឬនៅកន្លែងផ្សេងទៀត។ នៅពេលមានការលាតត្រដាងពីស្ថានភាពបែបនេះ អ្នកត្រូវតែយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ ដោយរក្សាការសម្ងាត់ និងចាត់វិធានការឲ្យបានទាន់ពេលវេលា ពីព្រោះកុមារម្នាក់កំពុងស្ថិតក្នុងគ្រោះថ្នាក់។ បើមានហេតុការណ៍ បែបនេះកើតឡើង ត្រូវជម្រាបដល់ទីភ្នាក់ងារមូលដ្ឋានដែលសមគួរ (រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានផង)។ អ្នកសម្របសម្រួល ត្រូវស្គាល់ភ្នាក់ងារបញ្ជូននៅក្នុងមូលដ្ឋានដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតពីហេតុការណ៍ដែលបានបង្ហាញ ទាំងនេះ។ **រាល់ហេតុការណ៍ដែលបានបង្ហាញត្រូវរាយការជាបន្ទាន់។**

## ត្រូវចេះឆ្លើយតបនឹងសំណួរដែលពិបាក និង/ឬឥរិយាបថរំខាននានា

វាជាការចាំបាច់ក្នុងការគិតគូរ និងគោរពចំពោះសាវតារវប្បធម៌របស់អ្នកចូលរួម។ ប៉ុន្តែ  វប្បធម៌មិនត្រូវទទួលយកក្នុងលក្ខណៈជាលេសសម្រាប់ការកែតម្រូវការរំលោភបំពានកុមារនោះទេ។

អាចនឹងមានការលើកឡើងនូវសំណួរអំពីការផ្តោតលើផ្លូវភេទ និងអត្តសញ្ញាណភេទ។ អ្នកសម្របសម្រួលគួរត្រៀមខ្លួន ដើម្បីឆ្លើយតបទៅនឹងការពិភាក្សាបែបនេះក្នុងលក្ខណៈច្បាស់លាស់ និងត្រង់ៗ។

---

[1] វាជារឿងសាមញ្ញសម្រាប់អ្នកដែលធ្លាប់រងគ្រោះដោយសារការរំលោភបំពាន ក្នុងការបំបាត់ចោលនូវការចងចាំនូវបទពិសោធន៍ទាំងនេះក្នុងលក្ខណៈជាយន្តការដោះស្រាយបញ្ហា។

អ្នកសម្របសម្រួលគួរសង្កត់ធ្ងន់ថា កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារ ដោយមិនគិតពីទំនោរផ្លូវភេទ និង/ឬ អត្តសញ្ញាណយេនឌ័រនោះទេ ហើយស្លាកស្នាមឈឺចាប់ ការរើសអើង ឬការមិនខ្វាយខ្វល់ពីបញ្ហានៃទំនោរផ្លូវភេទ និងអត្តសញ្ញាណភេទនេះ អាចនឹងរុញច្រានកុមារឱ្យធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ ប្រសិនបើពួកគេមិនទទួលបានការគាំទ្រនៅក្នុងសហគមន៍របស់គេ។

អ្នកសម្របសម្រួលត្រូវធានាថា រាល់ការលើកឡើងទាំងឡាយរបស់អ្នកចូលរួមដែលផ្សារភ្ជាប់នឹងជំនឿមិនពិត ឬមិនមានអំណោយផលល្អ សម្រាប់បង្កើតបរិស្ថានដែលមានសុវត្ថិភាពដល់កុមារ ត្រូវបានដោះស្រាយភ្លាមៗ និងមិនត្រូវបានព្រងើយកន្តើយឡើយនៅក្នុងដំណាក់កាលដំបូង។ ឧទាហរណ៍ដូចជា មតិយោបល់អំពីការស្លៀកពាក់របស់កុមារី គឺមិនទាក់ទងនឹងការពិភាក្សាទេ ហើយអាចភ្ជាប់គំនិតទៅនឹងឥរិយាបទរើសអើងផ្អែកលើភេទដែល "ស្តីបន្ទោសដល់ជនរងគ្រោះ" ។ អ្នកសម្របសម្រួល មិនត្រូវលើកទឹកចិត្តចំពោះការពិភាក្សាប្រភេទនេះទេ តែផ្ទុយទៅវិញ គួរផ្តោតការយកចិត្តទុកដាក់លើសារសំខាន់ៗ ដែលមានលើកឡើងនៅក្នុងកញ្ចប់ឧបករណ៍អំពីវេទិកាពិភាក្សា។

ពេលខ្លះ អ្នកសម្របសម្រួលអាចនឹងជួបប្រទះជាមួយនឹងអ្នកចូលរួមណាម្នាក់ ដែលបង្ហាញអាកប្បកិរិយាមិនលំបាក (បែបបង្ករឿង និយាយមិនឈប់ ឥរិយាបថអវិជ្ជមាន រំខានច្រើន ឬអ្នកដែលជឿថាខ្លួនដឹងរឿងគ្រប់យ៉ាង)។ ដើម្បីដោះស្រាយបញ្ហា ត្រូវដាក់អ្នកចូលរួមឱ្យចូលរួមក្នុងការកំណត់រកដំណោះស្រាយបញ្ហាដែលពួកគាត់បានលើកឡើង។ អ្នកសម្របសម្រួលត្រូវចៀសវាងការមិនអើពើដល់អ្នកចូលរួមផ្សេងទៀតដោយសារតែឥរិយាបថរបស់អ្នកចូលរួមម្នាក់។

នៅគ្រប់ពេល ជាការសំខាន់គឺត្រូវរំឭកដល់អ្នកចូលរួមថា កុមារមិនគួរត្រូវបានស្តីបន្ទោសដោយសារតែគេត្រូវបានក្លាយជាជនរងគ្រោះពីការរំលោភបំពានផ្លូវភេទនោះឡើយ។



# កត់ចំណាំ

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

# ផ្នែកទី២
# ការណែនាំតាមរយៈស្លាយ



# ការណែនាំតាមរយៈស្លាយ

ផ្នែកនេះ ផ្តល់នូវការណែនាំជាជំហានៗ ដើម្បីជួយដល់អ្នកសម្របសម្រួលក្នុងការផ្តល់នូវគ្រប់ទិដ្ឋភាពនៃវេទិកាពិភាក្សានេះ។ ឯកសារបទបង្ហាញរបស់ឪពុកម្តាយ និងអ្នកថែទាំអាចទាញយកបានពីគេហទំព័ http://www.childsafetourism.org និង
http://wvi.org/asiapacific/childsafetourism និងគួរត្រូវបានពិនិត្យឡើងវិញ និងកែសម្រួលដើម្បីដាក់បញ្ចូលខ្លឹមសារថ្នាក់ជាតិ និង/ឬ មូលដ្ឋានដែលពាក់ព័ន្ធ។ បទបង្ហាញស្លាយនេះ គឺជាឧបករណ៍មួយសម្រាប់គាំទ្រដល់ គោលបំណងនៃការសិក្សា និងលើកកម្ពស់ការប្រកាន់ខ្ជាប់របស់អ្នកចូលរួមនូវសារសំខាន់ៗក្នុងអំឡុងពេលនៃវេទិកាពិភាក្សានេះ។ ប្រសិនបើមិនអាចមានលទ្ធភាពប្រើប្រាស់ស្លាយទាំងនេះក្នុងលក្ខណៈសម្ភារជំនួយបន្ថែមទេនោះ (ដូចជាបង្ហាញនូវឧបករណ៍បញ្ចាំងស្លាយ ឬបោះពុម្ពចេញលើក្រដាសផ្ទាំងធំ) អ្នកសម្របសម្រួលអាចប្រើប្រាស់ សេចក្តីណែនាំជាស្លាយ ដើម្បីធ្វើជាកំណត់ត្រាសម្រាប់បទបង្ហាញរបស់ខ្លួនបាន។

អ្នកសម្របសម្រួលគួរខិតខំប្រឹងប្រែងបង្កើតបរិយាកាសសិក្សាប្រកបដោយថាមពល ដោយរៀបរាប់លម្អិតនៅតាមស្លាយនីមួយៗ និងបញ្ចូលសកម្មភាពនានានៅក្នុងអំឡុងចន្លោះពេលបង្ហាញ តាមការគួរ។ កាតយកតាមខ្លួន (ឧបសម្ព័ន្ធទី១) គួរផ្តល់ជូនដល់អ្នកចូលរួមនៅពេលចាប់ផ្តើមនៃការពិភាក្សា និងប្រើជាឯកសារយោងក្នុងអំឡុងពេលនៃការពិភាក្សា។ អ្នកសម្របសម្រួលគួរលើកទឹកចិត្តដល់អ្នកចូលរួមឱ្យប្រើប្រាស់ កាតយកតាមខ្លួនជាឯកសារ យោងដែលងាយស្រួលប្រើ។ អ្នកចូលរួមអាចប្រើ កាតយកតាមខ្លួន ដើម្បីចែករំលែកព័ត៌មានជាមួយនឹងគ្រួសារ និងសហគមន៍របស់គេបាន បន្ទាប់ពីវេទិកាពិភាក្សានេះ។ ប្រសិនបើប្រើ សំណួរមុនចូលមេរៀន អ្នកសម្របសម្រួល អាចជ្រើសរើសចែកជូននូវសំណួរមុនចូលមេរៀន(ឧបសម្ព័ន្ធទី៣) ក្នុងពេលតែមួយជាមួយនឹងកាតយកតាមខ្លួន និងសុំឱ្យអ្នកចូលរួមបំពេញសំណួរខ្លីនេះនៅពេលដែលមានសកម្មភាពពាក់ព័ន្ធក្នុងអំឡុងពេលនៃការពិភាក្សា។

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **សេចក្តីផ្តើម** | | |
| **ស្លាយទី១** ●  | | • ស្លាយផ្តើម៖ អាចបញ្ចាំងបង្ហាញនៅពេលអ្នកចូលរួមកំពុងដើរចូលមកក្នុងវេទិកាពិភាក្សា<br>• សូមធ្វើឱ្យស្លាយនេះ មានលក្ខណៈសមស្របនឹងមូលដ្ឋាន តាម រយៈការដាក់បន្ថែមឈ្មោះសហ-អ្នកសម្របសម្រួល ដែលអញ្ជើញមកពីអង្គការដៃគូ ហើយបើសមស្រប អាចដាក់បញ្ចូលស្លាកសញ្ញារបស់អង្គការដៃគូ។ |
| **ស្លាយទី២** ●  | • អរុណសួស្តី /ទិវាសួស្តី/សាយ័ណ្ហសួស្តី។<br>• សូមអរគុណអ្នកទាំងអស់គ្នាដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមក្នុងវេទិកាពិភាក្សានេះ។<br>• រំឭកដល់អ្នកចូលរួមថា តាមរយៈការចូលរួមរបស់ពួកគាត់ នៅក្នុងវេទិកាពិភាក្សានេះ គឺពួកគាត់ធ្វើសកម្មភាព ដើម្បីផលប្រយោជន៍កូនៗជាទីស្រឡាញ់របស់គាត់។<br>• អ្នកសម្របសម្រួលចាប់ផ្តើមលើកឡើង ដោយសង្ខេបនិងណែនាំខ្លួនបែបស្និទ្ធស្នាល និងណែនាំពីអ្នកផ្សេងទៀត ដែលកំពុងគាំទ្រដល់វេទិកាពិភាក្សានេះ។ | • ដោយសារមានពេលវេលាតិចសម្រាប់វេទិកាជជែកពិភាក្សាសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ សូមធ្វើវគ្គសេចក្តីផ្តើមនេះដោយខ្លី។<br>• គោលបំណងនៃវគ្គសេចក្តីផ្តើមនេះ គឺកំណត់ឱ្យច្បាស់ថា ការចូលរួមរបស់ពួកគាត់ គឺជាអ្វីដែលពួកគាត់ធ្វើដើម្បីកូនៗរបស់គាត់។<br>• ផ្នែកនេះក៏ជួយអ្នកចូលរួមឱ្យមានអារម្មណ៍ថាមានភាពងាយស្រួលជាមួយនឹងប្រធានបទ និងផ្តល់ឱកាសឱ្យពួកគេនិយាយពីបញ្ហាស្រាលៗនៅមុខអ្នកចូលរួមដទៃទៀត មុនពេលពួកគេពិភាក្សាពីប្រធានបទសើបនៃការរំលោភបំពានផ្លូវភេទ។<br>• សកម្មភាពចំនួនពីរ ( តាមជម្រើស នៅក្នុងការណែនាំ *(ការណែនាំពីអ្នកចូលរួម និងការបំផុសគំនិតក្នុងក្រុម )* គួរតែត្រូវបានអនុវត្តយ៉ាងលឿននិងមិនចាំបាច់បរិយាយវែងទេ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣** •<br> | • ពន្យល់ថា ឯកសារអប់រំនេះត្រូវបានបង្កើតឡើងដោយអង្គការទស្សនៈពិភពលោក សម្រាប់គម្រោងកុមារភាព ផ្នែកបង្ការ ជាគំនិត ផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារពីការរំលោភបំពានផ្លូវភេទ ក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ | • ប្រសិនបើពាក់ព័ន្ធ អ្នកសម្របសម្រួលគួរណែនាំដោយសង្ខេបពីរបៀបដែលសហគមន៍ផ្សារភ្ជាប់ជាមួយនឹងវិស័យទេសចរណ៍ (ឧទាហរណ៍៖ កន្លែងគោលដៅទេសចរណ៍ដែលមានការរៀបចំបានល្អ កន្លែងគោលដៅ ទេសចរណ៍ដែលមានការរីកចម្រើន ការធ្វើចំណាកស្រុកពីសហគមន៍ទៅកាន់តំបន់គោលដៅទេសចរណ៍ ជាដើម)។ លក្ខណៈនេះបានផ្តល់នូវសារតានិងបរិបទសម្រាប់វេទិកាពិភាក្សា<br>• នៅពេលដែលអាច អ្នកសម្របសម្រួលគួរតែធ្វើឲ្យប្រាកដថា ការរំលោភបំពានផ្លូវភេទកុមារ ក៏កើតឡើង ក្នុងសហគមន៍ដែលពុំមែនជាទីគោលដៅទេសចរណ៍ដែរ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤**<br> | *សកម្មភាព៖ ការណែនាំអ្នកចូលរួម (ជាជម្រើស៖ ប្រសិនបើអ្នកចូលរួមមិនទាន់ស្គាល់គ្នា)*<br>• ពួកយើងដឹងថា លោក លោកស្រីភាគច្រើនគឺជាឪពុកម្តាយ ឬអ្នកថែរក្សាកុមារ និងមនុស្សវ័យក្មេង *(អាយុក្រោម១៨ឆ្នាំ)*។<br>• លោក លោកស្រីមួយចំនួនស្គាល់គ្នារួចហើយ ប៉ុន្តែប្រហែលជានៅមានមនុស្សមួយចំនួនដែលលោក លោកស្រីមិនទាន់បានស្គាល់នៅឡើយ។<br>• ដើម្បីឱ្យយើងអាចស្គាល់គ្នាបាន ខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាណែនាំខ្លួនតាម<br>• រយៈការឆ្លើយសំណួរពីរសំណួរ៖<br>– តើអ្នកឈ្មោះអ្វី?<br>– តើមានកុមារនិងមនុស្សវ័យក្មេងប៉ុន្មាននាក់ដែលអ្នកកំពុងមើលថែទាំ?<br>• អ្នកសម្របសម្រួល អាចចាប់ផ្តើមដោយការណែនាំខ្លួនឯង។ ឧទាហរណ៍ ខ្ញុំឈ្មោះ [និយាយឈ្មោះ] ហើយខ្ញុំមាន [និយាយចំនួនកូន] នាក់។<br>• នៅចុងបញ្ចប់នៃការណែនាំខ្លួន អ្នកសម្របសម្រួលអាច៖<br>– លើកសរសើរអំពីចំនួនឆ្នាំ នៃបទពិសោធន៍ ក្នុងការចិញ្ចឹមបីបាច់រក្សាកុមារ ដែលមាននៅក្នុងបន្ទប់។<br>– ទទួលស្គាល់ចំនួនកុមារសរុប ដែលមនុស្សនៅក្នុងបន្ទប់ត្រូវថែទាំ។<br>– ពន្យល់ប្រាប់អ្នកចូលរួមថា វេទិកាពិភាក្សានេះ ត្រូវបានរៀបចំឡើងយ៉ាងពិសេស ដើម្បីជួយពួកគាត់ ក្នុងការការពារ កុមារឱ្យមានសុវត្ថិភាពរួចផុតពីការ រំលោភបំពានផ្លូវភេទ។<br>– លើកសរសើរអ្នកទាំងអស់គ្នាថា នៅពេលពួកគាត់បានចូលរួមនៅក្នុងវគ្គនេះ ពួកគាត់បានឈានជំហានទៅមុខ ដើម្បីការពារកូនៗរបស់ខ្លួនប្រឆាំងនឹងការរំលោភបំពាន។<br>– សូមលើកទឹកចិត្តអ្នកចូលរួម ឱ្យចែករំលែកបទពិសោធន៍របស់ខ្លួន ក្នុងអំឡុងពេលវេទិកាពិភាក្សា។ | • ដើម្បីធ្វើឲ្យវគ្គនេះ កាន់តែមានភាពរស់រវើក និងមានការចូលរួម សូមចាប់ផ្តើមការណែនាំខ្លួន ដោយការបោះបាល់កៅស៊ូទៅឲ្យអ្នកចូលរួមណាម្នាក់។<br>បន្ទាប់ពីគាត់បានណែនាំ ខ្លួនឯងរួចហើយ គាត់អាចជ្រើសរើសអ្នកចូលរួម ម្នាក់ទៀតតាមរយៈការបោះបាល់ទៅអ្នកនោះ។ សូមលើកទឹកចិត្តអ្នកចូលរួមឲ្យបោះបាល់ទៅនរណាដែលពួកគាត់មិនធ្លាប់បានជួបពីមុនមក។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៥** ●<br><br> | *ហេតុអ្វីបានជាអ្នកត្រូវអញ្ជើញមកទីនេះ ?*<br>• ថ្ងៃនេះយើងនឹងពិភាក្សាគ្នាត្រួសៗពីថា តើយើងអាចរក្សាកុមារឲ្យមានសុវត្ថិភាព រួចផុត ពីការរំលោភបំពានផ្លូវភេទដោយវិធីណា។<br>• ក្នុងនាមជាមនុស្សពេញវ័យ យើងដឹងថា ប្រហែលជាមានការលំបាកក្នុងការនិយាយពីបញ្ហាភេទ។ នេះប្រហែលជាលើកទីមួយហើយ ដែលលោក លោកស្រី ពិភាក្សាអំពីបញ្ហាទាំងនេះ។<br>• ប៉ុន្តែ ដើម្បីឱ្យកុមាររបស់យើងមានសុវត្ថិភាព វាជាការសំខាន់ណាស់ដែលយើង ត្រូវទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីប្រធានបទនេះ។ នេះមានន័យថា យើងមិនអាចនៅស្ងៀមស្ងាត់អំពីបញ្ហារំលោភបំពានផ្លូវភេទលើកុមារឡើយ។<br>*សំណូមពរ*<br>• ការចូលរួមចំណែករបស់អ្នកគ្រប់គ្នាអំពីប្រធានបទនេះ គឺមានតម្លៃខ្លាំងណាស់ ។<br>• ប្រសិនបើអ្នកមិនយល់អ្វីម្យ៉ាង សូមលើកឡើង។ អ្នកដទៃក៏ទំនងជាមិនយល់ដែរ។ ប្រសិនបើអ្នកមានសំណួរអំពី ប្រធានបទនេះសូមសួរ (ឬបើចង់ឱ្យងាយស្រួលជាងនេះទៀត អ្នកអាចជួប ខ្ញុំនៅចុងម៉ោងបាន)។<br>• ប្រសិនបើអ្នកបានដឹងអំពីស្ថានភាពដែលកុមារណាម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ សូមប្រាប់ឱ្យខ្ញុំដឹង នៅចុងម៉ោងនេះ ដើម្បី ឱ្យយើងអាចធ្វើសកម្មភាពការពារពួកគេបាន។ | សូមមើល កាតយកតាមខ្លួន (**ការការពារកុមារ គឺជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប**)<br><br> |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦**<br> | *សកម្មភាព៖ ការបំផុសគំនិតក្រុម (តាមជម្រើស)*<br>• ទទួលស្គាល់ថា ការចិញ្ចឹមកុមារ គឺជាការងារពេញម៉ោង។<br>• សូមឱ្យអ្នកចូលរួមលើកឡើងពីការងារទាំងអស់ដែលពួកគាត់ត្រូវធ្វើសម្រាប់កុមារជារៀងរាល់ថ្ងៃ។<br>• អ្នកសម្របសម្រួល ឬអ្នកស្ម័គ្រចិត្តណាម្នាក់នៅក្នុងក្រុម អាចសរសេរចំណុចទាំងនេះនៅលើក្រដាសផ្ទាំងធំ។ | • បានលើកទឹកចិត្តឱ្យពិភាក្សាអ្វីគ្រប់យ៉ាងដែលពួកគាត់ធ្វើសម្រាប់កូនៗរបស់គាត់។ សកម្មភាពនេះផ្តល់ឱ្យអ្នកចូលរួមឱកាសបញ្ចេញ "មតិយោបល់" ក្នុងបរិបទមួយដែលមិនមានការប្រឈមមុខដាក់គ្នាក្នុងអំឡុងពេលដំណាក់ដំបូងនៃវេទិកា។ ការធ្វើបែបនេះជួយដល់អ្នកចូលរួមឱ្យមានអារម្មណ៍ងាយស្រួលនៅពេលដែលនិយាយអំពីបញ្ហាផ្លូវភេទកាន់តែស៊ីជម្រៅក្នុងអំឡុងពេលនៃដំណើរការការពិភាក្សា ។ |
| | • ទទួលស្គាល់ថា អ្នកចូលរួមមានការងាររវល់ខ្លាំងណាស់ និងការទទួលខុសត្រូវដែលពេញលេញជាឪពុកម្តាយ និងអ្នកថែទាំ ដើម្បីការពារកុមារពីគ្រោះថ្នាក់គ្រប់ប្រភេទទាំងអស់។<br>• ពន្យល់ថា ក្នុងខណៈពេលដែលពួកយើងយល់ពីរបៀបការពារកុមារ ពីទម្រង់មួយចំនួននៃគ្រោះថ្នាក់ (ដូចរបៀបឆ្លងកាត់ផ្លូវដែលសុវត្ថិភាព របៀបនៃការប្រព្រឹត្តពេលនៅក្បែរភ្លើង) ពួកយើងដឹងឪពុកម្តាយនិងអ្នកថែទាំជាច្រើនមិនច្បាស់ពីរបៀបរក្សាកូនរបស់ពួកគេឱ្យមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទទេ។<br>• វេទិកាពិភាក្សានៅថ្ងៃនេះ ត្រូវបង្កើតឡើងដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវព័ត៌មានពីរបៀបដែលពួកគេអាចរក្សាកូនរបស់អ្នកឱ្យមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ។ | • ការឆ្លើយតបគួររួមមាន៖ សម្អាតភាពគ្មានសណ្តាប់ធ្នាប់របស់ពួកគេ បញ្ជូនពួកគេទៅសាលារៀន បង្រៀនពួកគេពីការងារផ្ទះ ផ្តល់អាហារ សម្លៀកបំពាក់ដល់ពួកគេ រក្សាសុវត្ថិភាពដល់ពួកគេជាដើម។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៧** ●<br> | **សកម្មភាព៖ សំណួរពេលចាប់ផ្តើម**<br>• អ្នកចូលរួមមួយចំនួន បានដឹងរួមមក ហើយអំពីការរំលោភបំពានផ្លូវភេទ។ ប៉ុន្តែប្រធានបទនេះ អាចជាប្រធានបទថ្មី សម្រាប់អ្នកមួយចំនួនទៀត។ ដើម្បីឱ្យកាន់តែច្បាស់ពួកយើងបានផ្តល់ព័ត៌មាន ដែលសមស្រប និងពាក់ពន្ធ័អ្នកបំផុត ពួកយើងនឹងសួរ **សំណួរពេលចាប់ផ្តើម។**<br>• អ្នកសម្របសម្រួលអាចជ្រើសរើស សកម្មភាពមួយក្នុងចំណោមសកម្មភាពសាមញ្ញៗ ដែលមានលក្ខណៈរស់រវើក ដូចមានរៀបរាប់នៅក្នុង **តារាងកំណត់សម្គាល់** ( **ខាងស្តាំដៃ** ) ដើម្បីសាកល្បងចំណេះដឹងរបស់អ្នកចូលរួម។ សកម្មភាពនេះត្រូវបានរកឃើញថា មានភាពសមស្រប ច្រើនសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ ហើយអាចចំណេញពេលវេលាច្រើន ជាងការធ្វើសកម្មភាពដោយសរសេរ។ ប្រសិនបើចង់ធ្វើសកម្មភាពសរសេរ គឺអាច ប្រើប្រាស់ និងចែកចាយ **សំណួរមុន ចូលមេរៀន** ( **ឧបសម្ព័ន្ធទី៣** ) បាន។ | ពេលវេទិកាពិភាក្សា។ មានការផ្តល់អនុសាសន៍ច្រើនថា*សំណួរពេលចូល* គួរត្រូវបានរៀបចំឡើងជាសកម្មភាពដោយមានការចូលរួម ដូចដែលបានបង្ហាញខាងក្រោមនេះ។ ជម្រើសផ្សេងទៀត*សំណួរពេលចាប់ផ្តើម* ជាលាយលក្ខណ៍អក្សរ ( **ឧបសម្ព័ន្ធទី៣** ) ក៏អាចប្រើប្រាស់បានដែរ ។<br>*សំណួរពេលចាប់ផ្តើម–សកម្មភាពបែបចូលរួម*<br>• ចែកជូននូវប័ណ្ណចម្លើយសំណួរពេលចាប់ផ្តើម និងពេលបញ្ចប់ ( **ឧបសម្ព័ន្ធទី៥** ) ឱ្យទៅអ្នកចូលរួមម្នាក់ៗ និងសុំឱ្យពួកគាត់លើកប័ណ្ណ ដែលមានគូស "ធីក" ប្រសិនបើគាត់ឆ្លើយ "បាទ/ចាស" លើកកាតគូសខ្វែង ប្រសិនបើគាត់ឆ្លើយថា "ទេ" និងលើកប័ណ្ណជា "សញ្ញាសួរ" ប្រសិនបើចម្លើយរបស់គាត់ថា "មិនដឹង" ជាការឆ្លើយនឹង **សំណួរពេលចាប់ផ្តើម។** អ្នកសម្របសម្រួល ( ឬជំនួយការ ) នឹង ត្រូវកត់ត្រាដោយប្រុងប្រយ័ត្នទុកចំនួនគូស "ធីក" "សញ្ញាខ្វែង" និង "សញ្ញាសួរ"សម្រាប់សំណួរនីមួយៗ នៅលើក្រដាសគំរូដែលបានផ្តល់ឱ្យនៅក្នុង **ឧបសម្ព័ន្ធទី៦**។<br>• ជម្រើសងាយស្រួលមួយផ្សេងទៀតក្នុងការបែងចែក "សញ្ញាធីក" "សញ្ញាខ្វែង" និង "សញ្ញាសួរ" គឺត្រូវចែកបន្ទប់ជាបីចំណែក ។<br>• ដាក់ "សញ្ញាធីក" "សញ្ញាខ្វែង" និង "សញ្ញាសួរ" ជាបីកន្លែងផ្សេងគ្នា។ ហើយសុំឱ្យអ្នកចូលរួមដើរទៅកាន់ផ្នែកនៃបន្ទប់ស្របតាម ការឆ្លើយរបស់ពួកគាត់ ដោយមានចម្លើយ "បាទ/ចាស" ( សញ្ញាធីក ) "ទេ" ( សញ្ញា ខ្វែង ) ឬ "មិនដឹង" ( សញ្ញាសួរ )។ |
| **តើការរំលោភបំពានផ្លូវភេទកុមារគឺជាអ្វី ?** | | |
| **ស្លាយទី៨** ●<br> | • មុននឹងនិយាយអំពី "ការរំលោភបំពានផ្លូវភេទកុមារ" យើងត្រូវយល់ថា តើអ្វីទៅជា "ការរំលោភបំពានលើកុមារ" ជាមុនសិន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៩** ●<br><br> | • ការរំលោភបំពានកុមារគឺជាសកម្មភាពទាំងឡាយណា (ឬមិនមែនជាសកម្មភាព) ដែលមិនមែនជាការចៃដន្យ និងធ្វើឱ្យ ឈឺចាប់ដល់កុមារ ឬធ្វើឱ្យកុមារស្ថិតក្នុងគ្រោះថ្នាក់។<br>• ការរំលោភបំពានលើកុមារអាចនឹងបង្ករឱ្យមានគ្រោះថ្នាក់ជាក់ស្ដែង ឬគ្រោះថ្នាក់អាចកើតមានចំពោះសុខភាពរបស់កុមារ ការរស់រានមានជីវិត ការអភិវឌ្ឍន៍ និង/ឬ សេចក្ដីថ្លៃថ្នូររបស់កុមារ។ | សូមមើល **កាតយកតាមខ្លួន (តើអ្វីជាការរំលោភបំពានលើកុមារ?)**<br>អ្នកសម្របសម្រួលគួរតែមើលនិយមន័យ និងផ្នែកដែលពាក់ព័ន្ធនៅក្នុងច្បាប់ជាតិ តាមការគួរ។<br><br> |
| **ស្លាយទី១០** ●<br> | មានទម្រង់សំខាន់ៗចំនួនបួន នៃការរំលោភបំពានលើកុមារ បើទោះបីជាញឹកញាប់ វាតែងតែកើតឡើង ដំណាលគ្នាក៏ដោយ៖<br>**ការរំលោភបំពានលើរាងកាយ**<br>• ការរំលោភបំពានលើផ្លូវកាយកើតមាននៅពេលដែលមនុស្សម្នាក់មានបំណងបង្ករបួស ឬគំរាមកំហែងចង់បង្កររបួសដល់កុមារណាម្នាក់។<br>• សកម្មភាពទាំងនេះរួមមាន ការវាយដាល់ គ្រវែង ទាត់ ដុត ច្រាន ខ្ទប់ដង្ហើម ចាប់ក្រៀក/ចង បំពុល ឬហាមឃាត់ការធ្វើចលនារបស់កុមារ។<br>**ការរំលោភបំពានផ្លូវចិត្ត**<br>• ការរំលោភបំពានផ្លូវចិត្តគឺជាការធ្វើបាបចិត្តជាប្រចាំ និងធ្ងន់ធ្ងរ។<br>• ការរំលោភបំពានផ្លូវចិត្តវាយប្រហារដល់ការគោរពខ្លួនឯងរបស់កុមារ។<br>• វាក៏អាចមានទម្រង់ជាការហៅឈ្មោះកុមារធ្វើឱ្យគេឈឺចាប់ ឬហៅឈ្មោះគេដោយពាក្យអសុរោះ គំរាមកំហែង និយាយចំអកឡកឡឺយ បំភិតបំភ័យ ឬទុកកុមារឱ្យនៅតែឯង ។<br>• គ្រប់ទម្រង់នៃការរំលោភបំពានកុមារទាំងអស់មានផលប៉ះពាល់ផ្លូវចិត្តកុមារ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | **ការមិនអើពើ**<br>• ការមិនអើពើ គឺជាការខកខានយ៉ាងធ្ងន់ធ្ងរក្នុងការផ្តល់នូវការថែទាំសំខាន់ៗសម្រាប់កុមារ។<br>• ឧទាហរណ៍៖ ការពារពួកគេពីការប្រឈមទៅនឹងគ្រោះថ្នាក់ ឬមិនផ្តល់ការយកចិត្តទុកដាក់ថែទាំវេជ្ជសាស្ត្រ ឬតម្រូវការជាមូលដ្ឋានរបស់ពួកគេ (ដូចជាអាហារ សម្លៀកបំពាក់ ជម្រក ឬ ការថែទាំផ្លូវចិត្ត)។<br>**ការរំលោភបំពានផ្លូវភេទ**<br>• ការរំលោភបំពានផ្លូវភេទកើតមាននៅពេលដែលនរណាម្នាក់នាំកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទរបស់គេដោយការប្រើអំណាចលើកុមារ ឬរំលោភលើសេចក្តីទុកចិត្តរបស់កុមារ។<br>• ការរំលោភបំពានផ្លូវភេទកុមារ រួមមានរាល់ទម្រង់នៃអាកប្បកិរិយាផ្លូវភេទដោយបង្ខំ។ សកម្មភាពនេះអាចរួមមានទាំងការប៉ះពាល់ ឬមិនមានប៉ះពាល់ផងដែរ។<br>• ការរំលោភបំពានផ្លូវភេទកុមាររួមមាន៖<br>– ផលិតរូបភាព/រូបថត/វីដេអូ ជាទម្រង់រំលោភបំពាននៃកុមារ<br>– បង្ខំកុមារឱ្យមើល ឬចូលរួមក្នុងសកម្មភាពផ្លូវភេទ ឬ<br>– បង្ខំ/គំរាមកំហែងកុមារឱ្យមើលរួមភេទ ឬចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយកុមារ ឬមនុស្សពេញ  វ័យផ្សេងទៀត។<br>ថ្ងៃនេះ យើងផ្តោតលើការរំលោភបំពានប្រភេទទី៤ គឺការរំលោភបំពានផ្លូវភេទកុមារ។ ទោះជាយ៉ាងណាក៏ដោយចាំបាច់ ត្រូវដឹងថាការរំលោភបំពានទាំងបួនប្រភេទនេះជារឿយៗ មានការជាប់ពាក់ព័ន្ធគ្នា ហើយមិនកើតឡើងដាច់តែឯងឡើយ។ ឧទាហរណ៍៖ កុមារដែលទទួលរងការរំលោភបំពានផ្លូវចិត្ត ជារឿយៗ មិនទទួលបានការ យកចិត្តទុកដាក់ទេ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១១** ●<br><br> | • មិនទាន់មានស្ថិតិច្បាស់លាស់ស្តីពីចំនួនកុមារដែលទទួលរងការរំលោភបំពានផ្លូវភេទ។<br>• ជាញឹកញាប់គឺជាការពិបាកដឹងពីចំនួនពិតប្រាកដណាស់ពីព្រោះជារឿយៗ មនុស្ស មិនរាយការណ៍ពីករណីរំលោភបំពានទេ ហើយជាញឹកញាប់ករណីទាំងនេះមិនត្រូវបានរាប់នោះបញ្ចូលនោះទេ។ ប៉ុន្តែតាមការ ប៉ាន់ស្មាន ករណីរំលោភបំពានផ្លូវភេទ មានរាប់លានករណី។<br>• ការរំលោភបំពានកុមារគឺមិនមែនតែក្នុងតំបន់នេះទេ។ បញ្ហាទាំងនេះកើតឡើងគ្រប់ប្រទេសនៅលើពិភពលោក។<br>• វាគឺជារឿងធម្មតា ដែលកុមារមានបទ ពិសោធន៍ រងការរំលោភបំពានជាច្រើនរូបភាពជាជាងរងការរំលោភបំពានតែមួយប្រភេទ។ ឧទាហរណ៍ កុមារអាចត្រូវឪពុកម្តាយ មិនយកចិត្តទុកដាក់ និងផ្លាស់ទីទៅរស់នៅ តាមចិញ្ចើមថ្នល់ ហើយពួកគេអាចក្លាយជាជនរងគ្រោះនៃការ រំលោភបំពានផ្លូវកាយ និងការរំលោភបំពានផ្លូវចិត្ត និង/ឬ ការរំលោភបំពានផ្លូវភេទ។ | • ដើម្បីសង្កត់ធ្ងន់នូវភាព ពាក់ព័ន្ធបរិបទ និងទិដ្ឋភាពពិតក្នុងមូលដ្ឋាន អ្នកសម្របសម្រួល គួរផ្តល់ឧទាហរណ៍ដែលស្រង់ពីប្រព័ន្ធផ្សព្វផ្សាយ ពីករណីការរំលោភបំពានផ្លូវភេទលើកុមារនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។<br>• វានឹងជាជំនួយសម្រាប់ អ្នកសម្របសម្រួល ក្នុងការចែករំលែកស្ថិតិ ឬនិន្នាការថ្នាក់ជាតិ ជាមួយអ្នកចូលរួមនៅដំណាក់កាលនេះ ដើម្បីឱ្យអ្នកចូលរួមបានដឹងច្បាស់អំពីអ្វីដែលអ្នកជំនាញ ឬមន្ត្រីថ្នាក់ជាតិ បានលើកឡើងលើប្រធានបទនេះ។<br>ការស្រាវជ្រាវថ្មីៗបានបង្ហាញថា៖ តាមទស្សនៈវិស័យមួយនៅក្នុង តំបន់ របាយការណ៍ស្រាវជ្រាវឆ្នាំ២០១២ របស់អង្គការយូនីសេហ្វ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានរកឃើញថា ៖<br>• ការរីករាលដាលនៃការរំលោភបំពានធ្ងន់ធ្ងរលើរាងកាយ បានកើនឡើងចំពោះកុមារនៅក្នុងតំបន់នេះ ពី៩% ទៅ២៥%។<br>• គេរកឃើញថា ក្មេងកុមារា និងកុមារីពី ១៤% ទៅ ៣០% បានជួបប្រទះ នឹងបញ្ហារួមភេទដោយការបង្ខិតបង្ខំនៅក្នុងឆាកជីវិតរបស់ពួកគេ។<br>• ក្មេងជំទង់ និងមនុស្សពេញវ័យ ដែលធ្លាប់ឆ្លងកាត់បទពិសោធន៍នៃការរំលោភបំពាន ផ្លូវភេទ និង/ឬ ការរំលោភបំពានលើរាងកាយ ពេលពួកគេនៅជាកុមារ គឺទំនងជាគិតដល់ ឬប៉ុនប៉ងធ្វើអត្តឃាតខ្លួនឯងដល់ទៅបួនដង ច្រើនជាងអ្នកដែលមិនធ្លាប់មានប្រវត្តិរងការរំលោភបំពាន ។<br>*(ប្រភព: យូនីសេហ្វ ការធ្វើទុក្ខទោសកុមារ ប្រវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាកនៅតំបន់អាស៊ីខាងកើត និងបាស៊ីហ្វិច ឆ្នាំ២០១២)* |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr><td>

**ស្លាយទី១២**




</td><td>

- ការរំលោភបំពានកុមារគឺជាអំពើខុសច្បាប់។
- កុមារមានសិទ្ធិទទួលបានការការពារពីការរំលោភបំពានផ្លូវភេទ ស្របតាមច្បាប់ជាតិនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។
- កុមារក៏មានសិទ្ធិទទួលបានការការពារពីការរំលោភបំពានគ្រប់ទម្រង់ផងដែរស្របតាមច្បាប់អន្តរជាតិ ដែលអ្នកប្រហែលជាធ្លាប់ឮដូចជា *អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ* ដែលគ្រប់ប្រទេសទាំងអស់នៅតំបន់អាស៊ីអគ្នេយ៍បានផ្តល់សច្ចាប័ន។

</td><td>

អ្នកសម្របសម្រួលគួរស្រាវជ្រាវរកព័ត៌មានខ្លះៗ ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់ ក្នុងប្រទេសមុនពេលនៃវេទិកាពិភាក្សា និងធ្វើការសង្ខេបខ្លះពី ៖

- តើមានច្បាប់ពាក់ព័ន្ធអ្វីខ្លះ ?
- តើច្បាប់នេះត្រូវបានអនុវត្តនៅក្នុងប្រទេសយ៉ាងដូចម្តេច ?

អនុសញ្ញា អង្គការសហប្រជាជាតិ*ស្តីពីសិទ្ធិកុមារ ដែលងាយស្រួលយល់ ក៏អាចចែកចាយជូនផងដែរ ប្រសិនបើចាំបាច់។*

</td></tr>
<tr><td>

**ស្លាយទី១៣**




</td><td>

- ការរំលោភបំពានផ្លូវភេទកុមារ គឺជាប្រធានបទងាយរសើបមួយ។ នេះជាអ្វីម្យ៉ាងដែលយើងមិនចង់និយាយដល់។ ជាលទ្ធផលមនុស្សជាច្រើន មានការយល់ច្រលំលើប្រធានបទនេះ។ មួយវិញទៀត មនុស្សជាច្រើនគិតថា នេះគឺជាបញ្ហាដែលនៅឆ្ងាយ ដែលមិនប៉ះពាល់ដល់ពួកគេ សហគមន៍ ឬគ្រួសាររបស់ពួកគេឡើយ។
- ដោយហេតុថា មនុស្សយើងច្រើនតែមិនចូលចិត្តនិយាយអំពីការរំលោភបំពានលើកុមារ ជាហេតុធ្វើឱ្យមាន ជំនឿខុសឆ្គងជាច្រើន ពីការរំលោភបំពានផ្លូវភេទលើកុមារ។
- អ្នករំលោភបំពានផ្លូវភេទលើកុមារ ឆ្លៀតយកឱកាសនៃការកង្វះចំណេះដឹងរបស់ប្រជាជនអំពីរបៀបប្រព្រឹត្តិបទល្មើសរបស់ពួកគេ ដើម្បីរំលោភបំពានកុមារ។ នេះជាមូលហេតុសំខាន់ដែលយើងត្រូវមានតែព័ត៌មាន និងពិភាក្សាពីបញ្ហានេះ។
- ព័ត៌មាន និងការពិភាក្សា ធ្វើឱ្យយើងម្នាក់ៗ និងសហគមន៍ កាន់តែរឹងមាំ ដើម្បីការពារកុមាររបស់យើង។

</td><td></td></tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **តើខ្ញុំអាចការពារកូនរបស់ខ្ញុំឱ្យមានសុវត្ថិភាពបានដោយរបៀបណា ?** | | |
| **ស្លាយទី១៤** ●<br><br> | • ក្នុងនាមជាឪពុកម្ដាយ និងអ្នកថែទាំ យើងមានតួនាទីដ៏សំខាន់បំផុតក្នុងការការពារកូនៗរបស់យើង។<br>• មានជំហានងាយៗ ដែលយើងទាំងអស់គ្នាអាចធ្វើបាន ដើម្បីទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារ និងកសាងបរិស្ថានប្រកបដោយការការពារសម្រាប់កុមារ៖<br>១. មានព័ត៌មានគ្រប់គ្រាន់<br>២. និយាយជាមួយកូនរបស់យើង<br>៣. ដឹងអំពីអ្វីដែលកំពុងកើតមានឡើង<br>៤. ស្គាល់អ្នកដែលត្រូវទំនាក់ទំនងដើម្បីសុំជំនួយ<br>• នៅពេលយើងបានធ្វើអ្វីៗគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីធ្វើឱ្យកូនរបស់យើងមានសុវត្ថិភាពនៅក្នុងផ្ទះ សហគមន៍ របស់យើងទាំងមូលយើងក៏អាចធ្វើរួមគ្នាបាន ដើម្បីធ្វើឱ្យកុមារកាន់តែមានសុវត្ថិភាព។ នេះរាប់បញ្ចូលសាលារៀន សួនកំសាន្ត និងទីកន្លែងដែលកុមារត្រូវទៅ។<br>• បច្ចុប្បន្ននេះពួកយើងនឹងក្រលេកមើលសកម្មភាពនីមួយៗចំនួនបួន នៅក្នុងព័ត៌មានលម្អិត។ | សូមមើល **កាតយកតាមខ្លួន** *(តើខ្ញុំអាចការពារកូនរបស់ខ្ញុំឱ្យមានសុវត្ថិភាពបានដោយរបៀបណា ?)*<br><br> |
| **1. តើព័ត៌មានអ្វីខ្លះដែលពួកយើងត្រូវដឹង ?** | | |
| **ស្លាយទី១៥** ●<br><br> | • ដើម្បីការពារកុមារ យើងចាំបាច់ត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីការរំលោភបំពានលើកុមារ។<br>• ព័ត៌មានត្រឹមត្រូវ ធ្វើឱ្យយើងកាន់តែរឹងមាំ នឹងត្រៀមខ្លួនជាស្រេច ដើម្បីកសាងបរិស្ថានប្រកបដោយការការពារ និងអាចឆ្លើយតបបាននៅពេលកុមារប្រឈមជាមួយបញ្ហា។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៦** •<br> | តើនរណាខ្លះជាជនរងគ្រោះ ?<br>• អ្នករំលោភបំពាន អាចកំណត់គោលដៅចំពោះកុមារណាម្នាក់មកពីប្រភពណាមួយ។<br>• ជនរងគ្រោះអាចជាកុមារា និងកុមារី។<br>• កុមារគឺជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។ ជនរងគ្រោះអាចមានអាយុចន្លោះពី០-១៧ ឆ្នាំ។ ពួកគេអាចជាទារកកុមារតូច ឬមនុស្សវ័យជំទង់។<br>• កុមារភេទទីបី ឬកុមារដែលកំពុងស្វែងយល់ ពីទំនោរផ្លូវភេទរបស់ខ្លួនអាចប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្ពស់។<br>• កុមារពិការក៏អាច ស្ថិតនៅក្នុងគ្រោះថ្នាក់កើនឡើងជាលំដាប់ផងដែរ។ កុមារពិការនេះរួមមាន កុមារពិការគ្រប់ប្រភេទដូចជាពិការភាពលើរូបរាងកាយ ពិការភាព ផ្នែកវិញ្ញាណ( ដូចជាការអន់ថយផ្នែកការស្តាប់ការមើល ) ពិការភាពសតិបញ្ញា និងពិការភាពផ្នែកចិត្តវិកល។<br>• ការរំលោភបំពានលើកុមារ អាចប៉ះពាល់ដល់កុមារណាម្នាក់ នៅក្នុងគ្រួសារ។<br>• កុមារមិនគួរត្រូវបានស្តីបន្ទោសអំពីការរំលោភបំពានទេ។ សូមចងចាំថា ពេលខ្លះការស្តីបន្ទោសមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោល។កុមារណាដែលធ្លាប់បានក្លាយជាជនរង គ្រោះនៃការរំលោភបំពាន គួរត្រូវបានធានាយ៉ាងច្បាស់ថា ពួកគេ នឹងមិនត្រូវបានស្តីបន្ទោស ទៅលើអ្វីដែលបានកើតឡើងចំពោះគេទេ។ | អ្នកសម្របសម្រួលគួរប្រមូល និងផ្តល់ឧទាហរណ៍ពីប្រវត្តិរបស់ជនរងគ្រោះមកពីប្រទេសរបស់ខ្លួន ដើម្បីបង្ហាញពីទម្រង់ផ្សេងៗពាក់ព័ន្ធនឹងអាយុ ភេទ ទីកន្លែងជាដើម។<br>ឧទាហរណ៍នានាពីប្រព័ន្ធផ្សព្វផ្សាយ ( មិនប្រាប់អត្តសញ្ញាណជនរងគ្រោះ ដោយផ្ទាល់ ) អាចជាការល្អក្នុងស្ថានភាពនេះ។<br>ត្រូវយកចិត្តទុកដាក់ឲ្យ បានច្រើនបំផុតចំពោះឥរិយាបទប្រកាន់វណ្ណៈ ឬអាកប្បកិរិយារើសអើង ដើម្បីធានាធ្វើយ៉ាងណាឲ្យមានភាពស្មើគ្នា សម្រាប់កុមារទាំងអស់។ ការយកចិត្តទុកដាក់លើបញ្ហានេះគឺត្រូវការជាចាំបាច់ ដើម្បីធានាថា អ្នកសម្របសម្រួល មិនបន្តអាកប្បកិរិយា ឬទស្សនៈរើសអើងលើទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី។ ការបន្តនូវទស្សនៈរើសអើង លើទំនោរផ្លូវភេទ អត្តសញ្ញាណយេនឌ័រ និងពូជសាសន៍ គឺមិនអនុលោមទៅតាមសិទ្ធិ កុមារអន្តរជាតិឡើយ ហើយចូលរួមចំណែកធ្វើឲ្យមានភាពងាយរងគ្រោះ ដែលដាក់កុមារឲ្យស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន។ |
| **ស្លាយទី១៧** •<br> | • ជាញឹកញាប់គេតែងតែយល់ខុសថា កុមារា មិនអាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទនោះទេ។<br>• ដោយហេតុនេះ ពេលខ្លះសហគមន៍យកចិត្តទុកដាក់លើការការពារកុមារីច្រើនជាងកុមារា។<br>• ការធ្វើបែបនេះអាចទុកឱ្យកុមារាងាយរងគ្រោះខ្លាំងទៅនឹងការរំលោភបំពាន។<br>• វាក៏មានការលំបាកផងដែរ សម្រាប់កុមារាក្នុងការប្រាប់នរណាម្នាក់អំពីការរំលោភបំពាន ដោយសារតែការរើសអើងពីសង្គម វិប្បដិសារីដែលសង្គមជេរស្តី និងការយល់ខុសជាដើម។ | ការសិក្សាស្រាវជ្រាវមួយ បានបង្ហាញថា ជាញឹកញាប់សហគមន៍មិនជឿថា កុមារា គឺជាគោលដៅនៃការរំលោភបំពានផ្លូវភេទទេ។ ការយល់បែបនេះ ផ្តល់ផលប៉ះពាល់អវិជ្ជមាន ខ្លាំងសម្រាប់សុខុមាលភាពរបស់កុមារា ហើយមានន័យថា សហគមន៍ប្រហែលជាមិនបានអនុវត្តនូវយន្តការការពារ ចំពោះកុមារា បើប្រៀបធៀបជាមួយនឹងកុមារី។ ជាឧទាហរណ៍គេបានរកឃើញថា នៅក្នុងប្រទេសមួយចំនួន កុមារាប្រឈមភាពងាយរងគ្រោះជាពិសេសតែម្តង ចំពោះការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារតែឪពុកម្តាយរបស់គេមិនសូវហាមឃាត់កូនប្រុសរបស់ខ្លួន ពីការធ្វើដំណើរដែល គ្មានសុវត្ថិភាពទេ បើប្រៀបធៀបទៅនឹងកូនស្រី។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៨** ●   | តើនរណាខ្លះជាអ្នករំលោភបំពាន?<br>• គេមិនអាចនិយាយជាមុនថា តើអ្នករំលោភបំពាននោះមានភិនភាគដូចម្តេចនោះទេ។<br>• មនុស្សដែលត្រូវបានរំលោភបំពានផ្លូវភេទលើកុមារ អាចជានរណាក៏បាន៖<br>– បុរស ឬស្ត្រី<br>– សមាជិកគ្រួសារ (ឪពុក ម្តាយ អ៊ំ/ពូមីង បងប្អូនជីដូនមួយ ជីតាជីដូន ឬសាច់ញាតិផ្សេងទៀត)។<br>– អ្នកជិតខាង មិត្តភក្តិ ឬមនុស្សដែលគួរឱ្យទុកចិត្ត (គ្រូបង្រៀន បុគ្គលិកសាលា អ្នកធ្វើការក្លឹបកីឡា បុគ្គលិកពេទ្យ។ល។) សូមចាំថា កុមារាត្រូវបានរំលោភបំពានដោយអ្នកដែលគេធ្លាប់ស្គាល់រួចហើយ។<br>– មនុស្សប្លែកមុខ<br>– កុមារ និងមនុស្សពេញវ័យផ្សេងទៀត។ វាជាការសំខាន់ ដែលត្រូវឃ្លាំមើលការរំលោភបំពាន ផ្លូវភេទដែលប្រព្រឹត្តឡើងនៅពេលខ្លះ ដោយកុមារផ្សេងទៀត ជាអ្នកដែលអាយុច្រើនជាង។<br>– មនុស្សដែលមកពីសហគមន៍ ឬប្រទេសផ្សេងទៀត គ្រប់អាយុទាំងអស់ ការងារ ឬសាសនាផ្សេងៗគ្នា។<br>– អ្នករំលោភបំពានភាគច្រើននៅក្នុងសហគមន៍អាចជាអ្នកនៅក្នុងស្រុក<br>• ថ្វីបើគេមិនអាចកំណត់អត្តសញ្ញាណអ្នករំលោភបំពានផ្លូវភេទកុមារ តាមរយៈការមើលពីរូបរាងខាងក្រៅរបស់ពួកគេក្តី គេអាច ដឹងបានអំពីអាកប្បកិរិយាគួរឱ្យសង្ស័យ ដែលមនុស្សពេញវ័យបង្ហាញចេញមក។ | ក្នុងមូលដ្ឋាន/ប្រទេស/អន្តរជាតិ។ ករណីសិក្សាគួរត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីទម្រង់ប្រែប្រួលនៃអ្នករំលោភបំពានដែលត្រូវបាន ចាប់ខ្លួន។<br><br>ជាថ្មីម្តងទៀត វាជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ទៅលើផ្នត់គំនិតយេនឌ័រ ដែលកើតមាន អំពីអ្នករំលោភបំពាន។ ទោះបីជាករណីដែលគេរាយការមកនោះ បង្ហាញថា អ្នករំលោភបំពាន ជាទូទៅ គឺជាបុរសនោះ ក៏មានគេដឹងកាន់តែច្រើនថា មនុស្សស្រីក៏ប្រព្រឹត្តទង្វើរំលោភបំពាន ផ្លូវភេទលើកុមារផងដែរ ហើយផលប៉ះពាល់ មកលើកុមារ គឺមានសភាពធ្ងន់ធ្ងរដូចគ្នា។<br><br>លើកឡើងថា មានករណីរំលោភបំពានជាច្រើន មិនត្រូវបានគេរាយការណ៍ដោយសារមូលហេតុមួយចំនួន ដូច្នេះរូបភាពពិតជាក់ស្តែងនៃបញ្ហានេះគឺមិនច្បាស់លាស់ទេ។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr><td>

**ស្លាយទី១៩ •**




</td><td>

តើអ្នករំលោភបំពានផ្លូវភេទកុមារប្រតិបត្តិដូចម្តេច?

- អ្នករំលោភបំពានជួបជាមួយនឹងកុមារ ហើយធ្វើការរំលោភបំពានក្នុងរូបភាពជាច្រើន។
- មនុស្សច្រើនតែគិតថា ការរំលោភបំពានផ្លូវភេទលើកុមារ កើតឡើងក្នុងលក្ខណៈជាការវាយប្រហារពីមនុស្សមិនដែល ស្គាល់មុខ។
- តាមពិត អ្នករំលោភបំពានច្រើនតែចំណាយពេលវេលា ដើម្បីកសាងទំនាក់ទំនងជាមួយកុមារ (និងពេលខ្លះ កសាងទំនាក់ទំនងជាមួយគ្រួសារកុមារ)។

</td><td>

សូមមើល **កាតតាមខ្លួន** *"តើអ្នករំលោភបំពានផ្លូវភេទកុមារប្រតិបត្តិយ៉ាងដូចម្តេច?"*



តើអ្នករំលោភបំពានផ្លូវភេទកុមារប្រតិបត្តិការយ៉ាងដូចម្តេច?

អ្នករំលោភបំពាន អាចប្រើប្រាស់វិធីផ្សេងៗជាច្រើនដើម្បីចូលទៅរកកុមារនិងរំលោភបំពានកុមារ។ មនុស្សជាច្រើនតែងគិតថា ការរំលោភបំពានផ្លូវភេទកុមារ ច្រើនតែកើតឡើងក្នុងលក្ខណៈជាការវាយប្រហារដោយមនុស្សមិនដែលស្គាល់គ្នា។ តាមពិត អ្នករំលោភបំពាន និង/ឬមេអណ្តើកច្រើនចំណាយពេលដើម្បីសាងទំនាក់ទំនងជាមួយកុមារ (និងពេលខ្លះជាមួយគ្រួសាររបស់កុមារ)។

ដំណើរការនេះហៅថា "ការល្បួង" ហើយអាចរួមមានដំហ៊ានជាច្រើន៖



អ្នករំលោភបំពានស្វែងរកកុមារដែលខ្លួនចង់រំលោភបំពាន។ ជារឿយៗ ពួកគេច្រើនជ្រើសរើសយកកុមារ ដែលងាយរងគ្រោះ។

អ្នករំលោភបំពានកសាងការទុកចិត្តពីកុមារ តាមរយៈការចែករំលែកចំណាប់អារម្មណ៍ជាមួយកុមារ ផ្តល់អំណោយផ្សេងៗដល់កុមារនិងធ្វើជាមិត្តរបស់កុមារ។

អ្នករំលោភបំពានចាប់ផ្តើមមានការសម្ងាត់ជាមួយកុមារ និងប្រើប្រាស់ការសន្យា ការគម្រាម ឬការបង្ខំ ដើម្បីឱ្យកុមាររក្សាភាពស្ងៀមស្ងាត់។

អ្នករំលោភបំពាន ពង្រីកលក្ខណៈផ្លូវភេទនៅក្នុងទំនាក់ទំនងរបស់ពួកគេ កាន់តែធំឡើងៗ។ ពួកគេលើកឡើងអំពីបញ្ហាផ្លូវភេទ និងចែករំលែកសម្ភារៈផ្លូវភេទដើម្បីឱ្យកុមារស៊ាំ។

អ្នករំលោភបំពានអនុវត្ត (ប្រតិបត្តិ) សកម្មភាពដែលមានលក្ខណៈរំលោភបំពានផ្លូវភេទ។

មិនមែនអ្នករំលោភបំពានទាំងអស់សុទ្ធតែប្រើប្រាស់បច្ចេកទេសល្បួងនោះឡើយ។ វិធីដទៃទៀតមានដូចជា ការវាយប្រហារភ្លាមៗ ការទិញ ការបញ្ឆោត និងកេងប្រវ័ញ្ច ការបង្ខំ។ ជារឿយៗ អ្នករំលោភបំពានមិនធ្វើសកម្មភាពតែម្នាក់ឯងនោះឡើយ។ ពួកគេអាចនឹងទទួលការជួយជ្រោមជ្រែង ឬការគាំទ្រពីមនុស្សផ្សេងទៀត ដូចជាជំនួយការ អ្នករកទិញ ភ្នាក់ងារ មេអណ្តើក និងអ្នកសម្របសម្រួល ជាដើម។

តាមរយៈការសិក្សាពីឥរិយាបថរបស់អ្នករំលោភបំពានផ្លូវភេទកុមារ ដែលតុលាការបានប្រកាសសាលក្រមផ្តន្ទាទោសនោះ អ្នកស្រាវជ្រាវអាចបាន ឃើញទម្រង់ និងភាពស្រដៀងគ្នាយ៉ាងច្បាស់លាស់ ពីរបៀបដែល អ្នករំលោភបំពានប្រព្រឹត្ត។ ព័ត៌មាននេះភាគច្រើន គឺផ្អែកទៅលើទិន្នន័យដែលបានមកពីបច្ចឹមប្រទេស និង/ឬជនល្មើសនៅបច្ចឹមប្រទេស។ គួរមានការ សិក្សាស្រាវជ្រាវបន្ថែម ពីរបៀបដែលជនល្មើសរំលោភបំពានលើកុមារ នៅទ្វីបអាស៊ី។

</td></tr>
<tr><td>

**ស្លាយទី២០ •**




</td><td>

- ដំណើរការកសាងទំនាក់ទំនងជាមួយកុមារ និង/ឬ គ្រួសាររបស់កុមារា ឬកុមារី គឺត្រូវបានស្គាល់ថាជា"ការល្បួង"។ "ការល្បួង" អាចមានរូបភាពជាច្រើនផ្សេងៗគ្នា។
- ដំបូង អ្នករំលោភបំពានបានព្យាយាមស្វែងរកកុមារ។ ជារឿយៗ ពួកគេជ្រើសរើសកុមារដែលងាយរងគ្រោះ។
- កុមារងាយរងគ្រោះគឺជាកុមារណាម្នាក់ដែលប្រហែលជាមិនអាចប្តឹងតវ៉ាគេបានជាកុមារដែលឯការ ឬមិនឱ្យមានទំនាក់ទំនងជាមួយមនុស្សពេញវ័យដែលគួរទុកចិត្តបាន ឬត្រូវបានសហគមន៍ផាត់ចោល។ ឧទាហរណ៍ដូចជា គ្រួសារមានតែឪពុក/ម្តាយតែម្នាក់ដែលមានកូនច្រើន កុមារដែលរស់នៅឆ្ងាយពីគ្រួសារ កុមារពិការកុមារ ដែលមានអារម្មណ៍តប់ប្រមល់ក្នុងជីវិតកុមារដែលប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារជាដើម។

</td><td>

- នៅក្នុងប្រទេសមួយចំនួន "ការទាក់ទងកុមារតាមអិនធើណេត" គឺជាបទល្មើសព្រហ្មទណ្ឌ ពីព្រោះគេបានកត់សម្គាល់ឃើញថា វាបានបង្កផលប៉ះពាល់ដល់កុមារ។
- បើសមស្រប អ្នកសម្រសម្រួលអាចដកស្រង់ច្បាប់នានា ដែលមានក្នុងស្រុក។

</td></tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២១** ●<br> | • បន្ទាប់មក អ្នករំលោភបំពានបន្តកសាងការទុកចិត្តរបស់កុមារ តាមរយៈការចែករំលែកចំណាប់អារម្មណ៍ ផ្តល់ជាអំណោយ និងធ្វើជាមិត្តរបស់ពួកគេ។ ពេលខ្លះអ្នករំលោភបំពានចូលមកធ្វើជាសិទ្ធស្គាល់ជាមួយគ្រួសារកុមារផងដែរ។ ជាឧទាហរណ៍ អ្នករំលោភបំពានម្នាក់អាចជាមិត្តភក្តិជាមួយនឹងម្ដាយ ដើម្បីទទួលបានការទុកចិត្តពីគាត់ និងដើម្បីមានលទ្ធភាពជួបជាមួយនឹងកូនរបស់គាត់បាន។<br>• សកម្មភាពនេះ អាចរួមមានដូចជា ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រួសាររស់នៅជាមួយគ្រួសារនោះដោយផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ កុមារ (សម្រាប់ឱ្យកុមារទៅសាលារៀន ឬសម្រាប់តម្រូវការផ្សេងទៀតរបស់កុមារ)។<br>• ក្នុងករណីភាគច្រើន អ្នករំលោភបំពានមួយចំនួន មានអំណាច លើកុមារ ដោយសារវ័យ អាយុរបស់គេ ភាពចាស់ទុំ កម្លាំងបាយ ឬតួនាទីអំណាច ឬការគ្រប់គ្រង។ | |
| **ស្លាយទី២២** ●<br> | • នៅពេលដែលអ្នករំលោភបំពានកសាងទំនាក់ទំនងជាមួយកុមារ ពួកគេចាប់ផ្តើមបង្កើតរឿងសម្ងាត់ជាមួយកុមារ ដើម្បីធ្វើឲ្យប្រាកដថា កុមារនឹងមិនលាតត្រដាងពីការរំលោភបំពាននោះ។<br>• ជារឿយៗ ការសម្ងាត់នោះ ទាក់ទងនឹងការសន្យាការគំរាម ឬការបង្ខិតបង្ខំ។ ពេលខ្លះ អ្នករំលោភបំពាន ហៅការសម្ងាត់ទាំងនេះថាជា "ទំនាក់ទំនងពិសេស" ជាមួយកុមារ។ តាមធម្មតា កុមាររងនូវការរំលោភបំពាន ផ្លូវចិត្ត និងត្រូវអ្នករំលោភបំពានកេងយកចំណេញ។<br>• ឧទាហរណ៍ កុមារអាចមានអារម្មណ៍ថាអ្នករំលោភបំពានគឺជាបុគ្គលតែម្នាក់គត់ដែលយកចិត្តទុកដាក់លើខ្លួន ហើយបុគ្គលនោះក្លាយទៅជាមនុស្ស ដែលគេទុកចិត្តបំផុត។ ជាញឹកញាប់ កុមារមានអារម្មណ៍ថា មនុស្សពេញវ័យមិនយល់ចិត្តរបស់គេ។<br>• ដូច្នេះ កុមារអាចនឹងទទួលរងឥទ្ធិពលយ៉ាងងាយស្រួល នៅពេលពួកគេ ប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យម្នាក់ ដែលយល់ច្បាស់ពីខ្លួន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៣** ●<br><br> | • ពេលវេលាអាចខុសគ្នា ពីមួយករណីទៅមួយករណី ប៉ុន្តែជារឿយៗ អ្នករំលោភបំពាន នឹងពង្រីកលក្ខណៈផ្លូវភេទនៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយកុមារ ឱ្យកាន់តែធំឡើងៗ។ ទង្វើទាំងនេះមានដូចជា ការឱ្យកុមារចូលទៅប៉ះពាល់ជាមួយសម្ភារផ្លូវ ភេទជាដើម ដើម្បីធ្វើឱ្យកុមារ"លែងមានការ ចាប់អារម្មណ៍" ឬមិនសូវមានអារម្មណ៍ រន្ធត់ ឬ តប់ប្រមល់។<br>• ឧទាហរណ៍ អ្នករំលោភបំពានអាចនឹងចាប់ផ្តើមប៉ះពាល់កុមារ ឬបង្ហាញកុមារពីរូបភាពអាសអាភាសមួយចំនួន។ ជម្រើសផ្សេងទៀតគឺ អ្នករំលោភបំពានអាចនឹងចាប់ផ្តើមជជែកជាមួយនឹងកុមារអំពីសកម្មភាពផ្លូវភេទ។ | |
| **ស្លាយទី២៤** ●<br><br> | • អ្នករំលោភបំពាន ឈានឡើងទៅដល់ការប៉ះពាល់ក្នុងលក្ខណៈផ្លូវភេទ និងអាកប្បកិរិយាបែបរំលោភបំពានផ្លូវភេទ។ សូមចងចាំថា ការរំលោភបំពានផ្លូវភេទកុមារ មិនមែនត្រឹមតែមានន័យថា ជាការរំលោភសេពសន្ថវៈដោយការស៊កអង្គជាតិចូលក្នុងប្រដាប់ភេទតែប៉ុណ្ណោះទេ។ វាក៏អាចពាក់ព័ន្ធ នឹងសកម្មភាពផ្លូវភេទផ្សេងទៀតផងដែរ ដោយរាប់បញ្ចូលទាំងការប៉ះពាល់ ឬសូម្បីតែមិនប៉ះពាល់សោះក៏ដោយ។<br>• ការរំលោភបំពានអាចនឹងកើនឡើងពីពេលមួយទៅពេលមួយដោយចាប់ផ្តើមពីរឿងតូចៗ។<br>• ដោយសារសកម្មភាពនេះអាចកើតមាននៅក្រោយពីរយៈពេលណាមួយនោះ យើងមានឱកាសក្នុងការបង្ការការរំលោភបំពានកុំឱ្យមានស្ថានភាពកាន់តែអាក្រក់ទៅ ប្រសិនបើការរំលោភបំពាននោះត្រូវបានកំណត់ឃើញនៅក្នុងដំណាក់កាលនេះ។<br>• នៅក្នុងពេលនេះកុមារត្រូវបានគេ "ល្បួងលោមតាមអិនធើណេត" យ៉ាងល្អចទៅហើយ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នករំលោភ។<br>• ការល្បួងកើតមានឡើងនៅក្នុងបរិយាកាសផ្សេងៗគ្នាជាច្រើន ( ផ្ទះ សាលារៀន ក្លឹបកីឡា សួនច្បារការជជែកលេងតាមអិនធើណេត )។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៥ •**<br> | ការវាយប្រហារភ្លាមៗ<br>• មិនមែនអ្នករំលោភបំពានទាំងអស់គ្នា សុទ្ធតែប្រើប្រាស់វិធីសាស្រ្ត "លួងលោម តាមអ៊ីនធើណេត" នោះទេ។<br>• វិធីសាស្រ្តផ្សេងទៀតដែលអ្នករំលោភបំពាន អាចនឹងចូលទៅជួបជាមួយ នឹង កុមារបានរាប់ទាំង ការវាយប្រហារភ្លាមៗ ផងដែរ។<br>• អ្នករំលោភបំពាន អាចនឹងវាយប្រហារកុមារភ្លាមៗនៅពេលដែលឱកាសល្អអំណោយផល។ | |
| **ស្លាយទី២៦ •**<br> | ការធ្វើជាមេអណ្ដើក<br>• អ្នករំលោភបំពានអាចនឹងឱ្យប្រាក់ទៅនរណាម្នាក់ដើម្បីរកកុមារឱ្យខ្លួនដើម្បីរំលោភបំពាន។<br>• បន្ទាប់ទៀតមេអណ្ដើកនោះចាប់ផ្ដើមកំណត់គោលដៅលើកុមារ ឬគ្រួសាររបស់គេ។<br>• ឧទាហរណ៍៖ ប្រសិនបើអ្នករំលោភបំពានស្ថិតនៅក្រៅសហគមន៍ គេអាចនឹងប្រើប្រាស់បណ្ដាញក្នុងស្រុកនោះ ឬមេអណ្ដើក ឱ្យជួយស្វែងរកកុមារ និងធ្វើការរំលោភ បំពាន។ | អ្នកសម្របសម្រួលអាចរៀបរាប់លម្អិតពីព័ត៌មានពីករណីសិក្សាក្នុងស្រុក/ថ្នាក់ជាតិ/អន្តរជាតិនានា។<br>ឧទាហរណ៍មួយចំនួនរួមមាន៖<br>• ករណីដែលគេរាយការណ៍មានអ្នកបើកតាក់ស៊ី ឬអ្នករត់ម៉ូតូឌុប ដែលនាំអ្នករំលោភបំពាន ទៅកាន់ផ្ទះបន ឬកន្លែងផ្សេងទៀតជាទីដែល កុមារត្រូវបានគេកេងប្រវ័ញ្ច។ ក្នុងករណីខ្លះ៖ អ្នកបើកបរ ក្នុងស្រុកអាចនឹងនាំយកកុមារទៅឱ្យអ្នករំលោភបំពានតាមការស្នើរបស់គេដើម្បីបានប្រាក់កម្រៃ។<br>• មានការរាយការណ៍ពីបណ្ដាញដែលមានការចាត់តាំង និងការជួញដូរ ដែលកុមារត្រូវបានគេដឹកជញ្ជូននៅក្នុងប្រទេសឬឆ្លងប្រទេសសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ។<br>• មានករណីដែលកុមារជាជនរងគ្រោះពីការរំលោភបំពានផ្លូវភេទខ្លួនឯង ណែនាំកុមារផ្សេងទៀតទៅឱ្យអ្នករំលោភបំពានខ្លួនមុន។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| ស្លាយទី២៧ •<br> | ការឆបោក និងប្រើឧបាយកលបោកបញ្ឆោត<br>• ពាក់ព័ន្ធជាមួយនឹងការទិញជាប្រាក់ ដែលអ្នករំលោភបំពាន ឬឈ្មួញកណ្តាល អាចនឹងបោកប្រាស់ ឬរៀបចំផែនការបញ្ឆោតកុមារ ឬគ្រួសាររបស់គេ។ ករណីបែបនេះ គឺពិតជាមានគ្រោះថ្នាក់នៅពេលដែលកុមារ ឬ គ្រួសាររបស់គេកំពុងស្ថិតក្នុងស្ថានភាពលំបាក។<br>តាមរយៈការបង្ខិតបង្ខំ<br>• ពាក់ព័ន្ធជាមួយនឹងការទិញជាប្រាក់ ដែលអ្នករំលោភបំពាន ឬឈ្មួញកណ្តាល អាចនឹងបោកប្រាស់ ឬរៀបចំផែនការបញ្ឆោតកុមារ ឬគ្រួសាររបស់គេ។ ករណីបែបនេះ គឺពិតជាមានគ្រោះថ្នាក់នៅពេលដែលកុមារ ឬ គ្រួសាររបស់គេកំពុងស្ថិតក្នុងស្ថានភាពលំបាក។ | |
| ស្លាយទី២៨ •<br> | តើនរណាខ្លះទៀតដែលជាប់ពាក់ព័ន្ធ?<br>• នៅពេលយើងក្រឡេកមើលពីវិធីផ្សេងៗ ដែលអ្នករំលោភបំពាន ធ្វើសកម្មភាព គឺច្បាស់ណាស់ថា ជាញឹកញាប់ អ្នករំលោភបំពានមិនអាចធ្វើសកម្មភាពតែឯងបានទេ។<br>• អ្នករំលោភបំពានអាចនឹងទទួលការជួយ ឬគាំទ្រពីបុគ្គលម្នាក់ ឬច្រើនអ្នកជួយដល់ខ្លួនដើម្បីបានជួបជាមួយនឹងកុមារបាន និងប្រព្រឹត្តការរំលោភបំពាន។<br>• មនុស្សទាំងនេះរួមមាន ជំនួយការ ឈ្មួញកណ្តាល ភ្នាក់ងារ អន្តរការី ឬ អ្នកសម្របសម្រួលជាដើម។<br>• ឧទាហរណ៍ ក្នុងករណីដែលបានដឹងជាច្រើន អ្នករំលោភបំពានជាបុរស នឹងប្រើប្រាស់ "មិត្តស្រី" របស់ខ្លួន ជួយខ្លួនក្នុងការទិញជាប្រាក់ ឬរៀបចំបោកបញ្ឆោតកុមារ។ កុមារហាក់ដូចជាជឿជាក់លើមនុស្សស្រីច្រើនជាង។ មានករណីភាគច្រើន ដែលស្ត្រីគាំទ្រជនល្មើសជាបុរស ក្នុងការ រំលោភបំពានលើកុមារ។ ឧទាហរណ៍៖ ក្នុងនាមជាមិត្តភក្តិ មិត្តស្រី ឬស្រីរកស៊ីផ្លូវភេទ។ | ក្នុងករណីពាក់ព័ន្ធ អ្នកសម្របសម្រួលអាចទាញចំណាប់អារម្មណ៍ទៅលើនិន្នាការនៃក្តីបារម្ភជាពិសេស នៃការកុមារដែលកំពុងត្រូវបាន បញ្ជូនចេញពីគ្រួសារទៅរស់នៅក្នុងស្ថាប័ន ឬ "មណ្ឌលកុមារកំព្រា"។ ក្នុងករណីខ្លះ ឪពុកម្តាយនិងក្រុមគ្រួសារ ត្រូវបានគេបញ្ចុះបញ្ចូល និង/ឬ យល់ព្រមក្នុងការបញ្ជូនកូនរបស់ខ្លួនទៅកាន់ "មណ្ឌលកុមារកំព្រា" ឬស្ថាប័នសម្រាប់ឱកាសល្អប្រសើរ និងការអប់រំ។ ដោយការគិតថា កូនៗរបស់ខ្លួននឹងទទួលបាននូវជីវិតប្រសើរជាងនោះ ឪពុកម្តាយព្រមបញ្ជូនកូនៗរបស់ខ្លួន ចេញពីបរិស្ថានមួយដែលស្ថិតក្រោមការការពាររបស់ពួកគេ និងចូល ទៅក្នុងបរិស្ថាន ដែលគ្មានសុវត្ថិភាព ជាទីដែលពួកគេអាចងាយរងគ្រោះចំពោះពីរំលោភបំពាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៩ ●**<br><br> | តើការរំលោភបំពានផ្លូវភេទមានផលប៉ះពាល់អ្វីខ្លះ លើកុមារ?<br>• ការរំលោភបំពានផ្លូវភេទកុមារមានផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារ។<br>• ផលប៉ះពាល់ទាំងនេះ អាចមានលទ្ធផលអាក្រក់ទាំងរយៈពេលខ្លី និងរយៈពេលវែង<br>• ផលប៉ះពាល់លើកុមារអាចមាន៖<br>– រូបរាងកាយ (របួស ការរោគឆ្លងតាមការរួមភេទ ជំងឺឆ្លងតាមការរួមភេទ និងការប្រើប្រាស់សារធាតុញៀន។<br>– ផ្លូវចិត្ត (សុខភាពផ្លូវចិត្ត និងបញ្ហាផ្លូវចិត្តរួមមាន ធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ប៉ុនប៉ងធ្វើអត្តឃាត ធ្វើបាបខ្លួនឯង)។<br>– ស្ដីបន្ទោសជនរងគ្រោះច្រើនជាងអ្នករំលោភបំពាន។<br>– បញ្ហាសង្គម (បញ្ហានៃការទុកចិត្ត អសមត្ថភាព ក្នុងការផ្ចង់អារម្មណ៍ ឬបង្កើតទំនាក់ទំនង ពិបាកចូលចំណោម ជាមួយអ្នកដទៃ ឬទទួលបានការងារ)។<br>– ផលប៉ះពាល់រយៈពេលវែង រួមមានការធ្លាក់ទៅក្នុងវដ្ដនៃការកេងប្រវ័ញ្ច ឬ "ការងារ" ដែលមិនល្អ។<br>– ផលប៉ះពាល់ពីមួយជំនាន់ទៅមួយជំនាន់លើកុមារដែលកើតចេញពីទំនាក់ទំនងរំលោភ ឬក្រោយពីទំនាក់ទំនងរំលោភ។<br>• ផលប៉ះពាល់ នៃការរំលោភបំពាន អាចរាលដាលហួសពីជនរងគ្រោះផ្ទាល់ គឺប៉ះពាល់ដល់ក្រុមគ្រួសារ និងសហគមន៍ច្រើនជំនាន់។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | • ផលប៉ះពាល់លើគ្រួសារអាចរួមមាន៖<br>– ស្លាកស្នាមឈឺចាប់ក្នុងគ្រួសារ។<br>– ត្រូវផ្លាស់ប្តូរទីលំនៅ ឬក្រុមគ្រួសារត្រូវទទួលការរើសអើងពីសហគមន៍។<br>– បំផ្លាញកេរ្តិ៍ឈ្មោះគ្រួសារ។<br>– វប្បធម៌នៃការភ័យខ្លាច និងការមិនជឿទុកចិត្ត<br>– បន្ទុកហិរញ្ញវត្ថុកើនឡើងដោយសារតែមានភាពចាំបាច់ក្នុងការថែទាំជនរងគ្រោះពីការរំលោភបំពាន។<br>– ការធ្វើឱ្យស៊ាំនឹងការរំលោភបំពាន<br>• ផលប៉ះពាល់លើសហគមន៍អាចរួមមាន៖<br>– ខូចកេរ្តិ៍ឈ្មោះ<br>– បរិយាកាសនៃការភ័យខ្លាច<br>– ការកើនឡើងនៃបញ្ហាសង្គម។<br>– ផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច។<br>– ធ្វើឱ្យបាត់បង់វប្បធម៌ និងប្រពៃណី។<br>– ទាក់ទាញអ្នករំលោភបំពានផ្សេងទៀតចំពោះសហគមន៍។<br>• កុមារមិនគួរត្រូវបានស្តីបន្ទោសចំពោះការរំលោភបំពាន ដែលខ្លួនជួបប្រទះឡើយ ឬចំពោះការប៉ះពាល់ដល់ក្រុមគ្រួសារ និងសហគមន៍ឡើយ។ កុមារណាម្នាក់ដែលជួបប្រទះការរំលោភបំពាន គួរត្រូវទទួលការអះអាងយ៉ាងច្បាស់ថា វាមិនមែនជាកំហុសរបស់ពួកគេឡើយ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៣០**<br> | តើបច្ចេកវិជ្ជាឌីជីថល និងការរំលោភបំពានកុមារមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច?<br>*(តាមជម្រើស–អាស្រ័យលើបរិបទក្នុងស្រុក)*<br>• ជារៀងរាល់ថ្ងៃ មានការអភិវឌ្ឍន៍ផ្នែកបច្ចេកវិជ្ជាថ្មីៗដែលផ្ដល់នូវឱកាសច្រើន សម្រាប់យើងក្នុងការទទួលបានព័ត៌មាន និងការទំនាក់ទំនងជាមួយនឹងមនុស្សនៅជុំវិញពិភពលោក។<br>• ឧទាហរណ៍៖ បច្ចុប្បន្នមនុស្សមិនត្រឹមតែប្រើប្រាស់ទូរស័ព្ទដៃសម្រាប់ជជែកគ្នាប៉ុណ្ណោះទេ។ តាមរយៈទូរស័ព្ទដៃមនុស្សក៏អាចផ្ញើសារជាអក្សរ និយាយជាមួយគ្នាដោយប្រើវីដេអូ ផ្ញើរូបភាព ឬវីដេអូ ឲ្យគ្នា ប្រើប្រាស់ ប្រព័ន្ធជីភីអេស (ឧ. ផែនទី) ចូលប្រើប្រាស់អ៊ីនធើណេត និងប្រព័ន្ធផ្សេងៗជាច្រើនទៀត។<br>• អ៊ីនធើណេត គឺជាចំណែកសំខាន់មួយនៅក្នុងជីវិតរបស់មនុស្សបច្ចុប្បន្ន។ និយាយដោយខ្លី អ៊ីនធើណេតជួយឱ្យមនុស្សអាចទទួលបាន និងចែករំលែកព័ត៌មាន និងការទំនាក់ទំនងនៅទូទាំងពិភពលោកតាមរយៈបណ្ដាញកុំព្យូទ័រ។<br>• មនុស្សអាចប្រើប្រាស់អ៊ីនធើណេតតាមកុំព្យូទ័រ ទូរស័ព្ទដៃ អាយផេត និងតាប្លេត ឬឧបករណ៍យកតាមខ្លួនបានផ្សេងទៀត។ នៅពេលដែលមនុស្ស កំពុងប្រើអ៊ីនធើណេត ឬកំពុង“ នៅលើគេហទំព័រ” គឺគេអាចធ្វើសកម្មភាពបានច្រើនបែប រួមមាន៖ ចូលទៅគេហទំព័រណាមួយ ឬបង្ហោះព័ត៌មាន រូបភាព ឬវីដេអូ មើល ឬផ្ញើអ៊ីម៉ែល ផ្ញើសារភ្លាមៗ ឬជជែកជាមួយអ្នកផ្សេងក្នុងបណ្ដាញទំនាក់ទំនងសង្គម (ឧទាហរណ៍៖ បង្កើតទំនាក់ទំនងមិត្តភក្តិ និងទាក់ទង(ផ្លូវស្នេហា) តាមរយៈហ្វេសប៊ុក) លេងហ្គេមលើអ៊ីនធើណេត។<br>• ដូច្នេះ នៅពេលដែលយើងនិយាយពី “បច្ចេកវិជ្ជាឌីជីថល” គឺយើងកំពុងនិយាយអំពីឧបករណ៍ ម៉ាស៊ីន និងប្រព័ន្ធទាំងនេះ ទាំងដោយរូបវ័ន្ត និងតាមរយៈការប៉ះពាល់ដោយភ្នែក។ | អាស្រ័យលើបរិបទក្នុងមូលដ្ឋាន អ្នកសម្របសម្រួលអាចសម្រេចចិត្តលើប្រធានបទនេះ ថាគួរឬមិនគួរដាក់បញ្ចូលក្នុងការពិភាក្សា។ វាអាចគ្រប់គ្រាន់ដោយគ្រាន់តែការផ្ដល់ឯកសារ យោង ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធជាមួយនឹង បច្ចេកវិជ្ជាឌីជីថល នៅក្នុងផ្នែកផ្សេងទៀត នៃការពិភាក្សា។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣១**<br> | តើគ្រោះថ្នាក់អ្វីខ្លះដែលអាចកើតចេញពីបច្ចេកវិជ្ជាឌីជីថល? *(តាមជម្រើសអាស្រ័យលើបរិបទក្នុងប្រទេស)*<br>• ជាមួយនឹងបរិបទផ្លូវកាយ ក្នុងករណីដែលកុមារមានការទាក់ទងគ្នាជាមួយនឹងមនុស្សពេញវ័យ ពិភពឌីជីថលគឺជាបរិយាកាស មួយផ្សេងទៀតដែលកុមារអាចមានលទ្ធភាពខ្ពស់ក្នុងការទំនាក់ទំនងជាមួយមនុស្សដែល ពួកគមេិនស្គាល់ រាប់បញ្ចូលទាំងកុមារ និងមនុស្សពេញវ័យផ្សេងទៀត។<br>• បច្ចេកវិជ្ជាឌីជីថល ចាប់ផ្តើមមានសារៈសំខាន់ កាន់តែខ្លាំងឡើងៗ សម្រាប់មនុស្សជំនាន់ថ្មីៗ។ វាមានសារៈសំខាន់ណាស់សម្រាប់កុមារដែលត្រូវស្គាល់ពីបច្ចេកវិជ្ជានេះ ដើម្បីរៀបចំខ្លួនគេសម្រាប់ពេលដែលគេពេញវ័យ ជាពេលដែលគេអាចនឹងត្រូវប្រើប្រាស់ បច្ចេកវិជ្ជាទាំងនេះសម្រាប់ការងារ និងការរស់នៅរបស់ពួកគេ។ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលត្រូវយល់ពីអត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលវាអាចកើតឡើង។<br>• បច្ចេកវិជ្ជាឌីជីថលផ្តល់ឱកាសវិជ្ជមានជាច្រើនសម្រាប់ពួកយើង និងកូនៗរបស់យើង ក៏ប៉ុន្តែនៅក្នុង "បរិយាកាស" ថ្មីណា មួយក៏ដោយ យើងចាំបាច់ត្រូវធានាថាកូនៗ របស់យើងដឹងពីរបៀបប្រព្រឹត្តិអាកប្បកិរិយា ដឹងអំពីគ្រោះថ្នាក់ និងដឹងពីរបៀប ដែលពួកគេអាចការពារខ្លួនគេពីគ្រោះថ្នាក់ទាំងនេះ រួមទាំងការរំលោភបំពានផ្លូវភេទកុមារផងដែរ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | ? *សំណួរឆ្លុះបញ្ចាំង/ពិចារណា (តាមជម្រើស)*<br><br>សុំឱ្យអ្នកចូលរួមគិតពីគ្រោះថ្នាក់ចំពោះសុវត្ថិភាពកុមារដែលអាចកើតចេញពីបច្ចេកវិជ្ជាឌីជីថល។ | ចម្លើយអាចឆ្លើយបាន ទៅនឹងសំណួរអំពីគ្រោះថ្នាក់ដែលអាចកើតចេញពី បច្ចេកវិជ្ជាឌីជីថលរួមមាន ៖<br>• នៅពេលដែលយើងចែករំលែកព័ត៌មាន/រូបភាពតាមប្រព័ន្ធអ៊ីនធើណេត គឺយើងមិនអាចលុបវាចេញវិញបានទេ។<br>• កុមារអ្នកចែករំលែកព័ត៌មានផ្ទាល់ខ្លួនជាមួយមនុស្សដែលគេមិនស្គាល់តាមរយៈបច្ចេកវិជ្ជាឌីជីថល។<br>• កុមារអាចក្លាយខ្លួនជាមិត្តភក្តិ ជាមួយមនុស្សដែលគេមិនស្គាល់ តាមរយៈបច្ចេកវិជ្ជាឌីជីថលនេះ  ហើយរៀបចំការជួបជាមួយនឹង មនុស្សទាំងនេះ។<br>• អ្នករំលោភបំពានអាចប្រើប្រាស់បច្ចេកវិជ្ជាឌីជីថលដើម្បីលួងលោមកុមារ។<br>• អ្នករំលោភបំពានជាមនុស្សពេញវ័យខ្លះធ្វើពុតថាខ្លួនជាក្មេង ដើម្បីបង្កើតទំនាក់ទំនង ហើយបន្ទាប់មកបោកបញ្ឆោតជនរងគ្រោះរបស់ខ្លួន ហើយធ្វើការស្នើសុំរួមភេទតែម្តង។<br>• រូបភាពផ្លូវភេទត្រូវបានចែករំលែកគ្នាតាមបច្ចេកវិជ្ជាឌីជីថលដើម្បីកំណត់ទីតាំង និងព័ត៌មានលម្អិតរបស់កុមារ។<br>• អ្នករំលោភបំពានប្រើប្រាស់បច្ចេកវិជ្ជាឌីជីថល ដើម្បីរក្សាទំនាក់ទំនងជាមួយកុមារ និង រៀបចំការជួបជាមួយកុមារដែលជាជនរងគ្រោះ។<br>• អ្នករំលោភបំពាន ប្រើប្រាស់ហ្គេមតាមអ៊ីនធើណេត ដើម្បីកំណត់គោលដៅកុមារទុក និង បង្កើតទំនាក់ទំនងសម្រាប់ការរំលោភបំពានផ្លូវភេទ នៅពេលក្រោយ។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr>
<td>

**ស្លាយទី៣២**




</td>
<td>

*តើឪពុកម្ដាយ និងអ្នកថែទាំត្រូវឆ្លើយតបយ៉ាងដូចម្ដេច ទៅនឹងគ្រោះថ្នាក់ដែលកើតចេញពីបច្ចេកវិជ្ជាឌីជីថលនេះ? (តាមជម្រើសអាស្រ័យលើបរិបទក្នុងប្រទេស)*

- មនុស្សពេញវ័យជាច្រើននិយាយថា ពិភពឌីជីថលរីកចម្រើនលឿនខ្លាំងពេក ដែលធ្វើឲ្យពួកគេមិនអាចតាមទាន់។
- មានវិធានការមួយចំនួនដែលមនុស្សពេញវ័យអាចអនុវត្ត ដើម្បីពង្រឹងសុវត្ថិភាពរបស់កុមារនៅពេលដែលពួកគេប្រើប្រាស់បច្ចេកវិជ្ជាដូចជាកុំព្យូទ័រ តាប្លេត និង/ឬ ទូរស័ព្ទដៃ។
- ជួយឱ្យកុមារយល់ថា ដូចគ្នានឹងការជួបជជែកផ្ទាល់មុខនឹងគ្នានោះ យើងក៏អាចរក្សាសុវត្ថិភាពរបស់យើង នៅពេលដែលយើងមានទំនាក់ទំនងតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាឌីជីថលផងដែរ។ ឧទាហរណ៍៖
  - ផ្ដល់យោបល់ដល់កុមារកុំឱ្យចែករំលែកព័ត៌មានលម្អិតរបស់ខ្លួន (ដូចជាលេខទូរសព្ទ អាសយដ្ឋាន ឈ្មោះសាលារៀនជាដើម) ឬរូបភាពផ្ទាល់ខ្លួនតាមរយៈបច្ចេកវិជ្ជាឌីជីថល។
  - គ្រប់ព័ត៌មានទាក់ទងនឹងប្រវត្តិទាំងអស់គួរ មានការកំណត់ពីភាពឯកជនឱ្យបានខ្ពស់បំផុត ហើយគ្រប់ព័ត៌មានទាំងអស់មិនត្រូវឱ្យអ្នកក្រៅចូលទៅមើលបានទេ។

- បង្រៀនកុមារអំពីការរាយការណ៍តាមបណ្ដាញអ៊ីនធើណេត។ មានគេហទំព័រ និងកម្មវិធីជាច្រើន (ឧ.ហ្វេសប៊ុក ធ្វីតធើ យូធូប អ៊ីនស្តាក្រាម ស្កាយ) ផ្ដល់នូវមធ្យោបាយងាយស្រួល ក្នុងការរាយការណ៍ពីអ្នកប្រើប្រាស់ ឬឯកសារដែលមានការរំលោភបំពាន។
- លើកទឹកចិត្តឱ្យកុមារប្រាប់អ្នកប្រសិនបើពួកគេមានអារម្មណ៍ថា ពួកគេមិនស្រួលក្នុងចិត្តនៅក្នុងទំនាក់ទំនងរបស់គេតាមបច្ចេកវិជ្ជានេះ។
- រំលឹកដល់កុមារថា ពួកគេគួរគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់គេ និងអ្វីដែលគេបានឃើញនៅតាមប្រព័ន្ធអ៊ីនធើណេត។

</td>
<td>

ប្រសិនបើកុមារម្នាក់ត្រូវបានទាក់ទងតាមរយៈបច្ចេកវិជ្ជាឌីជីថលដោយបុគ្គលណាម្នាក់ដែលធ្វើឱ្យគេមានក្ដីបារម្ភ ឬខូចចិត្ត នោះគឺគេអាចរាយការណ៍ដោយផ្ទាល់ពីវិបសាយ ឬកម្មវិធីដែលទំនាក់ទំនងរំលោភបំពាន ត្រូវបានធ្វើឡើងតាមរយៈកម្មវិធី/វិបសាយនោះ។ ឧទាហរណ៍៖

- http://www.facebook.com/help/reportlinks
- https://support.twitter.com/forms/abusiveuser
- http://www.youtube.com/yt/policyandsafety/reporting.html
- http://help.instagram.com/165828726894770
- https://support.skype.com/en/faq/FA10001/how-do-i-report-abuse-by-someone-in-skype?

</td>
</tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣៣** ●   | តើវិស័យទេសចរណ៍ និងការរំលោភបំពានលើកុមារ មានទំនាក់ទំនងគ្នាដូចម្ដេច?<br>• វិស័យទេសចរណ៍មានការរីកចម្រើននៅជុំវិញពិភពលោក និងនៅក្នុងតំបន់នេះ។<br>• កំណើនវិស័យទេសចរណ៍អាចនាំមកនូវផលប្រយោជន៍ជាច្រើនចំពោះប្រទេស និងសហគមន៍។<br>• អ្នកទេសចរភាគច្រើន គឺជាអ្នកធ្វើដំណើរដែលមានការទទួលខុសត្រូវ និងគោរពចំពោះវប្បធម៌ និងបរិស្ថានក្នុងស្រុក និងប្រជាជននៅពេលដែលគេធ្វើដំណើរ ឬរស់នៅក្នុងប្រទេសនោះមួយរយៈពេល។<br>• ប៉ុន្តែមានគ្រោះថ្នាក់មួយចំនួនចំពោះកុមារដែលប្រឈមនឹងចំនួនអ្នកទេសចរដែលការកើនឡើងជាលំដាប់ និងការអភិវឌ្ឍន៍វិស័យទេសចរណ៍។ | |
| **ស្លាយទី៣៤**   | ❓ *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា (តាមជម្រើស)*<br>សូមឱ្យអ្នកចូលរួមគិតពីគ្រោះថ្នាក់មួយចំនួនដែលអាចកើតមានចំពោះសុវត្ថិភាពកុមារដែល ប្រឈមដោយសារកំណើនទេសចរណ៍នៅក្នុងសហគមន៍។ | ការឆ្លើយតបដែលអាចកើតមានរួមមាន ៖<br>• ការដាក់មនុស្ស និងវប្បធម៌ ខុសគ្នាឲ្យនៅជិតគ្នាអាចនាំឲ្យមានជម្លោះ ការរំលោភបំពានអំណាច និង/ឬប្រាក់<br>• កុមារប្រឈមមុខនឹងផលប៉ះពាល់ពីការផ្សាយពាណិជ្ជកម្មមិនល្អ។<br>• កុមារអាចនឹងត្រូវបានប្រើប្រាស់ដើម្បីឱ្យរកប្រាក់ពីវិស័យ ទេសចរណ៍ ដោយការសុំទាន ឬដើរលក់របស់របរ តាមដងផ្លូវ។ ដោយការរស់នៅ និងធ្វើការងារនៅតាមដងផ្លូវ កុមារអាចងាយរងគ្រោះចំពោះការរំលោភបំពាន។<br>• អ្នកទេសចរអាចស្វែងរកវិធីផ្សេងៗ ដើម្បីទៅទស្សនាកន្លែងដែលមានការហាមប្រាមចំពោះមនុស្សពេញវ័យ ដូចជា "មណ្ឌលកុមាកំព្រា" សាលារៀនផ្ទះជាដើម ។ ការទុក ឱ្យមនុស្សពេញវ័យដែលមិនស្គាល់នៅជាមួយ នឹងកុមារអាចនាំឱ្យកុមារប្រឈមនឹងភាពងាយរងគ្រោះនៃការរំលោភបំពាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| | | • "កន្លែងកំសាន្តពេលយប់" ឬកន្លែងធ្វើអាជីវកម្មផ្លូវភេទ អាចបង្កើនតម្រូវការកើនឡើងចំពោះភ្ញៀវទេសចរ។ កុមារអាចត្រូវបានលួងលោម ឬត្រូវបានរំលោភបំពាននៅនឹងកន្លែងទាំងនេះតែម្តង។<br>• ឪពុកម្តាយ និងអ្នកថែទាំ អាចយល់ព្រមឱ្យភ្ញៀវទេសចរជាបរទេសចូលទៅផ្ទះ ឬអប់រំកូនរបស់ខ្លួន ឬយកកូនរបស់ខ្លួន ចេញពីផ្ទះ ដែលជាទីកន្លែងផ្តល់ការការពារ ដល់ពួកគេ ដែលអាចធ្វើឱ្យពួកគេប្រឈមនឹងភាពងាយរងគ្រោះពីការរំលោភបំពាន។ |
| **ស្លាយទី៣៥**   | • អ្នកទេសចរមួយចំនួនតូចប្រើប្រាស់ការធ្វើដំណើរ ជាឱកាសក្នុងការរំលោភបំពានផ្លូវភេទកុមារ។<br>• អ្នករំលោភបំពានផ្លូវភេទលើកុមារដែលផ្លាស់ទី ពីកន្លែងមួយទៅកន្លែងមួយទៀត គឺជាអ្នកទេសចរ អ្នកធ្វើដំណើរ ឬជនបរទេស ដែលតាំងទីលំនៅក្នុងប្រទេស ដែលពួកគេធ្វើការរំលោភបំពានផ្លូវភេទកុមារ ទាំងនៅក្នុងប្រទេស ឬប្រទេសផ្សេងៗ ដែលកំពុងទស្សនា និងរស់នៅ។<br>• ខណៈពេលដែលវិស័យទេសចរណ៍បាននាំមកនូវផលប្រយោជន៍ជាវិជ្ជមានដល់ប្រទេសនិង សហគមន៍របស់យើង វាគឺជាការសំខាន់ដែលពួកយើងដឹងពីគ្រោះថ្នាក់ដែលពួកយើងការពារកុមាររបស់យើងពីការរំលោភបំពានផ្លូវភេទដោយអ្នកទេសចរនិងនិងប្រជាជនក្នុងមូលដ្ឋាន ។<br>• ព័ត៌មានដែលយើងបានចែករំលែករួចហើយអំពីអ្នករំលោភបំពានផ្លូវភេទលើកុមារ គឺមាន ការពាក់ព័ន្ធជាមួយនឹងអ្នកដំណើរ ដែល រំលោភបំពានផ្លូវភេទលើកុមារ ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| ស្លាយទី៣៦ ●<br> | • ដូចដែលបានពិភាក្សាខាងដើម អ្នករំលោភបំពានផ្លូវភេទកុមារ ធ្វើសកម្មភាព ក្នុងមធ្យោបាយជាច្រើន។ នេះគឺដូចគ្នានឹង ជនល្មើស ដែលរំលោភបំពាន ផ្លូវភេទកុមារផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀតដែរ។<br>• នៅក្នុងបរិបទជាក់លាក់នៃវិស័យទេសចរណ៍និងការធ្វើដំណើរ៖<br>– អ្នករំលោភបំពានបានរៀបចំទុកជាមុន ដើម្បីប៉ុនប៉ងរំលោភបំពានលើកុមារ ក្នុងតំបន់ណាមួយជាក់លាក់។<br>– អ្នករំលោភបំពានមួយចំនួនបានយកពេលវេលាលំហែ ដើម្បីរំលោភបំពានលើកុមារ។<br>– អ្នករំលោភបំពានមួយចំនួនដែលធ្វើដំណើរទៅក្រៅប្រទេស ដើម្បីទៅកាន់ទីកន្លែងដែលត្រូវបានរាយការណ៍ថាកុមារ គឺអាចដើម្បីរំលោភបំពានផ្លូវភេទបាន។<br>– អ្នករំលោភបំពានមួយចំនួន អាចនឹងទៅទស្សនាជាទៀងទាត់ នៅក្នុងប្រទេសមួយ និងស្នាក់នៅម្ដងៗ ច្រើនខែឬច្រើនឆ្នាំ។ ក្នុងករណីនេះ ពួកគេភាគច្រើនមិនមែនជាទេសចរទៀតទេ ប៉ុន្តែរស់នៅ ដូចជាជនបរទេសដែលមានផ្ទះឬផ្ទះល្វែងផ្ទាល់ខ្លួន ។<br>– អ្នករំលោភបំពានខ្លះប្រើប្រាស់ បច្ចេកវិជ្ជាឌីជីថលដើម្បីរំលោភបំពានលើកុមារនៅក្នុងប្រទេសផ្សេង (ឧ. តាមរយៈការប្រើប្រាស់ "វេបខែម")។<br>– អ្នករំលោភបំពានខ្លះទៀតធ្វើការងារជាគ្រូបង្រៀន ឬវេជ្ជបណ្ឌិតស្ម័គ្រចិត្តនៅក្នុងប្រទេសក្រៅ ហើយរំលោភបំពានកុមារដែលគេបានជួបតាមរយៈការងាររបស់គេនៅក្នុងអង្គការសប្បុរសធម៌ "មណ្ឌលកុមារកំព្រា" សាលារៀន គ្លីនិកសុខភាពជាដើម។<br>– អ្នករំលោភបំពានខ្លះ នឹងប្រើប្រាស់ឈ្មួញកណ្ដាល និងបណ្ដាញនានា ដើម្បីជួយដល់ខ្លួនក្នុងការស្វែងរក និងរំលោភបំពានកុមារ។ ដូចដែលបានលើកឡើង មានមនុស្សច្រើនដែលអាចជួយដល់អ្នករំលោភបំពានក្នុងការជួប និងរំលោភបំពានលើកុមារ។ | អ្នកសម្របសម្រួលអាចរៀបរាប់លម្អិត ជាមួយនឹង ព័ត៌មានពីករណីសិក្សាក្នុងមូលដ្ឋាន/ប្រទេស/អន្តរជាតិ។ ឧទាហរណ៍មួយចំនួនរួមមាន៖ វាក៏មានសារៈសំខាន់ណាស់ដែលត្រូវនិយាយសង្កត់ធ្ងន់ថា នៅក្នុងសហគមន៍ណាមួយ អ្នករំលោភបំពានភាគច្រើនគឺជាអ្នកដែលនៅក្នុងមូលដ្ឋាននោះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **២. តើយើងអាចនិយាយជាមួយកូនរបស់យើងពីការរក្សាសុវត្ថិភាពដោយរបៀបណា ?** | | |
| **ស្លាយទី៣៧** •<br><br> | • តាមរយៈការឃ្លាំមើល និងយល់ដឹង ឪពុកម្តាយ និងអ្នកថែទាំអាចកាត់បន្ថយគ្រោះថ្នាក់នៃការរំលោភបំពានលើកុមារ។<br>• តាមរយៈការដឹង និងការចាប់អារម្មណ៍លើគ្រប់ទំនាក់ទំនងទាំងអស់ ដែលកូនៗរបស់ អ្នកមានជាមួយនឹងមនុស្សពេញវ័យ អ្នកអាច ជួយបង្កើនកម្រិតការពារបានមួយកម្រិតទៀតសម្រាប់កូនរបស់អ្នក។<br>• អ្នករំលោភបំពានអាចកំណត់គោលដៅកុមារដែលគេមិនយកចិត្តទុកដាក់ ឬកុមារដែលមានបញ្ហាជាមួយគ្រួសារពួកគេ។<br>• សូម្បីតែកុមារដែលមកពីគ្រួសារដែលមានការស្រលាញ់និងផ្តល់ការគាំទ្រក៏ដោយ ក៏កុមារទាំងអស់នោះនៅតែអាចទទួលរងគ្រោះថ្នាក់ដែរ។<br>• មធ្យោបាយសំខាន់ជាគន្លឹះមួយទៀតដែលយើងអាចប្រើដើម្បីការពារកុមាររបស់យើង ឲ្យបានកាន់តែប្រសើរឡើង គឺការទំនាក់ទំនង ដោយបើកចំហនិងពិភាក្សាជាមួយកុមារា និងកុមារីតាំងពីនៅក្មេង ពីការរក្សាសុវត្ថិភាពរបស់ពួកគេ។<br>• វាមានសារៈសំខាន់ស្មើគ្នា ក្នុងការដែលត្រូវមានការសន្ទនាទាំងនេះជាមួយនឹងកូនស្រីនិងកូនប្រុសរបស់យើងដែលសុទ្ធតែងាយរងគ្រោះចំពោះការរំលោភបំពាន។<br>• ឧទាហរណ៍ នៅក្នុងវគ្គអប់រំរបស់យើងជាមួយកុមារ យើងលើកទឹកចិត្តដល់កុមារឱ្យកំណត់ "មនុស្សពេញវ័យដែលគួរឲ្យទុកចិត្ត" ដែលពួកគេអាចនិយាយជាមួយបាន ក្នុងករណីដែលពួកគេមានអារម្មណ៍ថា "ពួកគេមានបញ្ហា"។<br>• កុមារគួរមានលទ្ធភាពអាចមករកនិងចែករំលែកអារម្មណ៍របស់គេជាមួយនឹងអ្នកដោយ មិនមានការភ័យខ្លាចលើការស្តីបន្ទោសឡើយ។<br>• ពេលខ្លះ កុមារមិនចែករំលែកអ្វីដែលមានសារៈសំខាន់ជាមួយនឹងឪពុកម្តាយរបស់គេទេ ពីព្រោះពួកគេភ័យខ្លាចថានឹងទទួល ការស្តីបន្ទោស។ អ្នករំលោភបំពានប្រើប្រាស់ភាពភ័យខ្លាចនេះ ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ។ | វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា អ្នករំលោភបំពានផ្លូវភេទលើកុមារខ្លះចំណាយការខិតខំប្រឹងប្រែងច្រើនដើម្បីយកលេស ឬធ្វើឱ្យសមហេតុសមផលសម្រាប់អាកប្បកិរិយារបស់ខ្លួនដោយប្រាប់អ្នកដទៃថា "វាគឺជាឧប្បត្តិហេតុ" ឬថា "កុមារនិយាយបំផ្លើស" ស្ថានភាព។ អ្នករំលោភបំពានខ្លះ សង្កត់ធ្ងន់ថា កុមារនិយាយកុហកពីអ្វីដែលកើតឡើងពីមុន ឬគឺ "អ្នកបង្ករឿង" ឬជាការយល់ច្រឡំរឿងផ្លូវភេទ។ ការធ្វើបែបនេះគឺធ្វើឱ្យអាប់អោនដល់ចរិតលក្ខណៈ និងភាពអាចជឿទុកចិត្តបាននៃកុមាររងគ្រោះ។ នោះគឺជាហេតុផលដែលមានសារៈសំខាន់ ដែលត្រូវជានាចំពោះកូនរបស់អ្នក ថាអ្នកស្តាប់ពួកគេ និងជឿជាក់លើអ្វីដែលពួកគេបានប្រាប់អ្នក។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr>
<td>

**ស្លាយទី៣៨ •**




</td>
<td>

សំណួរឆ្លុះបញ្ចាំង/ពិភាក្សា

• សូមសួរអ្នកចូលរួម តើពួកគេបង្រៀនអ្វីខ្លះដល់កូនរបស់គេ ទាក់ទងនឹងការថែរក្សាសុវត្ថិភាពកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ? តើសារសំខាន់ៗផ្នែកសុវត្ថិភាព និងយុទ្ធសាស្ត្រការពារខ្លួនអ្វីខ្លះដែលពួកគេលើកទឹកចិត្តកុមារឲ្យអនុវត្ត?

</td>
<td>

អ្នកសម្របសម្រួលអាចកត់ត្រាចម្លើយ របស់អ្នកចូលរួមដែលលើកឡើងនូវការអនុវត្តន៍ល្អៗ និង ដាក់បញ្ចូលទៅក្នុងវេទិកាពិភាក្សានៅពេលក្រោយទៀត។

អ្នកសម្របសម្រួលគួរមានការប្រុងប្រយ័ត្ន និងបញ្ជាក់ឱ្យច្បាស់លាស់ និងកែតម្រូវដោយទន់ភ្លន់លើគោលគំនិត ឬយុទ្ធសាស្ត្រនានាដែលជាអបិយជំនឿ។ អ្នកសម្របសម្រួលត្រូវសង្កត់ធ្ងន់ថា អ្នករំលោភបំពានទាញយកអត្ថប្រយោជន៍ពីការយល់មិនត្រឹមត្រូវទាំងនេះដើម្បីបានឱកាសជួបនិងការរំលោភលើកុមារ។

</td>
</tr>
<tr>
<td>

**ស្លាយទី៣៩ •**




</td>
<td>

- ជាទូទៅ ក្នុងពេលណាមួយនៃជីវិតរបស់ពួកគេ កុមារតែងចាប់ផ្តើមឆ្ងល់អំពីការរួមភេទ ហើយពួកគេយល់ថា នេះគឺជាប្រធានបទដែលត្រូវហាមឃាត់មិនឲ្យនិយាយ។
- ជួនកាល ភាពងឿងឆ្ងល់របស់ពួកគេ នាំឱ្យកុមារស្វែងរក និងចែករំលែកព័ត៌មានមិនត្រឹមត្រូវពីការរួមភេទដែលពួកគេទទួលបាន ពីគ្នាទៅវិញទៅមក ឬតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាអីនធើណេត។
- ការសន្ទនាជាមួយកូនរបស់យើងពីបញ្ហាផ្លូវភេទគឺជារឿងលំបាក។ ប៉ុន្តែ ប្រសិនបើយើងនៅស្ងាត់ស្ងៀម កូនៗរបស់យើងនឹងប្រឈមជាមួយនឹងគ្រោះថ្នាក់។
- កុមារនឹងរៀនសូត្រពីរឿងផ្លូវភេទ ទោះបីជាយើងចង់ឬមិនចង់ឲ្យពួកគេដឹងក៏ដោយ។ កុមារនឹងស្វែងរកព័ត៌មានពីប្រភពដទៃទៀត ហើយព័ត៌មានដែលពួកគេទទួលបាន អាចជាព័ត៌មានមិនត្រឹមត្រូវឬមានគ្រោះថ្នាក់។ ពេលខ្លះ អ្នករំលោភបំពានជាមនុស្សពេញវ័យកេងយកប្រយោជន៍ពីកុមារ ដែលមិនបានយល់ច្បាស់ពីបញ្ហាផ្លូវភេទ។
- យើងត្រូវតែបង្កើតឱកាសសមស្រប ដើម្បីនិយាយជាមួយកូនៗរបស់យើង ទាំងកូនប្រុស និងកូនស្រី។

</td>
<td>

សូមមើល **កាតយកតាមខ្លួន (តើខ្ញុំអាចរក្សាសុវត្ថិភាពរបស់កូនខ្ញុំបានយ៉ាងដូចម្តេច?**




ការស្រាវជ្រាវមួយបានបង្ហាញថា ពេលខ្លះគុណតម្លៃ បានរារាំងឪពុកម្តាយ កូនជាពិសេសកុមារី មិនឱ្យសិក្សាស្វែងយល់ និងពិភាក្សាពីភាពគ្រប់ការ ផ្លូវភេទ និងការ រួមភេទ។ ព័ត៌មានមានកម្រិតពីរឿងផ្លូវភេទ និងអាកប្ប-កិរិយាបែបការពារអាចរួមចំណែកដល់ភាពងាយរងគ្រោះរបស់កុមារចំពោះការរំលោភបំពាន។

</td>
</tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
| --- | --- | --- |
| | • ជាការពិតណាស់ របៀបនិយាយទៅកាន់កុមារអាយុបីឆ្នាំ ពីបញ្ហានេះ គឺច្បាស់ជាខុសពីរបៀបដែលយើងនិយាយជាមួយកុមារអាយុ១៧ឆ្នាំ។ ប៉ុន្តែ យើងអាចមានការសន្ទនាដែលសមស្របទៅតាមអាយុ និងការវិវឌ្ឍន៍របស់កុមារបាន។<br>• នេះជាមូលហេតុដែលយើងក៏ត្រូវតែលើកទឹកចិត្តឱ្យសាលារៀនផ្តល់ការអប់រំផ្លូវភេទដល់កុមារ។<br>• ក្នុងនាមជាឪពុកម្តាយ យើងត្រូវតែប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវរបស់យើងក្នុងការផ្តល់ការអប់រំក្រៅផ្លូវការពីបញ្ហាផ្លូវភេទ នៅផ្ទះ។<br>• ឥឡូវនេះ យើងនឹងចែករំលែកគំនិតមួយចំនួនពីរបៀបនិយាយជាមួយកុមារលើប្រធានបទទាំងនេះ ដោយផ្តែកលើការស្រាវជ្រាវ និងបទពិសោធន៍អន្តរជាតិ។ | |
| ស្លាយទី៤០ •<br><br> | *គន្លឹះទី១៖ កសាងទំនាក់ទំនងដោយបើកចំហ និងទុកចិត្តគ្នាជាមួយកូនអ្នក។*<br>• លើកទឹកចិត្តកូនអ្នកឱ្យនិយាយជាមួយអ្នកពីបញ្ហានោះ។ ជារឿយៗ ការលើកទឹកចិត្តឱ្យកូននិយាយចេញច្រើនតែចាប់ផ្តើមដោយការសួរថា តើកូនសុខសប្បាយទេ? តើមានអ្វី ដែលកូនចង់និយាយជាមួយពួក យើងឬទេ?<br>• ការកសាងទំនាក់ទំនងដោយបើកចំហ គឺមានភាពចាំបាច់ណាស់ ដើម្បីឱ្យកូនអ្នកមានអារម្មណ៍ងាយស្រួល ក្នុងការចែករំលែកទុក្ខកង្វល់របស់ពួកគេ ជាមួយអ្នក។<br>• នៅពេលកុមារនិយាយចេញមក សូមស្តាប់ និងឆ្លើយតបទៅពួកគេវិញ ដោយយកចិត្តទុកដាក់។<br>• សូមឱ្យពួកគេដឹងថា ប្រសិនបើពួកគេចង់ចែករំលែករឿងអ្វីមួយជាមួយអ្នក គឺគេអាចធ្វើបាន ហើយគេមិនគួរមានការភ័យខ្លាចដល់ការដាក់ទោសទេ។ | មានករណីដែលកុមារមិននិយាយពីការរំលោភបំពាន ប្រាប់ឪពុកម្តាយរបស់ខ្លួន ព្រោះពួកគេខ្លាចទទួលរងការស្តីបន្ទោស ដែលពួកគេបានទៅកន្លែងណាមួយដែលពួកគេមិនគួរទៅ។ ប្រសិនបើអាចធ្វើបាន អ្នកសម្របសម្រួលគួររកករណីសិក្សា ដើម្បីយកមកចែក រំលែកជាមួយអ្នកចូលរួម។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤១** ●<br> | *គន្លឹះទី២៖ និយាយជាមួយកូនអ្នកអំពីភេទ និងបញ្ហាផ្លូវភេទ តាមវិធីមួយដែលសមស្រប នឹងវ័យរបស់ពួកគេ។*<br>• ចំណុចនេះ រួមមានទាំងការពិភាក្សាពីការផ្លាស់ប្ដូរផ្នែករាងកាយ សុខភាពផ្លូវភេទ និងទំនាក់ទំនងជាវិជ្ជមាន។<br>• នៅពេលឪពុកម្ដាយចែករំលែកព័ត៌មានទាំងនេះ វាអាចជួយទប់ស្កាត់កុំឱ្យមានការទទួលព័ត៌មានខុស។ យើងដឹងថាជនល្មើសកេងយកប្រយោជន៍ពីការទទួលបានព័ត៌មានខុសទាំងនេះ ដើម្បីមានលទ្ធភាពចូលទៅរកកុមារ។<br>• ជាការពិតណាស់ ឪពុកម្ដាយជាច្រើនមានអារម្មណ៍មិនស្រួល ឬអៀនខ្មាសក្នុងការនិយាយអំពីបញ្ហាផ្លូវភេទ ប៉ុន្តែមានវិធីជាច្រើនដែលធ្វើឱ្យការនិយាយនេះ មានភាពងាយស្រួល។ ការនិយាយនេះ នឹងមិនសូវអាក្រក់ប៉ុន្មានទេ ប្រសិនបើអ្នកលើកយកប្រធានបទនេះមកនិយាយពេលកូនរបស់អ្នកនៅតូច ហើយឆ្លើយនឹងសំណួរផ្សេងៗតាមលក្ខណៈធម្មតា។<br>• ត្រូវចងចាំថា វាក៏អាចជាការអាម៉ាស់ និងធ្វើឱ្យមានការពិបាកសម្រាប់កុមារក្នុងការនិយាយពីរឿងនេះផងដែរ។ | ការស្រាវជ្រាវអន្តរជាតិមួយបានលើកឡើងពីព័ត៌មានខាងក្រោមទៅតាមអាយុសមស្រប៖<br>**អាយុ០-៣ ឆ្នាំ**<br>• បង្រៀនកូនអំពីឈ្មោះដែលត្រឹមត្រូវរបស់ផ្នែកផ្សេងៗនៃរាងកាយ រួមទាំងអវៈយវៈភេទផងដែរ។<br>• ចាប់ផ្ដើមបង្រៀនអំពីភាពខុសគ្នារវាងសាធារណៈ និងឯកជន<br>• បើកចំហ ចំពោះសំណួរនានា ជាពិសេសគឺសំណួរជុំវិញរឿងភាពខុសគ្នា។<br>**អាយុ៤-៥ឆ្នាំ**<br>• ពន្យល់ពីមុខងារខុសៗគ្នា របស់ផ្នែកផ្សេងៗនៃរាងកាយ រួមទាំងមុខងាររបស់អវៈយវៈភេទផងដែរ។<br>• ព័ត៌មានលម្អិតបន្ថែមទៀត (ច្បាប់ទម្លាប់ ប្រសិនបើអ្នកចង់បាន) ពីការប៉ះពាល់ខ្លួនឯង និងប៉ះពាល់អ្នកដទៃដែលសមរម្យ និងមិនសមរម្យ ព្រមទាំងការប៉ះពាល់ និងការនិយាយជាឯកជន និងជាសាធារណៈ។<br>• ផ្ដល់ព័ត៌មានអំពីយេនឌ័រ និងសង្គម (ហេតុអ្វី បានជាពេលខ្លះគេដាក់កុមារីឱ្យដាច់ពី កុមារា តើហេតុអ្វីបានជា ជារឿយៗមានការប្រព្រឹត្តិខុសគ្នាទៅលើកុមារា និងកុមារី?)<br>**អាយុ៥-៨ឆ្នាំ**<br>• កុមារគួរមានចំណេះដឹងជាមូលដ្ឋានអំពីការបន្តពូជ។<br>• ត្រូវផ្ដល់ព័ត៌មានអំពីការពេញវ័យ (ការផ្លាស់ប្ដូរផ្នែករាងកាយ ការចេញទឹកកាម ការឡើងរឹងនៃប្រដាប់ភេទ ការមករដូវ)។<br>• ពន្យល់អំពីទំនោរ និងអត្តសញ្ញាណផ្លូវភេទ<br>• ប្រសិនបើកុមារសួរ អ្នកគួរមានឆន្ទៈផ្ដល់ព័ត៌មានត្រឹមត្រូវអំពីទង្វើផ្នែកផ្លូវភេទ ដោយផ្ដល់ព័ត៌មានលម្អិតតិចតួច។<br>**អាយុ៩-១២ឆ្នាំ**<br>• ព័ត៌មានលម្អិតអំពីភេទ រួមទាំងការរួមភេទដោយសុវត្ថិភាព និងរបៀបសម្រេចចិត្តថាតើពេលណាគួរចាប់ផ្ដើមមានរឿងផ្លូវភេទជាមួយអ្នកដទៃ។<br>• ព័ត៌មានអំពីភាពកៀកកិតនិងការរួមភេទក្នុងទំនាក់ទំនង(ស្នេហា)។<br>• គាំទ្រចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងថា តើសារអំពីភេទនិងយេនឌ័រនៅក្នុងសង្គម អាចនឹងជា ជំនឿរៀចវេរ ដែលមិនឆ្លុះបញ្ចាំងពីបទពិសោធន៍ ក្នុងជីវិតជាក់ស្ដែងយ៉ាងដូចម្ដេចខ្លះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤២** ●<br><br> | *គន្លឹះទី៣៖ បង្រៀនកូនអ្នកអំពីយុទ្ធសាស្ត្រការពារខ្លួនតាំងពីនៅវ័យក្មេង*<br>• យុទ្ធសាស្ត្រទាំងនេះរួមមាន ការបង្រៀនកុមារពីឈ្មោះត្រឹមត្រូវអំពីផ្នែកនានានៃរាង កាយ។ ការធ្វើបែបនេះ ជួយដល់កុមារឱ្យដឹងអំពីខ្លួនរបស់គេ និងផ្តល់នូវវាក្យស័ព្ទសមស្របសម្រាប់ពួកគេដើម្បី រៀបរាប់ប្រាប់ពីស្ថានភាពបែបរំលោភបំពានដែលអាចកើតមាន។<br>• យុទ្ធសាស្ត្រទាំងនេះ ក៏រាប់បញ្ចូលទាំងការជួយកុមារឱ្យយល់ថា វាជាបញ្ហាប្រសិនបើមាននរណាផ្សេងទៀតទៅប៉ះកន្លែងសម្ងាត់ណាមួយនៃរាងកាយរបស់គេលុះត្រាតែពួកគេត្រូវមានរបួស ឬត្រូវការជំនួយ។<br>• កុមារក៏គួរត្រូវបានលើកទឹកចិត្តឱ្យចេះដឹងច្រើនពីអារម្មណ៍របស់ ពួកគេ (ឧ. បុកពោះ មានអារម្មណ៍ក្តៅ មានអារម្មណ៍ចង់យំ ញ័រជង្គង់ បេះដូងលោតញាប់ ស្ងួតមាត់។ល។ ការស្គាល់ និងការឆ្លើយតបទៅនឹងសញ្ញាផ្នែករាងកាយទាំងនេះ អាចជួយកុមារឱ្យយល់បានថា តើពេលណាដែលពួកគេត្រូវការកិច្ចការពារ។ | អ្នកសម្របសម្រួលអាចមើលឯកសារ រក្សាសុវត្ថិភាពកុមារឲ្យរួចផុតពីការ រំលោភបំពានផ្លូវភេទ៖ កញ្ចប់ឧបករណ៍អ្នកជំនាញសម្រាប់អប់រំកុមារ និងយុវវ័យ (អាចទាញយកបានពី http://www.childsafe-tourism.org និង http://wvi.org/asiapacific/childsafetourism) ដែលផ្តល់នូវការណែនាំជាជំហានៗដើម្បីចែករំលែកការអប់រំអាកប្បកិរិយាបែប ការពារខ្លួនចំពោះកុមារក្នុងក្រុមអាយុទាំងបី (៥-៧ឆ្នាំ, ពី៨-១០ឆ្នាំ និងពី១១-១៧ឆ្នាំ)។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៣** ●<br><br> | *គន្លឹះទី៣៖ បង្រៀនកូនអ្នកអំពីយុទ្ធសាស្ត្រការពារខ្លួនតាំងពីវ័យក្មេង (ត)*<br>• យុទ្ធសាស្ត្រដ៏មានប្រសិទ្ធិភាពមួយទៀតដើម្បីចាប់ផ្តើមបង្រៀនកូនតាំងពីវ័យក្មេង គឺ “ទេ ទៅ ប្រាប់”។ នេះគឺជាយុទ្ធសាស្ត្រដែលត្រូវអនុវត្តនៅពេលដែលស្ថានភាពដែល មានលក្ខណៈព្រួយបារម្ភត្រូវបានកំណត់ឡើង។<br>• សូមបង្រៀនកូនអ្នកថា ពួកគេមានសិទ្ធិនិយាយថា “ទេ”។ ឧទាហរណ៍ នៅពេលដែលនរណាម្នាក់សុំឱ្យពួកគេធ្វើអ្វីម៉្យាងដែលពួកគេមានអារម្មណ៍ថាជារឿងខុស ឬធ្វើឱ្យពួកគេភ័យខ្លាច។<br>• ប្រសិនបើពួកគេអាច ពួកគេគួរ “ទៅ” ពីស្ថានភាពដែលពួកគេកំពុងស្ថិតនៅ។<br>• ត្រូវឱ្យពួកគេដឹងថា ពួកគេគួរ “ប្រាប់” ដល់អ្នក ឬមនុស្សពេញវ័យដទៃទៀតឱ្យដឹង ប្រសិនបើមានរឿងអ្វីដែលពួកគេមិនចូលចិត្តកើតឡើង។<br>• កុមារត្រូវការឱកាសញឹកញាប់ដើម្បីហ្វឹកហាត់ជំនាញទាំងនេះ ដើម្បីយកជំនាញទាំងនេះទៅប្រើ នៅពេលមានស្ថានភាពរំលោភបំពានណាមួយអាចកើតឡើង។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៤** •   | *គន្លឹះទី៣៖ បង្រៀនកូនអ្នកអំពីយុទ្ធសាស្រ្តការពារខ្លួន តាំងពីវ័យក្មេង (ត)*<br>• រឿងសំខាន់មួយទៀត ដែលគួរបង្រៀនកុមារ គឺភាពខុសគ្នារវាង រឿងសម្ងាត់ "រីករាយ" និងរឿងសម្ងាត់ "មិនគួរឲ្យរីករាយ"។<br>• បង្រៀនកុមារឱ្យចេះបែងចែកឱ្យដាច់រវាង "រីករាយ" និងរឿងសម្ងាត់ "មិនគួរឲ្យរីករាយ ដែលរំខានដល់ពួកគេ ឬជាបន្ទុកមួយសម្រាប់ពួកគេគឺមានសារៈសំខាន់ខ្លាំងណាស់។<br>• ដូចយើងបានពិភាក្សាពីខាងដើមមកហើយ ការរំលោភបំពានលើកុមារ កម្រជាសកម្មភាព ដែលកើតម្តងរួចចប់ណាស់។ អ្នក រំលោភបំពានពឹងផ្អែកលើការសម្ងាត់ដែល បានបង្កើតឡើង ដើម្បីឱ្យសកម្មភាព រំលោភបំពានអាចបន្តទៅមុខបាន។<br>• ការបង្រៀនកុមារឱ្យចេះបែងចែករវាងរឿងសម្ងាត់ "រីករាយ" និងរឿងសម្ងាត់ "មិនគួរឲ្យរីករាយ" គឺជារឿងចាំបាច់ណាស់។ កុមារដែលធំៗ អាចរៀនអំពីការសូកប៉ាន់ និងការគំរាម។ | |
| **ស្លាយទី៤៥** •   | *គន្លឹះទី៣៖ បង្រៀនកូនអ្នកអំពីយុទ្ធសាស្រ្តការពារខ្លួនតាំងពីវ័យក្មេង (ត)*<br>• យើងក៏អាចជួយកូនរបស់យើង ដើម្បីកំណត់នូវមនុស្សពេញវ័យដែលគួរទុកចិត្ត នៅក្នុងសហគមន៍របស់យើង ដើម្បីឱ្យកុមារ អាចទៅរកអ្នកទាំងនោះបាន ប្រសិនបើពួកគេមានអារម្មណ៍ថាគ្មានសុវត្ថិភាព ឬព្រួយបារម្ភ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **៣. តើមានសញ្ញាសម្គាល់អ្វីខ្លះ ដែលបង្ហាញថា កុមារអាចស្ថិតក្នុងគ្រោះថ្នាក់?** | | |
| **ស្លាយទី៤៦**   | • ប្រសិនបើយើងព្រងើយកន្តើយលើបញ្ហានៃការរំលោភបំពានផ្លូវភេទកុមារ យើងកំពុងតែដាក់កុមារនៅក្នុងស្ថានភាពដែលកាន់តែមានគ្រោះថ្នាក់ខ្លាំងថែមទៀត។ វាមានសារៈសំខាន់ណាស់ ដែលត្រូវដឹងថា រឿងនេះ អាចកើតឡើងនៅ ក្នុងសហគមន៍របស់យើង។<br>• យើងគួរតែយកចិត្តទុកដាក់ចំពោះឥរិយាបថ របស់កុមារ ជាមួយមនុស្សពេញវ័យ ដែលនៅ ជុំវិញពួកគេ។ | សូមមើល *កាតយកតាមខ្លួន (តើខ្ញុំគួរប្រុងប្រយ័ត្នលើអ្វីខ្លះ?)*   |
| **ស្លាយទី៤៧**   | យកចិត្តទុកដាក់ចំពោះអាកប្បកិរិយារបស់កូនអ្នក។ មានសញ្ញាសម្គាល់ផ្សេងៗ ដែល កុមារអាចនឹងប្រឈមនឹងការរំលោភបំពាន។ ស្របពេលដែលអាការៈទាំងនេះ មិនមែនមានន័យច្បាស់ថា កូនរបស់អ្នកកំពុងត្រូវបានគេរំលោភបំពាននោះ វាពិតជាបានបង្ហាញពីហេតុផលដ៏ល្អក្នុងការនិយាយជាមួយកូនរបស់អ្នកពីស្ថានភាពរបស់ពួកគេ៖<br>• ការប្រែប្រួលទឹកមុខ ប្រែទៅជាគ្មានកម្លាំង តប់ប្រមល់ ខឹងភ្លាមៗ ឬឆេវឆាវ។<br>• រត់ចេញពីផ្ទះ ឬបាត់ខ្លួនរយៈពេលយូរ។<br>• មានការប្រែប្រួលលទ្ធផលធ្វើកិច្ចការសាលារៀនរបស់គេ ឬបាត់ពីសាលារៀន ដោយគ្មាន មូលហេតុ។<br>• មានលុយ អំណោយ ទូរស័ព្ទដៃដោយគ្មានមូលហេតុដែលអាចពន្យល់បាន។<br>• ការប្រើប្រាស់សារធាតុញៀន (រួមមានថ្នាំញៀន និងគ្រឿងស្រវឹង)។<br>• មានអាកប្បកិរិយាខាងផ្លូវភេទ ដែលមិនស្របសម្រាប់វ័យរបស់ពួកគេ។<br>• អាការៈលើរាងកាយរួមមាន៖ បញ្ហាក្នុងពេលដេក មានសើមនៅពេលដេក មានរោគឆ្លងតាម ការរួមភេទ។<br>• ជាកុមារដែលជាញឹកញាប់ត្រូវបានគេហៅថា "ជាក្មេងបង្កបញ្ហា"។ | នេះមិនមែនជាការរៀបរាប់លម្អិតនោះទេ ហើយជាការពិត ឪពុកម្តាយ អ្នកថែទាំដឹងច្បាស់ អំពីកូនរបស់ខ្លួនជាងអ្នកណាៗទាំងអស់។<br>ចំណុចសំខាន់គឺត្រូវសង្កេតមើលលើការប្រែប្រួលអាកប្បកិរិយា។ វាអាចប្រែប្រួលពី "ល្អ" ទៅ "អាក្រក់"។ ជាញឹកញាប់ កុមារដែលចូលចិត្តសម្តែងអាកប្បកិរិយា "មិនល្អ" មិនត្រូវបានគេមើលឃើញថាជាកុមារដែលអាចជាជនរងគ្រោះនោះទេ តែផ្ទុយទៅវិញ ពួកគេត្រូវបានគេកំណត់ថាជា "អ្នកបង្កបញ្ហា" ទៅវិញ។ លក្ខណៈនេះ បានធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះចំពោះការរំលោភបំពាន ដែលនៅតែមានជាបន្តបន្ទាប់ ហើយជាញឹកញាប់ការត្អូញត្អែររបស់កុមារទាំងនេះមិនត្រូវបានគេជឿឡើយ។ នេះគឺជាកំហុសយ៉ាងធ្ងន់ធ្ងរនៃការទទួលខុសត្រូវរបស់យើងចំពោះកុមារ។ |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr><td>ស្លាយទី៤៨ •<br><br></td><td>ត្រូវមានស្មារតីវាងវៃ ប្រសិនបើអ្នកកត់សម្គាល់ឃើញថា មានមនុស្សពេញវ័យម្នាក់ដែលសម្ដែងអាកប្បកិរិយាក្នុងរូបភាពបែបរំលោភបំពាន។ អាកប្បកិរិយានេះរួមមាន ៖<br>• ការយកចិត្តទុកដាក់ហួសហេតុពេក។<br>• ការឱ្យអំណោយរបស់លេង ឬប្រាក់កាស<br>• ការចំណាយពេលនៅតែពីរនាក់ជាមួយកូនរបស់អ្នក។<br>• យកកូនរបស់អ្នកចេញទៅដើរលេងនៅក្រៅដើរកំសាន្តនិងដើរលំហែ។</td><td></td></tr>
<tr><td colspan="3">៤. តើយើងអាចទៅរកជំនួយបានទៅកន្លែងណា ?</td></tr>
<tr><td>ស្លាយទី៤៩ •<br><br></td><td>• មានជំហានវិជ្ជមានជាច្រើន ដែលអាចរក្សាកុមារឱ្យមានសុវត្ថិភាពរួចផុតពីការរំលោភបំពានផ្លូវភេទនៅក្នុងប្រទេស និងនៅក្នុងតំបន់។<br>• ប្រសិនបើកូនរបស់អ្នកកំពុងស្ថិតក្នុងគ្រោះថ្នាក់ អាទិភាពសំខាន់បំផុតជាងគេរបស់អ្នកគឺត្រូវការពារកុមារ ។<br>• ជំនួយ មានសម្រាប់អ្នក និងសហគមន៍របស់អ្នក។<br><br>សកម្មភាព៖ផែនទីនៃធនធានសហគមន៍របស់យើង (តាមជម្រើស)<br><br>• អញ្ជើញឪពុកម្ដាយ ដើម្បីរួមចំណែក ក្នុងការបង្កើតដ្យាក្រាមក្រុម ឬផែនទីគំនិត* ពីប្រភេទនៃសេវាគាំទ្រនានា ដែលមាននៅក្នុងសហគមន៍ សម្រាប់អ្នកដែលមានការបារម្ភពីការរំលោភបំពាន កុមារ ឬសម្រាប់អ្នកដែលរងការរំលោភបំពាន។ (ឧ៖ ក្រសួងសង្គមកិច្ច បណ្ដាញ ទូរស័ព្ទទាន់ហេតុការណ៍ មណ្ឌលសុខភាពសហគមន៍ សាលារៀន ប៉ូលីស ជាដើម)។<br><br>*ឧទាហរណ៍អំពីផែនទីគំនិត៖<br><br></td><td>អ្នកសម្របសម្រួលអាចបន្ថែមឧទាហរណ៍មួយចំនួនអំពីជំហានវិជ្ជមាន ដើម្បីការពារកុមារនៅកម្រិតថ្នាក់មូលដ្ឋាន និង/ឬ ថ្នាក់ជាតិ។ ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា។<br>• អង្គការក្នុងមូលដ្ឋានជាច្រើនអាចជួយ ដល់អ្នកបានក្នុងការស្វែងរកដំណើរការ និងផ្ដល់ឱ្យអ្នកនូវព័ត៌មានត្រឹមត្រូវ។ អ្នកខ្លះទៀតអាចនឹងផ្ដល់ការគាំទ្របានខ្លះផងដែរ។<br>• រដ្ឋាភិបាលផ្ដល់ការគាំទ្រដល់គ្រួសារ ដើម្បីធានាបាននូវសុខុមាលភាពកូនៗរបស់ពួកគេ។<br>• រដ្ឋាភិបាល គាំទ្របណ្ដាញទូរស័ព្ទជំនួយដែលកុមារា និងកុមារី គ្រួសារ និងពលរដ្ឋដទៃ អាចទូរស័ព្ទទៅសុំដំបូន្មាន និងព័ត៌មាននានា ទាក់ទងនឹងកង្វល់របស់ពួកគេ<br>• រដ្ឋាភិបាលបានបង្កើតច្បាប់ ដើម្បីការពារកុមារ និងកាត់ទោសជនដែលបង្ករគ្រោះថ្នាក់ដល់កុមារ។<br>• ប៉ូលីសតាមដាន និងស៊ើបអង្កេតករណីនានា។<br>• តុលាការកាត់ទោសអ្នករំលោភបំពាន។<br>• រដ្ឋាភិបាលថ្នាក់ខេត្តធ្វើយុទ្ធនាការផ្សេងៗ។<br>• មានលេខទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីរាយការណ៍ពីករណីសង្ស័យអំពីការរំលោភបំពានផ្លូវភេទលើកុមារ។<br>អ្នកសម្របសម្រួលត្រូវទទួល និងផ្ដល់នូវព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង គ្រប់សេវាពាក់ព័ន្ធទាំងអស់ និងយន្តការរាយការណ៍នានា នៅក្នុងតំបន់ក្នុងមូលដ្ឋាន។</td></tr>
</table>

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សម្គាល់ជំនួយ</th></tr>
<tr>
<td>ស្លាយទី៥០<br><br></td>
<td>សូមផ្តល់នូវព័ត៌មាន លម្អិតសម្រាប់ទំនាក់ទំនងសម្រាប់អាជ្ញាធរក្នុងមូលដ្ឋាន និង អង្គការនានាដែលឪពុកម្តាយ និងអ្នកថែទាំ អាចទំនាក់ទំនងបានសម្រាប់ជំនួយ។</td>
<td>សូមមើល កាតយកតាមខ្លួន (នរណាផ្សេងទៀតដែលអាចជួយអ្នកបាន?) និងផ្តល់ដល់សិក្ខាកាមនូវព័ត៌មានសម្រាប់ទំនាក់ទំនងថ្នាក់មូលដ្ឋាន/ថ្នាក់ជាតិ។<br><br></td>
</tr>
<tr><td colspan="3">ធ្វើផែនការសកម្មភាព</td></tr>
<tr>
<td>ស្លាយទី៥១<br><br></td>
<td>សកម្មភាព៖ ផែនការរបស់ឪពុកម្តាយ<br>• ប្រសិនបើមានពេល សូមចែកអ្នកចូលរួមទៅជាក្រុមតូចៗ ដោយមានសមាជិក ៥-៦ នាក់ក្នុងមួយក្រុម។<br>• ប្រាប់អ្នកចូលរួមថា ពួកគាត់គឺជាគណៈកម្មការថ្មី ទទួលបន្ទុក សម្របសម្រួល ការការពារកុមារនៅក្នុងសហគមន៍របស់ពួកគាត់។<br>• ឱ្យពួកគាត់បង្កើតផែនការមួយពីសកម្មភាពទាំងអស់ ដែលពួកគាត់នឹងផ្តួចផ្តើមគំនិតធ្វើសកម្មភាព ដើម្បីរក្សាកុមារ ឱ្យមានសុវត្ថិភាពនៅក្នុងសហគមន៍។ សូមផ្តល់ពេលវេលាប្រាំនាទីដើម្បីឱ្យពួកគាត់រៀបចំផែនការ។<br>• អញ្ជើញអ្នកចូលរួមឱ្យចែករំលែកផែនការរបស់ខ្លួន។ បន្ទាប់ពីក្រុមនីមួយៗបានចែករំលែកផែនការរបស់ខ្លួនហើយ សូមលើកសរសើរដល់ក្រុមចំពោះគំនិតបង្កើតថ្មី និងលើកទឹកចិត្តឱ្យពួកគេធ្វើបន្តទៅទៀត ដើម្បីអនុវត្តគំនិតរបស់ពួកគេទៅជាសកម្មភាពជាក់ស្តែងជាងគេ នៅក្នុងសហគមន៍របស់ពួកគេ។</td>
<td>ផែនការអាចរួមមាន៖<br>• លើកទឹកចិត្តដល់ការអប់រំអំពីផ្លូវភេទ នៅក្នុងសាលារៀន<br>• គោលនយោបាយការពារកុមារ ក្នុងសាលារៀន<br>• មិនត្រូវមើលរំលង ឬស្ងប់ខ្ញើមកុមារ ឬជនរងគ្រោះដោយការរំលោភបំពានដទៃទៀត នៅក្នុងសហគមន៍។<br>• ត្រូវឃ្លាំមើលឱ្យបានច្រើនជាងមុនចំពោះអត្តចរិកគួរឱ្យសង្ស័យនិងរាយការណ៍។</td>
</tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **សេចក្ដីសន្និដ្ឋាន** | | |
| **ស្លាយទី៥២** •<br><br> | *សកម្មភាពៈ ការវាយតម្លៃ*<br>• ដើម្បីឱ្យយើងអាចបន្តកែលម្អ សកម្មភាពរបស់យើងឱ្យប្រសើរឡើង យើងខ្ញុំសុំសួរយោបល់ត្រលប់របស់អ្នកចំពោះវគ្គសិក្សាថ្ងៃនេះ។ នរណាក៏អាចឆ្លើយតបនឹងសំណួរទាំងនេះបានដែរ៖<br>– តើវគ្គសិក្សានេះមានសារៈប្រយោជន៍ឬទេ ?<br>– តើព័ត៌មានអ្វីដែលមានសារៈសំខាន់បំផុត ដែលអ្នកបានរៀនសូត្រនៅថ្ងៃនេះ ?<br>– តើមានអ្វីដែលយើងគួរផ្លាស់ប្ដូរ សម្រាប់វគ្គសិក្សានៅពេលខាងមុខដែរឬទេ ?<br>• វាអាចជាជម្រើសផ្សេងទៀត អ្នកសម្របសម្រួលអាចចែក ទម្រង់មតិយោបល់ខ្ញុំ (**ឧបសម្ព័ន្ធទី៧**) សម្រាប់ឲ្យអ្នកចូលរួមបំពេញ។ ការធ្វើបែបនេះអាចនឹងត្រូវការពេលវេលាច្រើន ហើយអាចជាបញ្ហាប្រឈមសម្រាប់អ្នកចូលរួមដែលមានកម្រិតអក្ខរកម្មខុសៗគ្នា។ សូមប្រើពាក្យពេចន៍សាមញ្ញៗ ដើម្បីងាយយល់។<br>*សកម្មភាពៈ សំណួរក្រោយមេរៀន*<br>• ពេលនេះខ្ញុំចង់ពិនិត្យបន្តិចថា តើចម្លើយរបស់អ្នកទៅនឹងសំណួរខ្លីទាំងនេះខុសគ្នាពីពេលចាប់ផ្ដើមវគ្គដែរឬទេ។<br>• អនុវត្តការធ្វើ សំណួរក្រោយមេរៀន ប្រកបដោយការចូលរួម ឬដោយការប្រើប្រាស់ទម្រង់ជាលាយលក្ខណ៍អក្សរនៅក្នុង **ឧបសម្ព័ន្ធទី៤**។<br>• បន្ទាប់មក លើកឡើងពីចម្លើយដែលត្រឹមត្រូវដើម្បីធានាថា អ្នកគ្រប់គ្នា យល់អំពីសារសំខាន់ មុនពេលដែលពួកគាត់ចាកចេញពីវេទិកាពិភាក្សានេះ។ | ទម្រង់មតិយោបល់របស់ខ្ញុំ មាននៅក្នុងឧបសម្ព័ន្ធទី៨។ ច្បាប់ថតចម្លងនៃខ្លឹមសារនេះអាចត្រូវបានចម្លងជូនដល់អ្នកចូលរួមគ្រប់រូបនៅមុនពេលវេទិកាពិភាក្សា។<br><br>សំណួរក្រោយមេរៀនអាចរកបាននៅក្នុង **ឧបសម្ព័ន្ធទី៤**។ ដូចគ្នានឹង សំណួរមុនចូលមេរៀនដែរ សំណួរនេះអាចត្រូវបានអនុវត្តប្រកបដោយការការចូលរួមខ្ពស់ តាមរយៈការប្រើប្រាស់ប័ណ្ណឆ្លើយតប ដែលមាននៅក្នុង **ឧបសម្ព័ន្ធទី៥** ឬតាមរយៈការឱ្យអ្នកចូលរួមនាំគ្នាទៅកាន់ផ្នែកមួយនៃបន្ទប់ទៅតាមសញ្ញា “សញ្ញាខ្វែង” “ធីក” ឬ “សញ្ញាសួរ”។<br><br>អ្នកសម្របសម្រួល គួររៀបចំឯកសារចម្លើយទៅនឹងកិច្ចពិភាក្សា សំណួរលើការវាយតម្លៃ និង សំណួរក្រោយមេរៀន (ប្រសិនបើអនុវត្តប្រកបដោយការចូលរួមខ្ពស់) ដូច្នេះ វាអាចត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ក្រោយវគ្គបណ្ដុះបណ្ដាល (**ឧបសម្ព័ន្ធទី៨**)។ |

| ស្លាយ | សារគន្លឹះ | កំណត់សម្គាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៣** ●<br><br> | • អរគុណអ្នកចូលរួមចំពោះការយកចិត្តទុកដាក់ និងការចូលរួមវិភាគទានរបស់ពួកគេ។<br>• រំលឹកអ្នកចូលរួមឡើងវិញ ពីតួនាទីដ៏សំខាន់របស់ឪពុកម្ដាយ និង អ្នកថែទាំក្នុងការការពារកុមារពីការរំលោភបំពានផ្លូវភេទ។<br>• លើកទឹកចិត្តអ្នកចូលរួម ឱ្យប្រើប្រាស់ព័ត៌មាន ដែលពួកគាត់បានរៀនសូត្រពីវគ្គសិក្សាថ្ងៃនេះ ដើម្បីកសាងបរិស្ថានប្រកបដោយការការពារមួយ សម្រាប់កុមារនៅក្នុងសហគមន៍របស់ខ្លួន។<br>• អញ្ជើញអ្នកចូលរួមឱ្យទាក់ទងទៅតាមព័ត៌មានសម្រាប់ទំនាក់ទំនងដែលបានរៀបរាប់ក្នុងអំឡុងវគ្គនេះ ប្រសិនបើពួកគាត់មានកង្វល់អ្វីមួយ អំពីការរំលោភបំពាន ផ្លូវភេទលើកុមារ។<br>• សូមសង្កត់ធ្ងន់ថា តាមរយៈការធ្វើសកម្មភាពងាយៗ ពួកយើង អាចធ្វើឱ្យការការពារកុមាររបស់យើងកាន់តែមានភាពប្រសើរឡើង។<br>• សូមកុំភ្លេចត្រូវអរគុណដល់បុគ្គលិកគាំទ្រដទៃទៀត ដែលបានជួយជ្រោមជ្រែងនៅក្នុងវគ្គសិក្សា។ | |

# កត់ចំណាំ

# កត់ចំណាំ

....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................
....................................................................................................................................

# ផ្នែកទី៣

# ឧបសម្ព័ន



# ឧបសម្ព័ន្ធទី១: កាតយកតាមខ្លួន

**ការណែនាំ៖** ច្បាប់ថតចម្លងនៃកាតទាំងនេះ គួរត្រូវបានធ្វើសម្រាប់អ្នកចូលរួមម្នាក់ៗ។ អ្នកចូលរួមអាចយកកាតទាំងនេះតាមខ្លួនបាន ក្រោយពីវេទិកាពិភាក្សា ដើម្បីរំលឹកដល់ចំណុចសំខាន់ៗដែលគាត់បានសិក្សារួច និងដើម្បីចែករំលែកជាមួយនឹងក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់។ ជាការល្អ គួរថតចម្លងកាតយកតាមខ្លួននៅក្នុង ឧបសម្ព័ន្ធទី៥ ឬទី៦ ទាំងសងខាង។ ការធ្វើបែបនេះគឺផ្តល់ឱ្យពួកគាត់នូវធនធានឯកសារដែលងាយចងចាំ និងកាន់តែមានប្រយោជន៍។

# រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ

## ឪពុកម្ដាយ និងអ្នកថែទាំ



Australian Aid

World Vision

# ការការពារកុមារ គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា

កុមារ គឺជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។ កុមារត្រូវការការការពារជាពិសេស។ ឪពុកម្តាយ និងអ្នកថែទាំជាអ្នកការពារចំបង និងសំខាន់បំផុតរបស់កុមារ។




**ឪពុកម្តាយ និងអ្នកថែទាំ មានតួនាទីសំខាន់បំផុតដើម្បីរក្សាសុវត្ថិភាពកុមារឲ្យរួចផុតពីការរំលោភបំពាន។**

# តើអ្វីជាការរំលោភបំពានកុមារ ?

ការរំលោភបំពានកុមារ គឺជាសកម្មភាពណាមួយ (ឬ មិនមែនសកម្មភាព) ដែលធ្វើឡើងមិនមែនដោយចៃដន្យ  ហើយធ្វើឲ្យកុមារឈឺចាប់ ឬធ្វើឲ្យកុមារមានគ្រោះថ្នាក់ ។

មានកុមាររាប់លាននាក់ នៅជុំវិញពិភពលោក បានទទួលរងគ្រោះដោយសារការរំលោភបំពានជារៀងរាល់ថ្ងៃ ។ ការរំលោភបំពានកុមារកើតឡើងនៅគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ។

## ប្រភេទនៃការរំលោភបំពានកុមារ

ការរំលោភបំពានកុមារមាន៤ប្រភេទសំខាន់ៗ ។ ជាញឹកញាប់ការរំលោភបំពានលើសពីមួយ ប្រភេទបានកើតឡើងក្នុងពេលដំណាលគ្នា ។

- ការរំលោភបំពានផ្លូវកាយ
- ការរំលោភបំពានផ្លូវភេទ
- ការរំលោភបំពានផ្លូវចិត្ត
- ការមិនអើពើ

## ផលប៉ះពាល់នៃការរំលោភបំពានកុមារ

ការរំលោភបំពានមានផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារ ហើយអាចបណ្តាលឲ្យកុមារមានបញ្ហាទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងរយៈពេលវែង។

ផលវិបាកនៃការរំលោភបំពានគឺមិនត្រឹមតែប៉ះពាល់ទៅលើជនរងគ្រោះប៉ុណ្ណោះទេប៉ុន្តែវាក៏ជះឥទ្ធិពលទៅដល់គ្រួសារ សហគមន៍ និងសង្គមជាតិផងដែរ ។

យើងមិនត្រូវបន្ទោសកុមារចំពោះការរំលោភបំពាន ឬផលប៉ះពាល់ដែលកើតមានចំពោះគ្រួសារ និងសហគមន៍នោះឡើយ។

# តើអ្វីជាការរំលោភបំពានកុមារ ?



រំលោភបំពានដោយប្រើពាក្យ
សម្តីមិនល្អចំពោះកុមារ



និយាយលូកលាន់លើកុមារ
ដែលមិនចាំបាច់



ប៉ះពាល់លើកុមារនៅផ្នែក
ណាមួយនៃរាងកាយដែល
កុមារមិនចង់ឲ្យប៉ះ



មិនស្តាប់សម្តីកុមារ



នាំឲ្យកុមារឃើញសកម្មភាព
ឬរូបអាសអាភាសផ្លូវភេទ



បង្ខំកុមារឲ្យប៉ះពាល់ផ្នែក
ណាមួយនៃរាងកាយរបស់ខ្លួន



ធ្វើឲ្យកុមារបាត់បង់ទំនុកចិត្ត
លើខ្លួនឯង



វាយដំ ឬធ្វើឲ្យកុមារ
ឈឺចាប់ ជារឿយៗ
ដើម្បីរំសាយកំហឹងខ្លួនឯង



បោកបញ្ឆោតកុមារ



មិនយកចិត្តទុកដាក់ថែទាំកុមារ
ដូចជាមិនសម្អាត ស្លៀកពាក់
និងឲ្យចំណីអាហារ



ប្រើប្រាស់កុមារធ្វើជាអ្នកបម្រើ



មិនយកចិត្តទុកដាក់លើ
សេចក្តីត្រូវការផ្នែកសតិអារម្មណ៍
របស់កុមារ



ធ្វើឲ្យកូនរបស់ខ្លួនក្លាយជា "អ្នកបម្រើ"
ដោយមិនឲ្យមានពេលលំហែរនិងសិក្សា



វាយដំ និងសើចចំអកឲ្យកុមារ
នៅសាលារៀន



មិនយកចិត្តទុកដាក់លើ
តម្រូវការផ្នែកសុខភាពរាងកាយ
របស់កុមារ



មិនយកចិត្តទុកដាក់លើ
តម្រូវការផ្នែកអប់រំរបស់កុមារ



ទុកកុមារចោលគ្មានអ្នកមើលថែ

រូបភាព និងអត្ថបទដកស្រង់ចេញពីផ្ទាំងរូបភាព "តើអ្វីទៅជាការរំលោភបំពានលើកុមារ" ដែលផលិតដោយ *Childline Thailand Foundation* ក្នុង គេហទំព័រ *http://childlinethailand.org*



# តើអ្វីជាការរំលោភបំពានផ្លូវភេទកុមារ ?

- ការរំលោភបំពានផ្លូវភេទកុមារ កើតមានឡើងនៅពេលមាននរណាម្នាក់ឲ្យកុមារពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទ ដោយប្រើប្រាស់អំណាចរបស់ខ្លួនលើកុមារ ឬកេងចំណេញពីការទុកចិត្តរបស់កុមារ។

- ការរំលោភបំពានផ្លូវភេទកុមាររួមបញ្ចូលនូវអាកប្បកិរិយាផ្លូវភេទដែលមិនគួរគប្បីគ្រប់ប្រភេទ។ ទង្វើទាំងនេះ អាចរួមមានទាំងទង្វើដែលមានការប៉ះកាន់ ឬមិនមានប៉ះកាន់ទាល់តែសោះ។

- ការរំលោភបំពានផ្លូវភេទកុមាររួមមាន៖
  - ការផលិតរូបភាព/រូបថត/វីដេអូ ដែលមានលក្ខណៈរំលោភបំពានអំពីកុមារ។
  - ការបង្ខំកុមារឲ្យមើល ឬឲ្យចូលរួមក្នុងទង្វើផ្លូវភេទ
  - បង្ខិតបង្ខំកុមារឲ្យរួមភេទ ឬចូលរួមក្នុងទង្វើផ្លូវភេទជាមួយកុមារដទៃ ឬជាមួយមនុស្សធំ។

# តើអ្នកដឹងទេថា ?

## ការរំលោភបំពានផ្លូវភេទកុមារ គឺជាបញ្ហាសកល

ការរំលោភបំពានផ្លូវភេទកុមារ កើតឡើងនៅគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។ សូម្បីតែសហគមន៍របស់យើង ក៏មិនប្រាកដថាគ្មាន ការរំលោភបំពានផ្លូវភេទកុមារដែរ។ ភាគច្រើននៃអ្នករំលោភបំពាន គឺជាអ្នកនៅក្នុងស្រុកនោះ។

## ជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ អាចមានទាំងកុមារា និងកុមារី

ទាំងកុមារា និងកុមារីសុទ្ធតែអាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ។ កុមារភេទទីបី ឬកុមារដែលកំពុងស្វែងយល់អត្តសញ្ញាណផ្លូវភេទរបស់ខ្លួន អាចប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្ពស់។ កុមារមានពិការភាព (ពិការភាពគ្រប់ប្រភេទ) ក៏អាចប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ផងដែរ។ ការរំលោភបំពានផ្លូវភេទ អាចកើតឡើងចំពោះកុមារមកពីគ្រប់សាវតាទាំងអស់។

## ជារឿយៗ អ្នករំលោភបំពាន ច្រើនតែជាមនុស្សដែលកុមារស្គាល់

ជារឿយៗ អ្នករំលោភបំពានផ្លូវភេទកុមារគឺច្រើនតែជាសមាជិកគ្រួសារ សមាជិកក្នុងសហគមន៍ ឬនរណាម្នាក់ដែលគេទុកចិត្ត។

## អ្នករំលោភបំពានអាចធ្វើខ្លួនជាមិត្តភក្តិជិតស្និទ្ធជាមួយកុមារ និងគ្រួសាររបស់ពួកគេ

ជារឿយៗ អ្នករំលោភបំពានច្រើនតែសាងមិត្តភាពជាមួយជនរងគ្រោះ និងគ្រួសាររបស់គេ ជាវិធីមួយដើម្បី "លាក់បាំង" ការរំលោភបំពានរបស់ពួកគេ។

## ការរំលោភបំពានផ្លូវភេទកុមារអាចកើតមានក្នុងវិស័យទេសចរណ៍

ជនបរទេសមួយចំនួនតូច ប្រើប្រាស់ការធ្វើដំណើរជាឱកាសដើម្បីរំលោភបំពានផ្លូវភេទកុមារ។ ជនល្មើសជាអ្នកធ្វើដំណើររំលោភបំពានផ្លូវភេទកុមារ គឺជាអ្នកទេសចរ អ្នកធ្វើដំណើរ ឬអ្នកតាំងលំនៅបរទេសទាំងឡាយណាដែលប្រព្រឹត្តិការរំលោភបំពានផ្លូវភេទកុមារក្នុងប្រទេស ឬបណ្តាប្រទេសដែលខ្លួនកំពុងរស់នៅ ឬកំពុងទស្សនា។

## ជារឿយៗកុមារមិននិយាយប្រាប់មនុស្សធំអំពីការរំលោភបំពាននោះទេ

ដោយសារហេតុផលជាច្រើន ជារឿយៗកុមារតែងនៅស្ងៀមស្ងាត់មិននិយាយអំពីការរំលោភបំពាននោះទេ។ សូមពិនិត្យរកមើលសញ្ញានានា ជាជាងរង់ចាំឲ្យកុមារមករាយការណ៍។

## កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារ

កុមារគ្រប់រូបនៅទូទាំងពិភពលោក មានសិទ្ធិទទួលបានការការពារឲ្យរួចផុតពីការរំលោភបំពានគ្រប់ទម្រង់ទាំងអស់។ ក្នុងនាមជាមនុស្សធំ យើងមានភារកិច្ចការពារកុមារឲ្យរួចផុតពីគ្រោះថ្នាក់។ យើងមិនត្រូវស្តីបន្ទោសកុមារចំពោះការរំលោភបំពានដែលកើតលើរូបគេនោះឡើយ។

# តើខ្ញុំអាចរក្សាសុវត្ថិភាពកូនរបស់ខ្ញុំបានដោយរបៀបណា ?

### ១ ត្រូវដឹងព័ត៌មានឲ្យបានច្រើន

- អ្នករំលោភបំពានផ្លូវភេទកុមារ អាចឆ្លៀតឱកាសបានដោយសារប្រជាជនខ្វះចំណេះដឹងអំពីរបៀបដែលពួកគេរំលោភបំពានកុមារ។
- ត្រូវដឹងព័ត៌មានឲ្យបានច្រើន និងជជែកដោយបើកចំហរអំពីការរំលោភបំពានកុមារ។

### ២ ត្រូវនិយាយជាមួយកូនរបស់យើង

- ពេលខ្លះ កុមារមិនប្រាប់អ្វីដែលសំខាន់ជាមួយឪពុកម្ដាយរបស់ខ្លួនទេ ព្រោះពួកគេខ្លាចទទួលពិន័យឬការស្ដីបន្ទោស។ អ្នករំលោភបំពានផ្លូវភេទកុមារ ប្រើប្រាស់ការភ័យខ្លាចនេះជាប្រយោជន៍របស់ខ្លួន។
- សូមសាងទំនាក់ទំនងបើកចំហរ និងទុកចិត្តគ្នាជាមួយកូនអ្នក។ សូមធ្វើឲ្យកូនៗដឹងថាគេអាចប្រាប់រឿងគ្រប់យ៉ាងដល់អ្នកបាន។
- និយាយជាមួយកូនអ្នកអំពីការរួមភេទ និងបញ្ហាផ្លូវភេទ ក្នុងលក្ខណៈមួយដែលសមស្របទៅនឹងអាយុរបស់ពួកគេ។
- បង្រៀនកូនឲ្យចេះយុទ្ធសាស្ត្រការពារខ្លួនតាំងពីគេនៅអាយុតិច រួមមាន៖
  - ស្គាល់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយយ៉ាងត្រឹមត្រូវ
  - ស្គាល់ និងឆ្លើយតបទៅនឹងអារម្មណ៍ និងការផ្ដល់សញ្ញារបស់រាងកាយ ដើម្បីដឹងថាពេលណាពួកគេត្រូវការការការពារ។
  - ប្រសិនបើកុមារមានអារម្មណ៍ថា បារម្ភ ឬភ័យខ្លាច គេតអាចនិយាយថា ទេ និង ទៅ ឲ្យឆ្ងាយពីស្ថានភាព និង ប្រាប់ ដល់មនុស្សធំដែលមានសុវត្ថិភាពណាម្នាក់អំពីអ្វីដែលបានកើតឡើង។

### ៣ ត្រូវដឹងអំពីអ្វីដែលកំពុងកើតឡើង

- ត្រូវដឹងថា រឿងនេះក៏អាចកើតមានក្នុងសហគមន៍របស់យើងបានដែរ។
- ត្រូវយកចិត្តទុកដាក់មើលទៅលើការប្រែប្រួលផ្នែកអាកប្បកិរិយារបស់កូនអ្នក។
- ត្រូវសង្កេតមើលអាកប្បកិរិយារបស់មនុស្សធំដទៃទៀតដែលចំណាយពេលជាមួយកូនអ្នក។

### ៤ ត្រូវដឹងថានរណាដែលអ្នកអាចសុំជំនួយបាន

- ត្រូវស្វែងរកជំនួយភ្លាមៗ ប្រសិនបើអ្នកសង្ស័យថាកុមារណាម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់ ឬបានរងការរំលោភបំពាន។

# តើអ្នករំលោភបំពានផ្លូវភេទកុមារ ប្រតិបត្តិការយ៉ាងដូចម្តេច?

អ្នករំលោភបំពាន អាចប្រើប្រាស់វិធីផ្សេងៗជាច្រើនដើម្បីចូលទៅរកកុមារនិងរំលោភបំពានកុមារ។ មនុស្សជាច្រើនតែងគិតថា ការរំលោភបំពានផ្លូវភេទកុមារ ច្រើនតែកើតឡើងក្នុងលក្ខណៈជាការវាយប្រហារដោយមនុស្សមិនដែលស្គាល់គ្នា។ តាមពិត អ្នករំលោភបំពាន នឹង/ឬមេអណ្តើកច្រើនចំណាយពេលដើម្បីសាងទំនាក់ទំនងជាមួយកុមារ ( និងពេលខ្លះជាមួយគ្រួសាររបស់កុមារ )។

ដំណើរការនេះហៅថា “ការល្បួង” ហើយអាចរួមមានជំហ៊ានជាច្រើន៖




អ្នករំលោភបំពានស្វែងរកកុមារដែលខ្លួនចង់រំលោភបំពាន។ ជារឿយៗ ពួកគេច្រើនជ្រើសរើសយកកុមារ ដែលងាយរងគ្រោះ។

អ្នករំលោភបំពានកសាងការទុកចិត្តពីកុមារ តាមរយៈការចែករំលែកចំណាប់អារម្មណ៍ជាមួយកុមារ ផ្តល់អំណោយផ្សេងៗដល់កុមារនិងធ្វើជាមិត្តរបស់កុមារ។

អ្នករំលោភបំពានចាប់ផ្តើមមានការសម្ងាត់ជាមួយកុមារ នឹងប្រើប្រាស់ការសន្យា ការគម្រាម ឬការបង្ខំ ដើម្បីឲ្យកុមាររក្សាភាពស្ងៀមស្ងាត់។

អ្នករំលោភបំពាន ពង្រីកលក្ខណៈផ្លូវភេទនៅក្នុងទំនាក់ទំនងរបស់ពួកគេ កាន់តែធំឡើងៗ។ ពួកគេលើកឡើងអំពីបញ្ហាផ្លូវភេទ និងចែករំលែកសម្ភារៈផ្លូវភេទដើម្បីឲ្យកុមារស៊ាំ។

អ្នករំលោភបំពានអនុវត្ត ( ប្រតិបត្តិ ) សកម្មភាពដែលមានលក្ខណៈរំលោភបំពានផ្លូវភេទ។

មិនមែនអ្នករំលោភបំពានទាំងអស់សុទ្ធតែប្រើប្រាស់បច្ចេកទេសល្បួងនោះឡើយ។ វិធីដទៃទៀតមានដូចជា ការវាយប្រហារភ្លាមៗ ការទិញ ការបញ្ឆោត និងកេងប្រវ័ញ្ច ការបង្ខំ។ ជារឿយៗ អ្នករំលោភបំពានមិនធ្វើសកម្មភាពតែម្នាក់ឯងនោះឡើយ។ ពួកគេអាចនឹងទទួលការជួយជ្រោមជ្រែង ឬការគាំទ្រពីមនុស្សផ្សេងទៀត ដូចជាជំនួយការ អ្នករកទិញ ភ្នាក់ងារ មេអណ្តើក និង អ្នកសម្របសម្រួល ជាដើម។

# តើខ្ញុំត្រូវសម្លឹងរកមើលអ្វី ?

## អាកប្បកិរិយារបស់កូនអ្នក

មានសញ្ញានានាដែលអាចបង្ហាញថា កូនរបស់អ្នកប្រហែលជារងនូវការរំលោភបំពាន។ ថ្វីបើសញ្ញាទាំងនេះ មិនមែនសុទ្ធតែមានន័យថា កូនរបស់អ្នកត្រូវគេរំលោភបំពានក្តី ប៉ុន្តែសញ្ញាទាំងនេះក៏អាចផ្តល់ជាហេតុផលសមស្របដើម្បីឲ្យអ្នកនិយាយជាមួយកូនរបស់អ្នកអំពីស្ថានភាពរបស់ពួកគេ ឬដើម្បីស្វែងរកជំនួយដែរ។

- អារម្មណ៍ប្រែប្រួល, ដកខ្លួនពីគេឯង តានតឹងចិត្ត ខឹងភ្លាមៗ ឬកម្រោល
- រត់ចេញពីផ្ទះ ឬបាត់ខ្លួនរយៈពេលយូរ
- មានការប្រែប្រួលចំពោះលទ្ធផលរៀនសូត្រនៅសាលា ឬគេចសាលាដោយគ្មានមូលហេតុ
- មានលុយ អំណោយ ទូរស័ព្ទដៃដោយមិនមានមូលហេតុ
- ប្រើប្រាស់បំពានសារធាតុផ្សេងៗ ( ដូចជាថ្នាំញៀន និងគ្រឿងស្រវឹង )
- អាកប្បកិរិយាក្នុងលក្ខណៈផ្លូវភេទមិនសមស្របតាមអាយុ
- រោគសញ្ញាផ្លូវកាយ ដូចជាបញ្ហាក្នុងការគេង នោមដាក់គ្រែ ជំងឺកាមរោគជាដើម។

## អាកប្បកិរិយារបស់មនុស្សធំនៅជុំវិញអ្នក

ត្រូវប្រុងប្រយ័ត្នប្រសិនបើអ្នកកត់សំគាល់ឃើញមនុស្សធំមានអាកប្បកិរិយាមិនប្រក្រតីជាមួយកូនអ្នក។ អាកប្បកិរិយាទាំងនេះមាន៖

- យកចិត្តទុកដាក់ហួសប្រមាណចំពោះកូនអ្នក
- ផ្តល់អំណោយជាប្រដាប់លេង ឬលុយ
- ចំណាយពេលជាមួយកូនអ្នកតែឯង
- ចង់យកកូនអ្នកចេញទៅក្រៅ ទៅដើរលេង និងសម្រាកលំហែរ។

**ប្រសិនបើកុមារម្នាក់ និយាយប្រាប់អ្នកថា រូបគេបានរងនូវការរំលោភបំពាន សូមធ្វើឲ្យគេជឿជាក់ថាអ្នកកំពុងស្តាប់អ្វីដែលគេនិយាយ និងជឿលើអ្វីដែលគេកំពុងប្រាប់អ្នក។**



# តើមាននរណាខ្លះទៀតអាចជួយបាន ?

តើអ្នកត្រូវការព័ត៌មានបន្ថែមទៀត ឬទេ ? ឬ តើអ្នកដឹងអំពីស្ថានភាពដែលកុមារប្រហែលជាកំពុងប្រឈមនឹងគ្រោះថ្នាក់ពីការរំលោភបំពាន ឬទេ ?

ទូរសព្ទ័ទៅបណ្តាញទូរសព្ទ័ទាន់ហេតុការណ៍ការពារកុមារថ្នាក់ជាតិ

**១២៨៨** ........................................

ទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋាន

........................................

ទំនាក់ទំនងទីភ្នាក់ងារការពារកុមារ ដែលមានកេរ្តិ៍ឈ្មោះល្អ:

**០៩២ ៣១១ ៥១១** ........................................

**w:** childsafetourism.org **and** wvi.org/asiapacific/childsafetourism

**f:** facebook.com/ChildSafeTourism **t:** twitter.com/childsafetravel

**Child Safe Tourism**

Take action against abuse

# ឧបសម្ព័ន្ធទី២៖ ទម្រង់ចុះវត្តមានអ្នកចូលរួម

**គំរូនេះអាចប្រើប្រាស់បានដើម្បីកត់ត្រាទុកនូវព័ត៌មានលម្អិត និងសំខាន់ៗរបស់អ្នកចូលរួម។**

ទីកន្លែងវេទិកាពិភាក្សា: ______________________________________________

និងម៉ោងវេទិកាពិភាក្សា: ___________________________________________

| គោត្តនាម និងនាម | ភេទ | លេខទូរស័ព្ទ | អ៊ីម៉ែល (ប្រសិនបើមាន) | ហត្ថលេខា |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ឧបសម្ព័ន្ធទី៣៖ សំណួរមុនចូលមេរៀន

**ការណែនាំ៖** យកល្អ សំណួរមុនចាប់ផ្តើមគួរធ្វើឡើងជាផ្ទាល់មាត់វិញ។ យើងក៏អាចធ្វើសំណួរមុនចាប់ផ្តើមនេះជាទម្រង់លាយលក្ខណ៍អក្សរបានផងដែរ។ ច្បាប់ថតចម្លងករណីនៃសំណួរខ្លីនេះ គួរថតចម្លងជូនអ្នកចូលរួមម្នាក់ៗ និងចែកជូនពួកគាត់នៅពេលចាប់ផ្តើមបើកវគ្គ។ អ្នកសម្របសម្រួលគួរប្រមូលឯកសារទាំងនេះដែលបានបំពេញរួច និងរក្សាទុកដើម្បីធ្វើការវិភាគ ( ដោយប្រើប្រាស់គំរូនៅក្នុងឧបសម្ព័ន្ធទី៦ ) បន្ទាប់ពីបញ្ចប់វគ្គ។

| សូមអានសំណួរនីមួយៗ និងជ្រើសរើសចម្លើយមួយ។ | | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១. | តើអ្នកយល់ថា "ការរំលោភបំពានផ្លូវភេទកុមារ" ជាអ្វីដែរឬទេ ? | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារកើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារ កើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថា កុមារអាចនឹងស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពានឬទេ ? | | | |
| ៧. | តើអ្នកដឹងអំពីអ្វីខ្លះដែលអ្នកអាចធ្វើបាន ក្នុងនាមជាឪពុកម្តាយ/អ្នកថែទាំ ដើម្បីជួយរក្សាសុវត្ថិភាពរបស់កុមារពីការរំលោភបំពានផ្លូវភេទទេ ? | | | |
| ៨. | តើអ្នកស្គាល់អ្នកដែលត្រូវទាក់ទងដែរឬទេ ប្រសិនបើអ្នកយល់ថាកុមារអាចនឹងត្រូវបានគេរំលោភបំពាន ? | | | |

# ឧបសម្ព័ន្ធទី៤៖ សំណួរក្រោយមេរៀន

**ការណែនាំ៖** យកល្អ សំណួរក្រោយមេរៀនវគ្គគួរធ្វើឡើងដោយផ្ទាល់មាត់។ យើងក៏អាចធ្វើសំណួរនេះជាលាយលក្ខណ៍អក្សរបានផងដែរ។ ច្បាប់ថតចម្លងនៃសំណួរខ្លីនេះ គួរថតចម្លងជូនអ្នកចូលរួមម្នាក់ៗ និងចែកជូនពួកគាត់នៅពេលបញ្ចប់វគ្គ។ អ្នកសម្របសម្រួលគួរប្រមូលឯកសារទាំងនេះដែលបានបំពេញរួច និងរក្សាទុកដើម្បីធ្វើការវិភាគ ( ដោយប្រើប្រាស់គំរូនៅក្នុងឧបសម្ព័ន្ធទី៦ ) បន្ទាប់ពីចប់វគ្គ។

| សូមអានសំណួរនីមួយៗ និងជ្រើសរើសចម្លើយមួយ។ | | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១. | តើអ្នកយល់ថា “ការរំលោភបំពានផ្លូវភេទកុមារ” ជាអ្វីដែរឬទេ ? | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារកើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារ កើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថា កុមារអាចនឹងស្ថិត ក្នុងគ្រោះថ្នាក់នៃការរំលោភបំពានឬទេ ? | | | |
| ៧. | តើអ្នកដឹងអំពីអ្វីខ្លះដែលអ្នកអាចធ្វើបាន ក្នុងនាមជាឪពុកម្ដាយ/អ្នកថែទាំ ដើម្បីជួយរក្សាសុវត្ថិភាពរបស់កុមារពីការរំលោភបំពានផ្លូវភេទទេ ? | | | |
| ៨. | តើអ្នកស្គាល់អ្នកដែលត្រូវទាក់ទងដែរឬទេ ប្រសិនបើអ្នកយល់ថា កុមារអាចនឹងត្រូវបានគេរំលោភបំពាន ? | | | |

# ឧបសម្ព័ន្ធទី៥: ប័ណ្ណសម្រាប់ការឆ្លើយតបមុនចាប់ផ្ដើម និងពេលបញ្ចប់



**ការណែនាំ៖** ប័ណ្ណទាំងនេះអាចប្រើប្រាស់ដើម្បីរៀបចំធ្វើសំណួរមុនចូលមេរៀននិងក្រោយមេរៀន ក្នុងលក្ខណៈជាលំហាត់ចង្អុល បង្ហាញ។ អ្នកចូលរួមម្នាក់ៗគួរទទួលបានប័ណ្ណនេះមួយសំណុំ ( សញ្ញា “ធីក” “សញ្ញាខ្វែង” និង “សញ្ញាសួរ” ) ។ អ្នកសម្របសម្រួលអាចសួរសំណួរនៅក្នុង ឧបសម្ព័ន្ធទី៣ ហើយអ្នកចូល រួមអាចបង្ហាញ ចម្លើយរបស់ខ្លួន ( បាទ/ចាស ទេ ឬ មិនដឹង )។ ចំនួន និងប្រភេទចម្លើយគួរត្រូវបានកត់ត្រាទុកនៅក្នុងគំរូ ដែលបានផ្ដល់ឱ្យនៅក្នុងឧបសម្ព័ន្ធទី៦។



# ឧបសម្ព័ន្ធទី៦: ទម្រង់គំរូវិភាគសំណួរមុនចូលមេរៀន និងក្រោយមេរៀន

**ការណែនាំ៖** សំណួរពេលចាប់ផ្ដើម/ពេលបញ្ចប់ អាចធ្វើក្នុងទម្រង់ជាសំណេរ ឬដោយផ្ទាល់មាត់។ គំរូនេះអាចប្រើប្រាស់បានដោយអ្នកសម្របសម្រួល ដើម្បីកត់ត្រាទុកនូវចម្លើយជាពាក្យសម្ដី ឬអាចប្រើក្រោយពីបញ្ចប់វគ្គ ដើម្បីរៀបជាលំដាប់ និងវិភាគលើចម្លើយជាលាយលក្ខណ៍អក្សរ។ សេចក្ដីសង្ខេប អាចដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធទី៨៖ ទម្រង់គំរូរបាយណ៍ក្រោយការបណ្ដុះបណ្ដាល។

| | | បញ្ចូលចំនួនអ្នកឆ្លើយ ក្នុងសំណួរនីមួយៗខាងក្រោម | | | | | |
|---|---|---|---|---|---|---|---|
| | | សំណួរមុនមេរៀន ពេលចាប់ផ្ដើមការពិភាក្សា | | | សំណួរក្រោយមេរៀន ពេលបញ្ចប់ការពិភាក្សា | | |
| | | ✔ | X | ? | ✔ | X | ? |
| ១. | តើអ្នកយល់ថា “ការរំលោភបំពានផ្លូវភេទកុមារ” ជាអ្វីដែរឬទេ ? | | | | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារកើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារកើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថាកុមារអាចនឹងស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពានឬទេ ? | | | | | | |
| ៧. | តើអ្នកដឹងអំពីអ្វីខ្លះដែលអ្នកអាចធ្វើបាន ក្នុងនាមជាឪពុកម្ដាយ/ អ្នកថែទាំ ដើម្បីជួយរក្សាសុវត្ថិភាពរបស់កុមារពីការរំលោភបំពានផ្លូវភេទទេ ? | | | | | | |
| ៨. | តើអ្នកស្គាល់អ្នកដែលត្រូវទាក់ទងដែរឬទេ ប្រសិនបើអ្នកយល់ថា កុមារអាចនឹងត្រូវបានគេរំលោភបំពាន ? | | | | | | |

# ឧបសម្ព័ន្ធទី៧៖ ទម្រង់មតិរបស់ខ្ញុំ

**ការណែនាំ៖** រៀបចំច្បាប់ថតចម្លងមួយច្បាប់នៃទម្រង់នេះសម្រាប់អ្នកចូលរួមម្នាក់ៗ។ ច្បាប់ថតចម្លង គួរត្រូវបានចែកចាយជូនដល់អ្នកចូលរួមនៅពេលបញ្ចប់វគ្គ។ ជម្រើសផ្សេងទៀត អ្នកសម្របសម្រួលអាចវាស់វែងចម្លើយរបស់អ្នកចូលរួមដោយផ្ទាល់មាត់ ដោយសួរទៅកាន់គេនូវសំណួរធម្មតាមួយចំនួនមានដូចជា៖ តើវគ្គនេះមានសារៈប្រយោជន៍ដែរឬទេ? តើព័ត៌មានអ្វីខ្លះដែលអ្នកបានសិក្សានៅថ្ងៃនេះ? តើមានអ្វីខ្លះដែលយើងគួរផ្លាស់ប្តូរសម្រាប់វគ្គបណ្តុះបណ្តាលបែបនេះនៅពេលអនាគត? វិធានសួរសំណួរផ្ទាល់មាត់បែបនេះត្រូវបានលើកទឹកចិត្តឱ្យធ្វើ។

## មតិរបស់ខ្ញុំ

យើងផ្តល់តម្លៃចំពោះមតិរបស់លោកអ្នក! សូមចែករំលែកព័ត៌មានត្រឡប់ដ៏ស្មោះត្រង់របស់អ្នក ដើម្បីជួយដល់យើងខ្ញុំក្នុងការកែលម្អការងារការពារកុមាររបស់យើង។

**១. តើអ្នកធ្វើការក្នុងវិស័យអ្វី?**

- ○ រដ្ឋាភិបាល
- ○ អាជីវកម្ម
- ○ សហគមន៍
- ○ បើផ្សេងពីនេះ សូមបញ្ជាក់:

**២. តើអ្នកមានភេទអ្វី?**

- ○ ស្រី
- ○ ប្រុស
- ○ ផ្សេងពីនេះ

**៣. សូមដាក់កម្រិតវាយតម្លៃដូចខាងក្រោម ៖**

| | | | |
|---|---|---|---|
| អ្នកសម្របសម្រួលពន្យល់ច្បាស់លាស់ ហើយមេរៀនមានភាពងាយស្រួលអនុវត្ត។ | ○ យល់ព្រម | ○ អព្យាក្រឹត្យ | ○ មិនព្រម |
| សម្ភារទាំងឡាយសុទ្ធតែមានប្រយោជន៍។ | ○ យល់ព្រម | ○ អព្យាក្រឹត្យ | ○ មិនព្រម |
| ការពិភាក្សា ជួយលើកកម្ពស់ការយល់ដឹងរបស់ខ្ញុំពីបញ្ហានេះ។ | ○ យល់ព្រម | ○ អព្យាក្រឹត្យ | ○ មិនព្រម |
| ការពិភាក្សាបានលើកទឹកចិត្តខ្ញុំឲ្យបង្កើនសកម្មភាពការពារកុមារ។ | ○ យល់ព្រម | ○ អព្យាក្រឹត្យ | ○ មិនព្រម |

៤. តើផ្នែកណាមួយនៃវេទិកាពិភាក្សានេះដែលមានសារៈប្រយោជន៍បំផុតសម្រាប់អ្នកនៅក្នុងការងារ/ជីវិតរបស់អ្នក ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

៥. តើយើងគួរធ្វើដូចម្ដេច ដើម្បីធ្វើឲ្យវេទិកាពិភាក្សានេះ មានលក្ខណៈកាន់តែប្រសើរឡើង ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

៦. សូមសរសេរអំពីអ្វីដែលអ្នកនឹងធ្វើខុសពីមុនដោយសារព័ត៌មាន និងធនធានដែលអ្នកបានទទួលក្នុងអំឡុងពេលនៃវេទិកាពិភាក្សានេះ។

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

៧. តើមានមតិយោបល់អ្វីផ្សេងដែរឬទេ ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

# ឧបសម្ព័ន្ធទី៨ ៖ គំរូរបាយការណ៍ក្រោយវគ្គបណ្តុះបណ្តាល

**ការណែនាំ៖** គំរូគួរត្រូវបានប្រើដើម្បីដាក់បញ្ចូលឧបករណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ដែលត្រូវបានប្រើប្រាស់នៅក្នុងវេទិកាពិភាក្សាគ្នានេះ។ គំរូនេះគួរត្រូវបានបំពេញដោយអ្នកសម្របសម្រួល ហើយចែករំលែកជាមួយអ្នកគ្រប់គ្រង/ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីជួយដល់ការត្រួតពិនិត្យតាមដានលើលទ្ធផលនៃការសិក្សា និងការធ្វើឱ្យប្រសើឡើងដល់សកម្មភាពនៅថ្ងៃក្រោយ។

**១. សំណួរមុនចូលមេរៀននិងពេលបញ្ចប់**

*រួមមានសេចក្តីសង្ខេបនៃឧបសម្ព័ន្ធទី៦៖ ការវិភាគសំណួរមុនចូលមេរៀននិងពេលបញ្ចប់។*

**២. មតិយោបល់របស់ខ្ញុំ**

*ត្រួតពិនិត្យឡើងវិញលើទម្រង់ "មតិយោបល់របស់ខ្ញុំ" ដែលទទួលបានដើម្បីធ្វើការសង្ខេបលើចំណុចខាងក្រោម៖*

១. សាវតារវិស័យ និងភេទ

| វិស័យ | ចំនួនសរុប | សរុប - ស្ត្រី | សរុប - បុរស | សរុប- ផ្សេងៗ |
|---|---|---|---|---|
| រដ្ឋាភិបាល | | | | |
| ធុរកិច្ច | | | | |
| សហគមន៍ | | | | |
| ផ្សេងទៀត | | | | |

២. ការកំណត់លំដាប់ថ្នាក់

| | ចំនួនយល់ព្រម % | | ចំនួនអព្យាក្រិត % | | ចំនួនមិនព្រម % | |
|---|---|---|---|---|---|---|
| អ្នកសម្របសម្រួលមានភាពច្បាស់លាស់ ហើយមេរៀនគឺ ងាយស្រួលក្នុងការអនុវត្តតាម។ | | | | | | |
| ឯកសារនេះគឺមានប្រយោជន៍ | | | | | | |
| ការពិភាក្សាជួយកែលម្អដល់ការយល់របស់ ខ្ញុំ អំពីបញ្ហានេះ | | | | | | |
| ការពិភាក្សាលើកទឹកចិត្តខ្ញុំឱ្យចាត់វិធានការបន្ថែមក្នុងការការពារកុមារ។ | | | | | | |

៣. រៀបរាប់ពីការជ្រើសរើសការឆ្លើយជា សម្រង់សម្តី "តើផ្នែកណាមួយនៃវេទិកាពិភាក្សានេះដែលមានសារៈប្រយោជន៍បំផុតសម្រាប់អ្នកនៅក្នុងការងារ/ជីវិតរបស់អ្នក ?"

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

៤. រៀបរាប់ពីការជ្រើសរើសការឆ្លើយនឹងសំណួរ (អាចជាសម្រង់សម្តី) "តើយើងគួរធ្វើអ្វីខ្លះដើម្បីកែលម្អវេទិកាពិភាក្សានេះ ?"

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

៥. រៀបរាប់ពីការជ្រើសរើសការឆ្លើយនឹងសំណួរ (អាចជាសម្រង់សម្តី) "សូមសរសេរអំពីអ្វីដែលអ្នកនឹងធ្វើខុសពីមុនដោយសារព័ត៌មាន និងធនធានដែលអ្នកបានទទួលក្នុងអំឡុងពេលនៃវេទិកាពិភាក្សានេះ។"

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

៦. រៀបរាប់អំពីមតិយោបល់ផ្សេងទៀត

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

## ៣. ការអង្កេតរបស់អ្នកសម្របសម្រួល

ការអង្កេតរបស់អ្នកសម្របសម្រួល គឺជាផ្នែកដ៏មានសារៈសំខាន់មួយ នៃការវាយតម្លៃ និងកែលម្អសកម្មភាពនានា។ អ្នកសម្របសម្រួលគួរសង្កេតមើលរបៀបដែលអ្នកចូលរួមឆ្លើយតបទៅនឹងសំណួររួមមាន អំពីរបៀដែលពួកគាត់ផ្សារភ្ជាប់ជាមួយនឹងសកម្មភាពក្រុម ទាំងរបៀបបែបដែលអ្នកចូលរួមចាប់អារម្មណ៍ ឬ មានអ្នកចូលរួមខ្លះសួរ សំណួរ ដែលពិបាកឆ្លើយ។ នេះគឺជាមធ្យោបាយមួយសម្រាប់វាស់វែងប្រតិកម្ម ការសិក្សា និងការផ្លាស់ប្តូរអាកប្បកិរិយា របស់អ្នកចូលរួម។

១. សូមពន្យល់ពីចំណាប់អារម្មណ៍ទាំងមូលរបស់អ្នកអំពីព្រឹត្តិការណ៍នៃវគ្គបណ្តុះបណ្តាល។

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

២. សូមពន្យល់ពីបញ្ហាទាំងឡាយណាដែលអ្នកធ្លាប់ជួបប្រទះ ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

៣. តើមានការលើកឡើងពីបញ្ហា ការការពារកុមារ ដែលសារៈសំខាន់ៗដែរឬទេ ?

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

៤. សូមផ្តល់មតិយោបល់លើការយល់ដឹង និងការចូលរួមរបស់អ្នកចូលរួម។

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

៥. តើមេរៀនអ្វីខ្លះដែលអ្នកបានកំណត់សម្រាប់ព្រឹត្តិការណ៍ទៅថ្ងៃអនាគត ?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

៦. តើវគ្គបណ្តុះបណ្តាល និងឯកសារសម្រាប់ការបណ្តុះបណ្តាលនេះអាចត្រូវបានកែលម្អបានយ៉ាងដូចម្តេច ?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

៧. តើត្រូវការការបណ្តុះបណ្តាលបន្ថែមដែរឬទេ ? សម្រាប់នរណា ? ហេតុអ្វី ?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

# កត់ចំណាំ

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

……………………………………………………………………

# កត់ចំណាំ

ឯកសារសម្រាប់ការអប់រំផ្សេងទៀតដែលត្រូវបានផលិតឡើងសម្រាប់គម្រោងកុមារភាពផ្អែកបង្ការរួមមាន៖




*រក្សាសុវត្ថិភាពកុមារឱ្យរួចផុតពីការរំលោភបំពាន៖*
*កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង*




*រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖*
*កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍*




*រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍៖*
*កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្រប សម្រួលក្នុងវគ្គបណ្ដុះបណ្ដាលប្រតិបត្តិករវិស័យទេសចរណ៍*

ឯកសារនេះក៏មានជាភាសាខ្មែរ ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឱ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

កុមារដែលធ្វើការ និងរស់នៅក្នុងមជ្ឈដ្ឋានវិស័យទេសចរណ៍ងាយរងគ្រោះជាពិសេសទៅនឹងការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ វាមានសារៈសំខាន់ណាស់ដែលឪពុកម្ដាយ និងអ្នកផ្ដល់ការថែទាំត្រូវចូលទៅរកព័ត៌មានត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ដូច្នេះគេអាចការពារកុមារបានកាន់តែប្រសើរ ពីការបង្កផលប៉ះពាល់។

*ឯកសារស្ដីពី រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖ កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួលក្នុងវេទិកាពិភាក្សាជាមួយឪពុកម្ដាយ និងអ្នកថែទាំ* ផ្ដល់នូវគោលការណ៍ដែល ងាយស្រួលក្នុងការ  អនុវត្តតាម និងឧបករណ៍នានាសម្រាប់អ្នកសម្របសម្រួលដើម្បីប្រើប្រាស់ សម្រាប់រៀបចំវេទិកាពិភាក្សានេះជាមួយនឹងឪពុកម្ដាយ និងអ្នកថែទាំ។ កញ្ចប់ឧបករណ៍នេះត្រូវបានតាក់តែងឡើងដើម្បីផ្ដល់ចំណេះដឹង និងជំនាញដល់អ្នកចូលរួម ក្នុងការការពារកុមារ ដែលស្ថិតក្រោមការថែទាំរបស់ខ្លួនពីការរំលោភបំពានផ្លូវភេទ និងមានរៀបរាប់អំពីអ្វីៗគ្រប់យ៉ាងដែលចាំបាច់សម្រាប់អ្នកសម្របសម្រួល ក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលដែលមានការចូលរួមខ្ពស់ ទោះជាក្នុងបរិបទផ្លូវការ និងក្រៅផ្លូវការ ជាមួយនឹងសម្ភារបរិក្ខារ ឬបច្ចេកវិជ្ជាតិចបំផុត។

ឯកសារនេះក៏មានជាភាសាខ្មែរ ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឱ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

**Child Safe Tourism**

Take action against abuse

គម្រោងកុមារភាព គឺជាគំនិតផ្ដួចផ្ដើមរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បាននាំមកនូវកិច្ចសហការគ្នា រវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ កម្មវិធីបានផ្ដោតទៅលើទាំងផ្នែកទប់ស្កាត់ និងការការពារ។

Australian Aid

World Vision®